ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៤៤**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា (បម្រុង)

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក អាឡាញ ប្រែអត *(Mr.Aline BRIOT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាធិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្រ្វង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គង់ ពិសី

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

លោក អាឡាំង វ៉ែនណឺ *(Mr. Alain WENER)*

**មេធាវីជំនួយរបស់សាក្សី៖**

លោក គង់ សំអុន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក ម៉ម ណៃ ហៅ ចាន់

សួរបន្តដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៦
សួរដោយ ចៅក្រម ធូ មណី ផ្តើមពី ........ ទំព័រ ៩
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍ ផ្តើមពី ........ ទំព័រ ៣០
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៤១

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រ ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺន៍ | បារាំង |
| លោក ម៉ម ណៃ ហៅ ចាន់ | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក វីលៀម ស្មីត | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:១១:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មរបស់សាក្សីមួយរូបឈ្មោះ ម៉ម ណៃ ហៅចាន់ ។

អរុណសួស្តីលោកម៉ម ណៃ អញ្ជើញលោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ យើងសូមថ្លែងអំណរគុណចំពោះវត្តមានរបស់មេធាវីដែលជាអ្នកតំណាងឲ្យលោក ម៉ម ណៃ ។ ប៉ុន្តែ មេធាវីការពារសូមសម្តែងនូវការរក្សាសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងគំនិតមួយដែលថា សហសេវិករបស់យើងត្រូវបានសូមឲ្យអង្គុយនៅខាងផ្នែកមេធាវីការពារក្នុងជួរជា-មួយយើង នេះជាគំនិតមួយដូចថាបានសម្រេច មុននឹងមានសំណើខាងសហព្រះរាជអាជ្ញាដែលទាក់ទងទៅនឹងលោក ម៉ម ណៃ រាល់ថ្ងៃនេះថា ពេលនេះថា គាត់ជានៅប៉ែកខាងជនជាប់ចោទ ។ ដូច្នេះថ្ងៃនេះយើងពិនិត្យឃើញថាលោក ម៉ម ណៃ មានអ្នកតំណាងផ្លូវច្បាប់ជាមេធាវីតំណាងគាត់ ដែលនៅជួរខាងជនជាប់ចោទ ។ ដូច្នេះ មើលទៅដូចជាមិនស្របចំពោះយើងខ្ញុំទេ អ៊ីចឹងប្រសិនបើលោក ម៉ម ណៃ មានសិទ្ធិ ហើយមានមេធាវីតំណាង ហើយមេធាវីតំណាងនោះគប្បីតែអង្គុយជិតគាត់ មិនត្រូវអង្គុយនៅខាងមេធាវីការពារ នៅខាង ឌុច នោះទេ ។ សូមអរគុណលោកប្រធាន ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! យើងគាំទ្រនូវសំណើដែលលើកឡើងដោយលោកមេធាវី ហ្វ្រង់ស្វ័រ រូ ពីព្រោះយើងពិនិត្យមើលឃើញថា មិនសមស្របទេប្រសិនបើអ្នកតំណាងមេធាវីរបស់លោក ម៉ម ណៃ ទៅអង្គុយខាងផ្នែក ខាងមេធាវីការពារនោះ ។ យើងពិចារណាហើយគិតថា វាអាចនឹងសមស្របដែលថាគាត់ជា-- លោក ម៉ម ណៃ ជាសាក្សី ហើយមេធាវីរបស់គាត់គប្បីតែមានស្ថានភាពមួយ ដែលមេធាវីរបស់គាត់គប្បីតែអង្គុយនៅជិតគាត់ ។ ហើយប្រហែលអាចនឹងទទួលការណែនាំទាក់ទងទៅនឹងលោក ម៉ម ណៃ ។

អ៊ីចឹងយើងគាំទ្រគំនិតដែលលើកឡើងដោយមេធាវីការពារ ។ សូមអរគុណ ។

[០៩:១៥:៥៣]

**លោក វីលៀម ស្មីត៖**

សូមគោរពលោកប្រធាន មេធាវី លោក លោកស្រី ហើយនិងមេធាវី ហើយខ្ញុំមិនដឹងថា សាក្សីមិនទាន់បានដឹងពីរឿងហ្នឹង លើកលែងតែគាត់បានឮពីមេធាវី ។ អ៊ីចឹងហើយ យើងមានកៅអីច្រើននៅក្នុងសាលសវនាការនេះ ទាក់ទងទៅនឹងទីកន្លែងថាមេធាវីគប្បីអង្គុយកន្លែងណា គឺជាការសិទ្ធិរបស់អង្គជំនុំជម្រះជាអ្នកសម្រេច ។ អ៊ីចឹងហើយ គឺយើងមានការលើកឡើងពីចំណុចចាប់អារម្មណ៍ថាតើមេធាវីគាត់អាចលើកឡើងអង្គុយកន្លែងណា ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ចំណុចមួយទាក់ទងទៅនឹងនីតិវិធីពីម្សិល-មិញហ្នឹង ដែលមេធាវីការពារបានលើកឡើងថាចំណុចមួយដែលថា សាក្សីនេះគប្បីតែជូនដំណឹង ជូនដំណឹងទាំងស្រុងអំពីសិទ្ធិ អំពីការមិនឆ្លើយដាក់បន្ទុកលើខ្លួនឯងនេះ ដូចដែលលោកប្រធានជ្រាបហើយគឺថាលោកប្រធានបានជម្រាបសិទ្ធិនេះទៅគាត់ហើយ មុនពេលដែលមេធាវីគាត់លើកការជំទាស់ ហើយយើងក៏មានការព្រួយបារម្ភ មេធាវីមានការព្រួយបារម្ភមួយទៀត ដែលថា គាត់មិនបានដឹងពីសិទ្ធិរបស់គាត់ទាំងស្រុង ។ ពេលនោះខ្ញុំមិនទាន់យល់ច្បាស់នៅឡើយទេ ថាតើសាក្សីហ្នឹងបានដឹង ឬមិនបានដឹងពីសិទ្ធិរបស់គាត់ទាំងស្រុងទេ ដូចដែលលោកចៅក្រមជ្រាបហើយ វិធាន២៨ វិធាននេះគឺថាយើង ចុច៨នេះ គឺមិនគប្បីលើកឡើងចំពោះរូបគាត់ពេលនេះទេ គប្បីតែលើកលែងមុនពេលដែលគាត់ផ្តល់សក្ខីកម្ម។ អ៊ីចឹងការព្រួយបារម្ភហ្នឹងគប្បីតែលើកឡើងនៅក្នុងសវនាការជាសម្ងាត់ ។

អ៊ីចឹង គឺមិនគប្បីការរំឭកនេះឲ្យលេចឮជាសាធារណៈទេ ដោយហេតុថាសាក្សីនេះគាត់ជាអតីតបុគ្គលិកមកពីស-២១ ។ អ៊ីចឹងសាក្សីនេះមិនមែនសាក្សីតែមួយរូបដែលថា ជាអ្នកសួរចម្លើយឬអ្នកយាមនៅស-២១ ប៉ុណ្ណោះទេ អ៊ីចឹងគឺថា យើងអាចនឹងត្រូវអនុវត្តន៍នីតិវិធីនេះ ឲ្យបានត្រឹមត្រូវ គឺថាត្រូវមានការណែនាំក្នុងដំណើរការនីតិវិធីនេះឲ្យបានសមស្រប ដោយធ្វើយ៉ាងម៉េចកុំឲ្យមានការរំឭកឡើងទៅដល់សាក្សីជាមុននោះ ដូចដែលលោកចៅក្រមជ្រាបហើយ គឺថាការិយាល័យគាំពារការពារក្តី ហើយនិងសហព្រះរាជអាជ្ញាបានធ្វើការចរចាជាច្រើនដើម្បីរករូបមន្តដ៏ល្អមួយ ដើម្បីស្នើទៅដល់អង្គជំនុំជម្រះ ដើម្បីរកកម្រិតមួយដែលសមស្រប ដែលថា ធ្វើយ៉ាងណាយើងអាចធ្វើសវនាការចំពោះអតីតបុគ្គលិករបស់ស-២១ ឲ្យបានត្រឹមត្រូវដើម្បីចៀសវាងអ្វីដែលកើតឡើងដូចម្សិលមិញ ដែលថា ធ្វើឲ្យសាក្សីមានការភ័យខ្លាច ដោយសារថាមានលទ្ធភាពនៃការចោទប្រកាន់ទៅលើគាត់ ដោយសារលទ្ធភាពនោះវានៅឆ្ងាយណាស់ ។ នេះហើយយើងបានដាក់សំណើនេះជូនអង្គជំនុំជម្រះនេះ ។

[០៩:១៩:០៥]

អ៊ីចឹងគឺយើងត្រឡប់ទៅមេធាវីរបស់គាត់ គឺយើងមើលវិធាន២៨.៨ នៅពេលដែលភាគីបានដឹងថា សក្ខីកម្មរបស់សាក្សីណាមួយដែលលើកឡើងពីចំណុចដែលអាចនឹងដាក់បន្ទុកលើខ្លួនឯង ឬក៏សាក្សីខ្លួនឯងដឹងពីរឿងហ្នឹង គឺសាក្សីនោះ គឺថាអាចស្នើសុំឲ្យមានការសវនាការជាអសាធារណៈ ហើយនិង-- ហើយអាចនឹងត្រូវ-- នៅពេលដែលសាក្សីឡើង-- លើកឡើងនូវបញ្ហានេះ គឺត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតនិងអង្គជំនុំជម្រះពីបញ្ហានេះ ។ អ៊ីចឹង គាត់មានឱកាសពេញលេញដើម្បីនឹងលើកឡើងមុននឹងមកតុលាការហ្នឹង ហើយយើងរង់ចាំៗរហូតទាល់តែគាត់ចូលមកដល់កន្លែងអង្គុយរបស់សាក្សីហ្នឹង ហើយគាត់រង់ចាំ-- ហើយមេធាវីការពារ ហើយភាគីផ្សេងៗនៅក្នុងសាលសវនាការបានស្វែងរកតុល្យភាពដើម្បីឲ្យមានការការពារផ្លូវច្បាប់នៅពេលមួយដែលសមស្របនោះ ។

លោកចៅក្រមជាទីគោរព! ហើយបញ្ហាមួយទៀត ទទ្ធីករណ៍ដែលលើកឡើងពីដំបូងនោះ ។ ខ្ញុំបញ្ជាក់ឡើងវិញក្នុងន័យនេះដោយសារថា សហកម្មខក្រិដ្ឋកម្មរួមបានលើកឡើង ហើយបានដាក់ជូនដើម្បីឲ្យមានការពិចារណាដោយអង្គជំនុំជម្រះ ទាក់ទងនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទហ្នឹង ទាក់ទងទៅនឹងសាក្សីនេះ គឺយើងមិនបានដឹង ។ ឥឡូវនេះ អ្វីដែលយើងផ្តល់ការអះអាងគឺមិនមាន-- ហើយមានសុពលភាព ដោយសារថាសំណើនេះនឹងត្រូវបានរង់ចាំការសម្រេចនូវសេចក្តីសម្រេចចុងក្រោយ ។ ដូច្នេះគឺមិនមានន័យ គឺថាមិនត្រឹមត្រូវទេ គឺមានទ្រឹស្តីជាច្រើនតាមតុលាការយើងនេះ ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌផ្ទាល់ខ្លួនទាក់ទងទៅនឹងការជំរុញញុះញង់ ការគាំទ្រ និងការប្រព្រឹត្តិបទល្មើសជាដើមហ្នឹង គឺជាទ្រឹស្តីដែលថា បុគ្គលណាម្នាក់នៅក្នុងស-២១ គឺថាអាចនឹងចោទប្រកាន់ ប៉ុន្តែ ខ្លឹមសារនេះវានៅឆ្ងាយពីវិសាលភាពណាស់ ។ អ៊ីចឹងហើយ អ្វីដែលមេធាវីការពារអន្តរាគមន៍នោះគឺមិនត្រឹមត្រូវ មិនសមស្រប ហើយខ្ញុំសូមស្នើថា ដើម្បីធ្វើបានល្អនៅអនាគតនោះ បើសិនជាបញ្ហាហ្នឹងលើកឡើង សូមលើកឡើងក្នុងសវនាការអសាធារណៈ កុំឲ្យសាក្សីគាត់បានដឹងដូចពីម្សិលមិញនោះ ។ សូមអរគុណ ។

**លោក ហ្វ្រង់ស្វ័រ រូះ**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនអាចទុកមិនឆ្លើយតបទៅលើកឡើងរបស់សហព្រះរាជអាជ្ញានោះទេ ដែលហាក់ដូចជាគាត់ធ្វើជាមិនយល់ទៅលើចំណុចហ្នឹង ប៉ុន្តែគាត់បានយល់ច្បាស់ណាស់ទៅលើបញ្ហាទាំងអស់នេះ ។

[០៩:២២:៣០]

យើងៗមិនស្ថិតនៅក្នុងបរិបទកម្រិតនៃវិធាន២៨.៩ នោះទេ ហើយខ្ញុំបានលើកចំណុចនេះយ៉ាងច្បាស់កាលពីម្សិលមិញ ។ យើងបានអនុវត្តន៍ហួសទៅលើវិធាននេះ ។ លោកប្រធានបានជម្រាបអំពី-- ជម្រាបសាក្សីអំពីការចៀសវាងមិនដាក់បន្ទុកខ្លួនឯង ហើយសាក្សីនេះក៏បានជម្រាបអំពីពាក្យសុំដែលបានធ្វើឡើងផងដែរ ដែលពាក្យសុំនេះគឺបានដាក់ឡើងទាក់ទងទៅនឹងសហកម្មឧក្រិដ្ឋកម្មរួម ហើយចំណុចនេះគឺវាជាចំណុចមួយដែលខុសគ្នាទាំងស្រុងតែម្តង ។

លោកបានលើកឡើងអំពីជម្រើស លោកបានធ្វើការជ្រើសរើស ហើយលោកបានពន្យល់ថាជម្រើសនោះគឺវាមិនមានភាពចាំបាច់នោះទេ ដោយសារតែវាមានលទ្ធភាពផ្សេងទៀតក្នុងការដាក់បន្ទុកខ្លួនឯងរបស់សាក្សី ។ ដូច្នេះ នេះជាសំណួរដែលខ្ញុំចង់សួរ។ នៅថ្ងៃនេះ តើលោកនៅតែស្នើសុំឱ្យធ្វើការពិចារណាទៅលើសហកម្មឧក្រិដ្ឋកម្មរួមទៀត ឬយ៉ាងម៉េច? លោកបានលើកឡើងថា វាមិនមានភាពចាំបាច់នោះទេ ។ អ៊ីចឹងគឺតើលោកនៅរក្សាការដាក់សំណើរបស់លោកឬយ៉ាងម៉េច? ហើយមេធាវីរបស់ម៉ម ណៃ នៅថ្ងៃនេះ ថាតើលោកនៅរក្សាពាក្យសុំសហកម្មឧក្រិដ្ឋកម្មរួមដែរឬទេ? អ៊ីចឹងថាតើសហព្រះរាជអាជ្ញានៅរក្សាជំហររបស់ខ្លួនទៅលើពាក្យសុំនេះដដែលឬយ៉ាងម៉េច?

ប្រសិនបើ ឌុច នោះគាត់នឹងមានពិរុទ្ធភាពទាក់ទងទៅនឹងសកម្មឧក្រិដ្ឋកម្មរួម វានឹងមានន័យជាស្វ័យប្រវត្តិថា សាក្សីនេះនឹងមានពិរុទ្ធភាពដែរ នឹងអាចគេរកឃើញពិរុទ្ធភាពដែរ ។ តើលោកសហព្រះរាជអាជ្ញានៅតែរក្សាជំហរហ្នឹងដដែលឬក៏យ៉ាងម៉េច? ប្រសិនបើលោកនៅរក្សាជំហរនេះដដែលសូមឱ្យលោកសហព្រះរាជអាជ្ញាជម្រាបមេធាវីនិងសាក្សីរបស់គាត់ ។ ដូច្នេះ ចំណុចនេះដែលយើងចង់ដឹងខ្លាំងណាស់ ថាតើលោកនៅរក្សាជំហរ ឬក៏យ៉ាងម៉េច?

**លោក វីលៀម ស្មីត៖**

ខ្ញុំមិនដឹងថា ខ្ញុំត្រូវលើកប៉ុន្មានដងទៀត ទាក់ទងទៅនឹងបញ្ហានេះទេ មិនថាជនជាប់ចោទនេះគាត់រកឃើញ-- ត្រូវបានរកឃើញពិរុទ្ធភាព ឬក៏អត់នោះទេ គឺវាមានភាពពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទៅលើបុគ្គលណាផ្សេង ទោះបីជាពួកគេនៅឆ្ងាយពីការឧក្រិដ្ឋកម្មក៏ដោយ ។ ដូច្នេះហើយគឺវាមិនមានឥទ្ធិពលឬសក្តានុពលក្នុងការមិនចោទប្រកាន់ទៅលើបុគ្គលណានោះទេ ។ ទាំងការចោទប្រកាន់នោះវានៅឆ្ងាយណាស់ ដូច្នេះ ហើយបញ្ហានេះគួរតែលើកនៅក្រៅពីពេលដែលយើងវត្តមានសាក្សីនេះ ។ ប៉ុន្តែ ខ្ញុំមិនដឹងថា ខ្ញុំត្រូវលើកបញ្ហានេះប៉ុន្មានដងនោះទៀតទេ ហើយការទទួលខុសត្រូវនេះវាមិនមានភាពខុសគ្នាចំពោះការទទួលខុសត្រូវ និងទម្រង់នៃការទទួលខុសត្រូវផ្សេងៗនោះទេ ។ សូមអរគុណ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ដូច្នេះ អ៊ីចឹងលោកសូមដកពាក្យសុំរបស់លោកក្នុងការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួមទៅចំណុចនឹងវាអាចធានាបានទៅលើករណីដែលយើងអនុវត្តន៍នៅទីនេះ ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវមតិចំណាប់អារម្មណ៍របស់អស់លោក លោកស្រីជាមេធាវី និងតំណាងសហព្រះរាជអាជ្ញា ដែលបានលើកឡើងពាក់ព័ន្ធនឹងបញ្ហានេះ ។ ទីមួយ គឺអង្គជំនុំជម្រះជម្រាបជំហរថា អង្គជំនុំជម្រះបានពិចារណាពិភាក្សាគ្នាយ៉ាងល្អិតល្អន់សម្រេចផ្តល់អាសនៈឲ្យមេធាវីរបស់ ម៉ម ណៃ នៅទីនោះ គឺកន្លែងដែលមេធាវីរបស់គាត់អង្គុយនេះ ។ ហើយការសម្រេចនេះ អរគុណណាស់ដែលមេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី អន្តរជាតិដែលបានលើកឡើងពីបញ្ហាកង្វល់នៃការភាពភាន់ច្រឡំនេះ ។ ប៉ុន្តែ អង្គជំនុំជម្រះបានសម្រេចជ្រើសរើសយកកន្លែងនោះ មិនមានន័យថា ឬក៏មានខ្លឹមសារថា សាក្សីរូបនេះជាជនជាប់ចោទនោះទេ ឬក៏មានពិរុទ្ធភាពនោះទេ ។ ការជម្រើសទីតាំងកន្លែងនេះទីមួយ គឺកន្លែងសមរម្យដែលទូលាយ អាចឲ្យគាត់អង្គុយបាន ។

ទីពីរ ឲ្យគាត់នៅទីនេះ គឺគាត់ជិតនឹងសាក្សីរូបនេះ ដែលគាត់អាចមើលគ្រប់អាកប្បកិរិយារបស់សាក្សី ដែលគាត់ការពារនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មនេះ ដើម្បីគាត់មានឱកាស ឬក៏មានលទ្ធភាពក្នុងការលើកឡើងនូវសំណូមពរផ្សេងៗ ដើម្បីគាត់បានធ្វើការប្រាស្រ័យទាក់ទង ឬក៏ប្រឹក្សាជាមួយសាក្សីរូបនេះ ។

ទីបី អង្គជំនុំជម្រះនឹងជម្រាបជូនដល់ភាគី និងសាធារណជនយល់នឹងជ្រាបអំពីកន្លែងអង្គុយនេះគ្រាន់តែជារូបភាពមិនអាចភាន់ច្រឡំងាយៗនោះទេ ។ ទីបី គាត់ជាមេធាវីដូចអស់លោក លោកស្រីដែរគប្បីរៀបរយកន្លែងគាត់សមរម្យសមស្រប ដើម្បីដំណើរការនីតិវិធីឲ្យបានច្បាស់លាស់ជាក់លាក់ក្នុងការការពារកូនក្តីរបស់ខ្លួន ។ ចំណុចមួយទៀត នៅក្នុងដំណើរការសវនាការនេះ សិទ្ធិចាត់ចែងនៅក្នុងការរៀបចំដំណើរការនោះ គឺជាសិទ្ធិរបស់អង្គជំនុំជម្រះនៅក្នុងការចាត់ចែងថាតើធ្វើយ៉ាងណា ។

[០៩:២៩:៤៥]

ទីពីរអង្គជំនុំជម្រះសង្កេតឃើញថា ការក្រោកឈរឡើងនិយាយដោយសេរីគ្មានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះ នេះគឺគប្បីបញ្ឈប់កុំឲ្យមានទៀត ។ ការជជែកវែកញែកត្រូវមានការអនុញ្ញាតត្រឹមត្រូវ ។

លោកមិនអនុញ្ញាតទេណ៎ា ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោក ម៉ម ណៃ ដល់ពេលនេះ តើលោកបានទទួលជំនួយមេធាវីហើយឬនៅ? លោក ម៉ម ណៃ?

**សាក្សី ម៉ម ណៃ៖**

**ឆ៖** បាទ, បានទទួលហើយ ។

**ស៖** តើមេធាវីជំនួយរបស់លោកគាត់ឈ្មោះអ្វីដែរ?

**ឆ៖** មេជំនួយរបស់ខ្ញុំបាទឈ្មោះ គង់ សំអុន ។

**ស៖** គាត់មានវត្តមាននៅក្នុងអង្គសវនាការនេះដែរឬទេ?

**ឆ៖** គាត់នៅក្នុងអង្គសវនាការនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន ក្រោកឈរ ។ បាទ, នេះគឺជាមេធាវី គង់ សំអុន ដែលលោកជាមេធាវីជំនួយដល់សាក្សី ម៉ម ណៃ ដោយសារលក្ខណៈពិសេសនៃសាក្សីរូបនេះ ហើយគាត់បានស្នើសុំថា ឱ្យមានសាក្សីជំនួយប្រឹក្សានៅក្នុងអំឡុងពេលធ្វើសក្ខីកម្ម ។ ហេតុដូច្នេះ ហើយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញសហការជាមួយនឹងការិយាល័យនានានៅក្នុង អ.វ.ត.ក បានសម្រេចជ្រើសរើសគាត់ ដើម្បីឱ្យគាត់ជាជំនួយដល់សាក្សីរូបនេះនៅក្នុងដំណើរការក្តី ។ ដូច្នេះ សូមជម្រាបសាធារណជនជ្រាបថា គាត់មិនមែនជាមេធាវីការពារក្តីឱ្យជនជាប់ចោទទេ គឺគាត់ជាមេធាវីជំនួយដល់ចំពោះមុខចំពោះសាក្សី ដោយសារលក្ខណៈនៃសាក្សីមានលក្ខណៈពិសេសតែប៉ុណ្ណោះ ។

សូមអញ្ជើញអង្គុយចុះលោកមេធាវី ។

**សួរដោយប្រធានអង្គជំនុំ៖**

លោក ម៉ម ណៃ តើលោកបានប្រឹក្សាយោបល់ជាមួយមេធាវីរបស់លោករួចហើយឬនៅ?

[០៩:៣៣:០៥]

**ឆ៖** បានពិគ្រោះគ្នារួចហើយ ។

**ស៖** ឥឡូវនេះលោកអាចឆ្លើយនូវសំណួរនានា ដែលអ្នកដំណើរការនីតិវិធីនឹងសួរលោកនាពេលនេះបានដែរឬទេ?

**ឆ៖** អាចសួរបាន ។

**ស៖** លោក ម៉ម ណៃ ចូរលោកនិយាយរៀបរាប់អំពីទីកន្លែងធ្វើការ និងរស់នៅរបស់លោកនៅក្នុងចន្លោះឆ្នាំ១៩៧០ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ តើលោករស់នៅទីណា? លោកធ្វើការអ្វីឬប្រកបមុខរបរអ្វីដែរ?

**ឆ៖** ក្រោយឆ្នាំ១៩៧០ ខ្ញុំជាសាស្ត្រាចារ្យបង្រៀននៅអ្នកលឿង នៅកន្ទួត ហើយក្រោយមក គឺថានៅឆ្នាំ១៩៧៣ មានការធ្វើមីទិ្ទងទាមទារតម្លើងប្រាក់ខែនៅគរុកោសល្យ វិទ្យាស្ថានគរុកោសល្យខាងត្បូង ។ ពេលនោះពួកទាហានរបស់ លន់ ណុន បានបាញ់សម្លាប់អ្នកចូលរួមធ្វើមីទិ្ទងនោះ ។ ហើយក្រោយមកក៏ខ្ញុំត្រូវរត់ទៅព្រៃ ទៅនៅរៀនសូត្រជីវនយោបាយនៅក្រាំងក្តិប ។ ក្រោយពីនោះមក បានមិត្តឌុច ដែលធ្លាប់ស្គាល់គ្នាតាំងពីនៅរៀនត្រៀម សញ្ញាប័ត្រត្រៀមឧត្តមសិក្សា បរិញ្ញាប័ត្រនោះ ហើយជាអ្នកដែលធ្លាប់សម័យស្តេច សីហនុ ចោទប្រកាន់ថាធ្វើខ្មែរក្រហមចាប់ដាក់គុកនៅព្រៃសជាមួយគ្នា បានក្រោយរៀនសូត្រនយោបាយហើយ គាត់បានសុំខ្ញុំយកទៅនៅជាមួយគាត់នៅអមលាំង ជាកន្លែងសន្តិ-សុខ ។ ក្រោយមកក៏-- ក្រោយ១៧ មេសា ១៩៧៥ ក៏មកនៅភ្នំពេញ ។

**ស៖** ចាប់ពីក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកមកនៅភ្នំពេញ តើលោកមកធ្វើការងារអ្វីនៅទីណា រហូតដល់ថ្ងៃរំដោះថ្ងៃ៧ មករា ឆ្នាំ១៩៧៩?

**ឆ៖** ខ្ញុំធ្វើការនៅផ្នែកសន្តិសុខ ដំបូង គឺនៅកន្លែង *ប៉េអេស (PS)*។ ក្រោយមកបានមកនៅម្តុំទួលស្វាយព្រៃ ។ នៅទីនោះរហូតដល់ថ្ងៃដែលកងទ័ពវៀតណាមចូលមកដល់ភ្នំពេញ ខ្ញុំក៏រត់ទៅទិសខាងលិចទៅ ។

**ស៖** លោកអាចនិយាយរៀបរាប់អំពីការងារដែលលោកបានធ្វើជាសន្តិសុខនៅមន្ទីរសន្តិសុខដែលលោកអះអាងអំមិញថា នៅអមលាំងហ្នឹង និងទិដ្ឋភាពទាំងឡាយដែលលោកបានឃើញនៅទីនោះវាយ៉ាងម៉េច? ទីមួយខ្លួនលោក តើលោកធ្វើអ្វី ក្នុងកិច្ចការនៅមន្ទីរសន្តិសុខនេះ? ហើយមានភារកិច្ចធ្វើអ្វីខ្លះ? ទីពីរ ថាតើទិដ្ឋភាពផ្សេងទៀតដែលលោកបានឃើញនោះ លោកបានឃើញស្ថានភាពនិងទិដ្ឋភាពនៅទីនោះយ៉ាងម៉េចខ្លះ រវាងអ្នកគ្រប់គ្រង ហើយនិងអ្នកដែលគេគ្រប់គ្រងនៅទីនោះ?

[០៩:៣៩:១០]

**ឆ៖** មិត្តឌុច បានសុំខ្ញុំយកពីក្រាំងក្តិបទៅៗមន្ទីរសន្តិសុខជាមួយនឹងគាត់ ។ ខ្ញុំទៅដល់ដំបូងខ្ញុំមានបញ្ហាសតិអារម្មណ៍ដែរ ព្រោះថា ខ្ញុំមិនធ្លាប់នៅក្នុងព្រៃ ដល់ទៅខ្ញុំមានការវាចង្អៀតចង្អល់ក្នុងចិត្ត

ដែរ ។ ខ្ញុំពេលនោះប្រហែលជាលាយឡំជាមួយជំងឺគ្រុនចាញ់ផង ខ្ញុំបានសុំ មិត្តឌុច ថាទៅនៅជាមួយ ខ្មោច ទិន គឹមហុង វិញ ។ ហើយឯភារកិច្ចរបស់ខ្ញុំពេលនោះ វាច្របូកច្របល់ វាមិនច្បាស់លាស់ ពីព្រោះថា ខ្ញុំទៅដល់មុនដំបូង គឺគាត់គ្រាន់តែអត់មានប្រគល់ភារកិច្ចអីឲ្យទេ មុនដំបូង ។ ខ្ញុំក៏កាប់គាស់ ព្រៃព្រិចក្បែរមន្ទីរហ្នឹង ហើយនាំគ្នាដាំដំឡូងជ្វា ។ ជួនកាលគាត់ប្រើខ្ញុំទៅតំបន់៣១ ទាក់ទងនឹងប្រធាន តំបន់៣១ ដើម្បីសុំនេះសុំនោះពីប្រធានតំបន់ហ្នឹង ពីព្រោះហ្នឹងធ្លាប់ស្គាល់គ្នា កាលជាប់គុកកាលសម័យ សម្ដេចសីហនុដែរ ។ ក្រោយមកគាត់មិនបានឲ្យខ្ញុំទៅនៅជាមួយ ទិន គឹមហុង ក៏ប៉ុន្តែក្រោយមកគឺថា ខ្ញុំនៅតែធ្វើការងារដាំបន្លែ ដាំដំឡូងអីហ្នឹងទៅ ។ ដល់យប់ឡើងគឺ គាត់ឲ្យអង្គុយមើលគាត់សួរចម្លើយ ។ ដូច្នេះ ខ្ញុំយល់ថា ជាការរៀនសូត្រនៃការសួរចម្លើយ ។ ក្រោយមកក៏ឲ្យខ្ញុំសួរចម្លើយមនុស្សដែលមិនជា សំខាន់នៅពេលយប់ៗ ។ ឯសភាពការណ៍នៅពេលនោះ គឺមានអ្នកជាប់ចោទដែរ តែជាប់ចោទតិច ឯកងការពារក៏តិច ហើយច្រើនតែ-- តិចហើយ មានច្រើនតែក្មេងៗទៀត ។ នេះខ្ញុំសូមជម្រាបលោក ប្រធានប៉ុណ្ណឹង ។

**ស៖** លោកគិតមើលថាតើអាទិភាពនៃមន្ទីរសន្តិសុខអមលាំងហ្នឹង ទីមួយ តើមន្ទីរនោះគេកំណត់ ថាឈ្មោះអ្វីដែរ? ហើយចាប់មានពីពេលណា រហូតដល់ពេលណា ទើបត្រូវបិទទ្វារ ឬក៏ត្រូវបញ្ឈប់លែង ឲ្យ-- លែងធ្វើសកម្មភាពទៀត?

**ឆ៖** មន្ទីរសន្តិសុខនោះ ខ្ញុំមិនដឹងជាកើតពីពេលណាទេ ពីព្រោះខ្ញុំទៅឃើញអ៊ីចឹង ។ ហើយ ពេលដែលមន្ទីរសន្តិសុខនេះ អស់សកម្មភាព គឺនៅពេលរំដោះភ្នំពេញហើយ ។

**ស៖** អ៊ីចឹងពេលដែល ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលលោកបាននិយាយថា លោក មកធ្វើការនៅភ្នំពេញ ហើយនៅមន្ទីរសន្តិសុខស-២១ ហើយរហូតដល់ថ្ងៃរំដោះ៧មករា ឆ្នាំ៧៩ ថាតើ លោកនៅក្នុងមន្ទីរនោះធ្វើអ្វី? ហើយមានមុខងារធ្វើអ្វី ហើយក្នុងមុខងារនោះ លោកមានភារកិច្ចធ្វើអ្វីខ្លះ? ហើយអ្នកណាជាអ្នកជ្រើសរើសលោកមកធ្វើការនៅក្នុងមន្ទីរសន្តិសុខស-២១ ?

**ឆ៖** ខ្ញុំមកធ្វើការនៅស-២១ នេះ គឺជាមួយគ្នានឹង មិត្តឌុច ធ្លាប់នៃធ្វើការសន្តិសុខនៅអមលាំង ហើយខ្ញុំមានភារកិច្ចជាអ្នកសួរចម្លើយ អ្នកដែលជាប់ចោទ អ្នកដែលមិនសំខាន់ ។ សូមលោក ប្រធានជ្រាប ។

[០៩:៤៤:៥៣]

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ ។ អញ្ជើញលោកចៅក្រម ធូ មណី ។

**សួរដោយចៅក្រម ធូ មណី៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក ម៉ម ណៃ លោកបានឆ្លើយបញ្ជាក់ប្រាប់លោកប្រធានអម្បាញ់មិញថា លោកបានចូលព្រៃដើម្បីធ្វើបដិវត្តន៍នោះ ។ តើលោកចូលព្រៃហ្នឹងនៅក្នុងឆ្នាំណា?

**ឆ៖** ខ្ញុំចូលព្រៃនៅឆ្នាំ៧៣ ។

**ស៖** នៅមុនឆ្នាំ៧៣ លោកបានអះអាងទៀតថា បានធ្លាប់បានត្រូវបានរដ្ឋការសម្តេច សីហនុចាប់ដាក់ពន្ធនាគារម្តង តើគេចាប់លោកហ្នឹងពីរឿងអីដែរ?

**ឆ៖** កាលសម័យមុន៧០ហ្នឹង គឺថាក្នុងពេលដែលស្តេច សីហនុ កាន់កាប់រដ្ឋអំណាចនោះ គឺថាគេចាប់ខ្ញុំដាក់គុកដោយចោទថា ខ្ញុំជាខ្មែរក្រហម ជាអ្នកធ្វើបដិវត្តន៍ ។

**ស៖** លោកធ្លាប់បានចូលធ្វើជាអ្នកបដិវត្តន៍អ៊ីចឹងមែនទេ បានជាគេចាប់ខ្លួន?

**ឆ៖** កាលនោះ គឺខ្ញុំធ្វើបដិវត្តន៍ ពីព្រោះកាលនៅរៀន ខ្ញុំរៀនប្រវត្តិសាស្ត្របដិវត្តន៍នៅសូវៀត និងបដិវត្តន៍ស្រុកចិន ។ ដូច្នេះ ខ្ញុំស្រលាញ់កុម្មុយនីស្ត ។

**ស៖** អ៊ីចឹងមានន័យថា លោកធ្លាប់បានសិក្សាអំពីលិទ្ធិកុម្មុយនីស្តនៅអតីតសហភាពសូវៀត ក៏ដូចជានៅប្រទេសចិន បានជាលោករត់ចូលព្រៃ ធ្វើបដិវត្តន៍ ហើយអម្បាញ់មិញនេះ លោកក៏បានឆ្លើយបញ្ជាក់ដែរថា លោករត់ចូលព្រៃក្រោយឆ្នាំ៧៣នេះ គឺរត់ចូលទៅនៅភូមិក្រាំងក្តិបហ្នឹង លោកបានរៀនវគ្គនយោបាយ តើវគ្គនយោបាយហ្នឹង គេបណ្តុះបណ្តាលពីអីខ្លះទៅ?

**ឆ៖** ក្នុងវគ្គនយោបាយនោះ គេបានបង្រៀនពីទស្សនៈសភាពការណ៍កម្ពុជា ហើយនិងនិយាយអំពីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យតែប៉ុណ្ណឹង ។

[០៩:៤៨:៣៤]

**ស៖** បានអះអាងទៀតថា ក្រោយពីបានជួប ឌុច នៅក្នុងការដែលលោករត់ចូលព្រៃហ្នឹង ឌុច បានស្នើសុំលោកឲ្យទៅធ្វើការជាមួយនៅអមលាំង ផ្នែកសន្តិសុខ ។ តើជំនាន់នោះផ្នែកសន្តិសុខមានន័យយ៉ាងម៉េចទៅ?

**ឆ៖** ជំនាន់នោះ គឺថា វាមិនខុសអីពីក្រិត្យក្រមទូទៅ គឺថា សួរចម្លើយអ្នកទោសតែប៉ុណ្ណឹង ។

**ស៖** ផ្នែកសន្តិសុខ បានន័យថា ក្នុងការសួរចម្លើយអ្នកទោស។ អ៊ីចឹងថា តើអ្នកទោសដែលមន្ទីរសុខនៅអមលាំងហ្នឹងចាប់យកមកហ្នឹង ជាប្រភេទអ្នកទោសយ៉ាងដូចម្ដេចដែរ?

**ឆ៖** សន្តិសុខនៅអមលាំង សូមជម្រាបលោក គ្មានសិទ្ធិដើរចាប់ចងគេទេ គឺមូលដ្ឋានគេ ឬអង្គភាព គេចាប់មនុស្សបញ្ជូនមកឱ្យសួរ ។ ហើយភាគច្រើន ច្រើនគេរាយការណ៍ពីមូលដ្ឋានមក ពីអង្គភាពមក គេថាពួកហ្នឹងប្រឆាំងបដិវត្តន៍ ។ នេះសូមលោកជ្រាប ។

**ស៖** សូមអរគុណ ។ ហើយជាមូលដ្ឋានជាអ្នកចាប់មក ដោយថាប្រឆាំងបដិវត្តន៍ តើសកម្មភាពបែបណាទៅ ដែលអាចបែងចែកថាជាអ្នកប្រឆាំងបដិវត្តន៍ជំនាន់នោះ?

**ឆ៖** ពេលដែលមូលដ្ឋានចាប់មកឱ្យថាប្រឆាំងបដិវត្តន៍នោះ គឺថាមិនដឹងមូលដ្ឋាន គេសង្កេតឃើញបែបម៉េចទេ ។ ក៏ប៉ុន្តែ មកដល់ពេលសួរចម្លើយឃើញថា និយាយបំផុសបំផុល កុំឱ្យចូលបដិវត្តន៍ ឱ្យស្អប់បដិវត្តន៍ ឱ្យអីតែប៉ុណ្ណឹង ។

**ស៖** អ៊ីចឹងអ្នកទោស អ្នកដែលគេចាប់ខ្លួនយកមក បញ្ជូនយកមកឱ្យមន្ទីរសន្តិសុខនៅអមលាំងហ្នឹង ជាអ្នកដែលមាននិន្នាការប្រឆាំងបដិវត្តន៍ ។ អ៊ីចឹងជាប្រភេទមនុស្សដែលនៅក្នុងជួរបដិវត្តន៍ ឬក៏សម័យនោះ វាអាចជាពួកទាហាន លន់ នល់ ឬក៏គិញ?

**ឆ៖** បញ្ហានេះ ខ្ញុំក្ដាប់មិនបានដែរ ក៏ប៉ុន្តែតាមសង្កេតជាទូទៅគឺថា មានពួកអ្នកនៅក្នុងជួរបដិវត្តន៍ខ្លះ ហើយមានជួរប្រជាជនខ្លះ ។ ឯជួរគិញ ឬជួរទាហាន ខ្ញុំមិនដែលឃើញទេ ប៉ុន្តែជួរគិញ ខ្ញុំមិនដឹងទេ មិនដឹងថាអ្នកណាគិញអ្នកណាអីទេ ពីព្រោះខ្ញុំសួរចម្លើយតែអ្នកដែលប្រឆាំងនឹងបក្ស ហើយទៅឃើញតែអ្នកបំផុសបំផុល អ្នកដែលស្អប់បដិវត្តន៍ប៉ុណ្ណឹង ។

**ស៖** តើមន្ទីរសន្តិសុខនៅអមលាំងនោះ មានអ្នកណាជាអ្នកប្រធាន និយាយឱ្យចំអ្នកណាជាអ្នកគ្រប់គ្រងនៅទីនោះ?

**ឆ៖** អ្នកគ្រប់គ្រងនៅទីនោះ គឺ មិត្តឌុច ។

**ស៖** អ៊ីចឹង តើមានខាងណាទៀតដែរ ដែលថាគ្រប់គ្រងពីលើលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះទៀត?

**ឆ៖** បញ្ហានេះ ខ្ញុំមិនច្បាស់ដែរ ។

**ស៖** លោកបានអះអាងថា លោកនៅក្នុងនោះគឺជាចូលដំបូង គឺមិនទាន់បានចែកការងារធ្វើអីទេ ប៉ុន្តែក្រោយមក លោកបានចូលទៅមើល គេសួរចម្លើយ ហើយក្រោយមកទើបគេប្រគល់ការងារសួរ

ចម្លើយនេះទៅឲ្យមកលោក ដោយសួរចម្លើយអ្នកមិនសំខាន់ ។ អ៊ីចឹងតើលោកអាចរៀបរាប់ប្រាប់យើងបានទេថា អំពីរបៀបសួរចម្លើយដែលគេប្រើប្រាប់នៅមន្ទីរសន្តិសុខអមលាំងនោះ?

**ឆ៖** ការសួរសម្លើយដែលប្រព្រឹត្តទៅនៅមន្ទីរអមលាំង គឺការធ្វើប្រវត្តិរូបហើយនិងប្រវត្តិសកម្មភាព ។

**ស៖** ចុះវិធី ដូចជាការសួរ ឬក៏បើគេមិនព្រមសួរយើងត្រូវធ្វើម៉េចៗ យ៉ាងម៉េច វាមានរបៀបរបបគេសួរយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំកន្លងមកគឺថា ការសួរជាប្រវត្តិរូបពុំមានអីសំខាន់ទេ គឺថាអ្នកដែលត្រូវជាប់ចោទនិយាយបាន ហើយការធ្វើប្រវត្តិសកម្មភាព យើងឲ្យគេនិយាយអំពីសកម្មភាពរបស់គេកន្លងមក គេធ្វើអីខ្លះ ។ ហើយក៏បើគេមិននិយាយទេ យើងគ្រាន់តែឈ្លេចសួរដេញដោលពីនេះទៅនេះ ពីនោះទៅនោះទៅរហូតដល់គេរាយរាប់ពីសកម្មភាពរបស់គេអស់ ។

**ស៖** នេះជាបទពិសោធន៍លោក ដែលលោកសួរចម្លើយផ្ទាល់ ប៉ុន្តែមានអ្នកដទៃសួរចម្លើយ តើគេនិយាយឲ្យចំទៅថាតើគេមានប្រើវិធីធ្វើទារុណកម្ម ដើម្បីឲ្យអ្នកទោសឆ្លើយចម្លើយសារភាពនោះ គេមានវិធីយ៉ាងម៉េចខ្លះ ក្រៅពីលោកណ៎ា?

**ឆ៖** ខ្ញុំក្តាប់មិនបានដែរបញ្ហាហ្នឹង ។

**ស៖** លោកថាក្តាប់មិនបានទេ ប៉ុន្តែលោកអាចសន្និដ្ឋានបានទេ ថានៅមន្ទីរសន្តិសុខអមលាំងហ្នឹងមានការធ្វើទារុណកម្មលើអ្នកទោស?

**ឆ៖** តាមខ្ញុំសន្និដ្ឋានជាទូទៅ គឺថាអាចមាន ឬអាចមិនមាន ។

**ស៖** អ៊ីចឹងលោកប្រហែលជាមិនច្បាស់ អំពីការធ្វើទារុណកម្មនេះទេ ។ អ៊ីចឹង តើក្រោយពីសួរបានចម្លើយហើយ តើចម្លើយនោះត្រូវបញ្ជូនទៅឲ្យអ្នកណា?

**ឆ៖** ការសួរចម្លើយហើយ គឺអ្នកសួរហ្នឹង ធ្វើសេចក្តីកត់ត្រាតាមអ្នកដែលទទួលរងគ្រោះឆ្លើយហើយសង្ខេបជូនទៅ មិត្តឌុច ។

**ស៖** តើលោកដឹងទេ ក្រោយពីបានទទួលចម្លើយពីអ្នកសួរចម្លើយហើយ ហើយ ឌុច បានអានហើយ តើលោកអាចដឹងទេថាតើ ឌុច បញ្ជូនចម្លើយនេះទៅឲ្យអ្នកណាទៀត?

**ឆ៖** ខ្ញុំមិនដឹងថា គាត់បញ្ជូនទៅឲ្យឈ្មោះណាទេ ប៉ុន្តែគ្រាន់តែដឹងថាគាត់បញ្ជូនចម្លើយទៅលើ។

**ស៖** ខាងលើនោះៗ ជាអ្នកណាទៅ?

**ឆ៖** លើហ្នឹងបើតាមខ្ញុំយល់មិនដឹងជាតំបន់មិនដឹង គឺភូមិភាគមិនដឹង ។

**ស៖** ក្រោយពីបានសួរចម្លើយរួច តើអ្នកដែលត្រូវគេចាប់ឃុំខ្លួននោះគេយកទៅណា? គេលែងឱ្យមានសេរីភាពឡើងវិញ ឬក៏យកទៅសម្លាប់?

[០៩:៥៩:២៥]

**ឆ៖** បញ្ហានេះក៏ខ្ញុំមិនដឹងដែរ គ្រាន់តែថា សួរចម្លើយហើយគេយកអ្នកទោសនោះទៅទុកកន្លែងដដែលទៅ ពីព្រោះខ្ញុំមិនបានជិតស្និទ្ធជាមួយនិងអ្នកទោសអស់ទាំងនោះទេ ។

**ស៖** តើលោកអាចចាំបានទេក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គឺថាបានកងទ័ពរំដោះហ្នឹង បានវាយយកទីក្រុងភ្នំពេញបានហើយ បានបង្កើតឡើងនូវមន្ទីរស-២១នេះ តើលោកអាចបញ្ជាក់បានទេ តើមន្ទីរស-២១នេះ បង្កើតឡើងជាក់លាក់នៅអំឡុងពេលណាដែរ?

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ជូនលោកចៅក្រមបានទេ គឺថាគ្រាន់តែដឹងថា ក្រោយ១៧ មេសា ៧៥ ហ្នឹងគឺថាមានមន្ទីរសន្តិសុខ ។ ហើយពេលនោះខ្ញុំក៏មិនដឹងថា ឈ្មោះអីដែរ តែក្រោយមកទៀតទើបដឹងថា ស-២១ ។

**ស៖** អ៊ីចឹងលោកមកពីអមលាំង មកធ្វើការនៅស-២១នេះ ពេលណាដែរ?

**ឆ៖** ខ្ញុំមកពីអមលាំងមក មកជាមួយនឹង មិត្តឌុច ហើយនិងកម្មាភិបាលដទៃទៀត យើងមកធ្វើការនៅកន្លែង *ប៉េអេស* ។

**ស៖** នៅពេលណាទៅដែលលោកមកពីអមលាំង មកធ្វើការនៅ *ប៉េអេស* ហ្នឹង?

**ឆ៖** ក្រោយថ្ងៃរំដោះ១៧ មេសា ហ្នឹងប្រហែលខ្ញុំមិនច្បាស់ជាប៉ុន្មានទេ គឺតាមខ្ញុំប៉ាន់ប្រហែលជាមួយខែ ឬអីប៉ុណ្ណឹង ។

**ស៖** តើពេលនោះអ្នកណាជាអ្នកគ្រប់គ្រងមន្ទីរស-២១ នេះ?

**ឆ៖** សុំជម្រាបលោកចៅក្រម តើលោកសួរខ្ញុំក្រោយដែលប្រកាសស-២១ ហើយគឺឬក៏ក្រោយដែលខ្ញុំមកពីអមលាំងភ្លាម?

**ស៖** បន្ទាប់ពីលោកមកពីអមលាំងភ្លាមៗហ្នឹង តើអ្នកណាជាអ្នកគ្រប់គ្រងមន្ទីរស-២១នេះ?

**ឆ៖** ក្រោយពីមកពីអមលាំងភ្លាម គឺដូចខ្ញុំបានជម្រាបលោកថា ខ្ញុំមិនដឹងថា តើគេបង្កើតស-២១ ហើយនៅទេ ។ តែដល់ពេលបង្កើតស-២១ គឺខ្ញុំដឹងថា នែ៎! ណាត ជាអ្នកគ្រប់គ្រង ។

**ស៖** អ៊ីចឹងបានន័យថា ដំបូងឡើង ណាត ជាអ្នកគ្រប់គ្រង ហើយតើលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះ តើគាត់ឡើងគ្រប់គ្រង ស-២១ នៅថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោក គឺថាចំពោះថ្ងៃខែខ្ញុំមិនចាំទេ គ្រាន់តែដឹងជាសភាពការណ៍ ឬព្រឹត្តិការណ៍ក្រោយពី ណាត ចេញទៅគឺថា មិត្តឌុច ឡើងគ្រប់គ្រង ។

[១០:០៣:៥០]

**ស៖** តើលោកអាចរៀបរាប់អំពីរចនាសម្ព័ន្ធរបស់ស-២១ តើស-២១ហ្នឹងមានអង្គភាពអីខ្លះទៅ? ហើយអង្គភាពនីមួយៗមានតួនាទីអ្វីខ្លះ?

**ឆ៖** បញ្ហាអង្គភាពនៅស-២១ ខ្ញុំក្តាប់មិនបានច្បាស់លាស់ទេ ពីព្រោះខ្ញុំគ្មានតួនាទីអីសំខាន់ ។ ខ្ញុំគ្រាន់តែដឹងថា មានផ្នែកនៅស្រែ ផ្នែកការពារ ហើយនិងផ្នែកសួរចម្លើយប៉ុណ្ណឹងទេ ។

**ស៖** ភារកិច្ចរបស់ផ្នែកនីមួយៗហ្នឹង ផ្នែកនៅស្រែនោះគេធ្វើអី? ផ្នែកការពារនោះគេធ្វើអី? ហើយផ្នែកសួរចម្លើយនោះគេធ្វើអីខ្លះ?

**ឆ៖** ជម្រាបប្រសាសន៍លោក! តាមខ្ញុំយល់ផ្នែកធ្វើស្រែ គឺធ្វើស្រែ ផ្នែកការពារហ្នឹង គឺគេការពារអ្នកដែលជាប់ចោទហ្នឹង ហើយផ្នែកសួរចម្លើយ គឺគេសួរចម្លើយហ្នឹង ។ ហ្នឹងខ្ញុំយល់អ៊ីចឹង ។ ឯការចាត់ចែងល្អិតខ្ញុំមិនដឹងទេ ។

**ស៖** ចុះបរិវេណនៃស-២១ លោកអាចដឹងដែរថា ស-២១ គ្រប់គ្រងតំបន់ណាខ្លះ?

**ឆ៖** បញ្ហានេះក៏ខ្ញុំអត់ដឹងដែរ ។

**ស៖** អ៊ីចឹងលោកបានឆ្លើយរួចមកហើយ ថានៅអមលាំងនោះលោកមានតួនាទីជាអ្នកសួរចម្លើយ ហើយចុះនៅ ស-២១ លោកមានតួនាទីជាអ្វីដែរ?

**ឆ៖** នៅស-២១ ជាដំបូងខ្ញុំ មិត្តឌុច ប្រើខ្ញុំឲ្យទាក់ទងទៅតំបន់៣១ សុំកុមារពីតំបន់៣១ ហើយសុំគោសុំក្របីគេយកមកដើម្បីឲ្យធ្វើស្រែ ហើយនិងដឹកខោអាវចាស់ៗនេះ ហើយនិងន៎! ស័ង្កសីអីយកទៅឲ្យតំបន់៣១ ចែកទៅឲ្យខាងសហករណ៍ ហ្នឹងដំបូង ។ ក្រោយមកបានសួរចម្លើយអ្នកទោសមិនសំខាន់ដែរ ។

**ស៖** តើក្រុមសួរចម្លើយរបស់លោកហ្នឹងមានគ្នាប៉ុន្មាននាក់ទៅ?

**ឆ៖** បញ្ហានេះខ្ញុំក្តាប់មិនបានទេ ពីព្រោះថាខ្ញុំសួរចម្លើយតែម្នាក់ឯង ឯអ្នកដទៃទៀតគេសួរ ហើយក៏ខ្ញុំមិនដឹងថាមានចំនួនប៉ុន្មាននាក់ដែរ ។

**ស៖** អ៊ីចឹង លោកអាចដឹងទេថាអ្នកដែល មនុស្សដែលគេចាប់ខ្លួនយកមកមន្ទីរ ស-២១ នេះជាមនុស្សដែលគេនាំយកមកពីខាងណាដែរ?

**ឆ៖** សុំជម្រាបលោក ខ្ញុំអត់ដឹងគេបញ្ជូនមកពីខាងណាទេ ។

**ស៖** យើងសង្កេតឃើញថា លោកហើយនិង ឌុច សុទ្ធតែអ្នកដែលមកពីអមលាំង ។ អ៊ីចឹង តើបុគ្គលិកមន្ទីរសន្តិសុខអមលាំង ត្រូវបានបញ្ជូនមកឲ្យធ្វើការនៅមន្ទីរស-២១ទាំងអស់ ឬក៏យ៉ាងម៉េច?

[១០:០៩:១០]

**ឆ៖** តាមខ្ញុំដឹង គឺមកទាំងអស់គ្នានៅស-២១ទាំងអស់គ្នា ក៏ប៉ុន្តែមិនដឹងថាជាអ្នកខ្លះគេនៅឯណាហើយគេធ្វើអីនៅត្រង់ណាខ្ញុំក្តាប់មិនបានដែរ ។

**ស៖** តើបុគ្គលិកសរុបរបស់មន្ទីរស-២១ មានប្រហែលប៉ុន្មាននាក់ទៅ?

**ឆ៖** សុំជម្រាបប្រសាសន៍លោក! ខ្ញុំមាននាទីគ្រាន់តែអ្នកសួរចម្លើយ ដូច្នេះខ្ញុំគ្មាននាទីអីទៅដឹងចំនួនបុគ្គលិកនៅស-២១ ប៉ុន្មាននាក់ទេ ។

**ស៖** ទាក់ទងទៅនឹងការនៅបំពេញការងារលោកនៅមន្ទីរស-២១ តើគេធ្លាប់ដែលមានបង្រៀនវគ្គនយោបាយផ្សេងៗដល់លោកដែរ?

**ឆ៖** ការបង្រៀននយោបាយគឺ វាជាការបង្រៀនប្រចាំឆ្នាំ ឬប្រចាំខែមាន ។

**ស៖** តើខ្លឹមសារនៃការបង្រៀននយោបាយនោះគេបង្រៀនពីអ្វីខ្លះទៅ?

**ឆ៖** គេបង្រៀនទស្សនៈសភាពការណ៍ ហើយមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍ និងមាគ៌ាចាត់តាំង ។

**ស៖** តើលោកអាចរៀបរាប់ អំពីមាគ៌ានីមួយៗដែលគេបានបង្រៀននោះដែរ មាគ៌ានយោបាយយ៉ាងម៉េច? មាគ៌ាចាត់តាំងយ៉ាងម៉េច?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! គឺខ្ញុំគ្រាន់តែចាំខ្លះៗ ខ្ញុំមិនអាចចាំល្អិតល្អន់បានទេ ពីព្រោះសភាពការណ៍នយោបាយ ពេលនោះគេគ្រាន់តែបង្រៀនអំពីបដិវត្តន៍សង្គមនិយម ។ ហើយមាគ៌ាសតិ-អារម្មណ៍ គឺថាខំកសាងខ្លួនទៅតាមមាគ៌ានយោបាយហ្នឹងទៅ ហើយមាគ៌ាចាត់តាំងគឺថាគ្រាន់តែថ្នាក់ក្រោមគោរពថ្នាក់លើ ។

**ស៖** មាគ៌ានយោបាយសង្គមនិយមនោះគឺ តើឈរមើលលើមូលដ្ឋានអីខ្លះទៅ? គេមានដែលបង្រៀនដែរ?

**ឆ៖** បញ្ហានេះខ្ញុំភ្លេចអស់ហើយ ។

**ស៖** ចុះប្រភេទលោកបានអះអាងថាលោកសួរចម្លើយ ហើយសួរនោះតែម្នាក់ឯងទេ លោកប្រហែលជាមិនអាចដឹងទេថា អ្នកផ្សេងសួរយ៉ាងម៉េចៗ ។ ប៉ុន្តែ ប្រភេទអ្នកទោសដែលលោកធ្លាប់បានទទួលសួរចម្លើយកន្លងមកហ្នឹង លោកសម្គាល់ឃើញថា អ្នកទោសនោះជាអ្នកទោសយ៉ាងម៉េច?

**ឆ៖** ខ្ញុំបញ្ហានេះខ្ញុំពិបាកជម្រាបលោកណាស់ គឺថាខ្ញុំច្រើនតែសួរយុទ្ធជន ឬកម្មាភិបាលក្រុមអីកម្របានសួរដល់កម្មាភិបាលអនុសេនាតូចណាស់ ។ ហើយពួកហ្នឹងគេ តាមគេប្រាប់មកគេថា ខ្សែក្បត់ប៉ុណ្ណឹង ។

[១០:១៥:០៩]

**ស៖** លោកអះអាងថា លោកសួរចម្លើយគ្រាន់តែអ្នកតូចតាច មិនមែនជាកម្មាភិបាលថ្នាក់ធំអីទេ អ៊ីចឹងបានន័យថា អ្នកដែលត្រូវបានគេចាប់ខ្លួនប្រគល់មកឲ្យមន្ទីរស-២១ ជាមនុស្សនៅក្នុងជួរបដិវត្តន៍អ៊ីចឹងដែរ?

**ឆ៖** មនុស្សដែលគេចាប់មកគឺថា គឺជាមនុស្សនៅក្នុងជួរបដិវត្តន៍ ហើយជាពិសេសច្រើនឃើញជួរកងទ័ព ។

**ស៖** ក្រៅពីអ្នកទោសដែលមាននៅក្នុងជួរបដិវត្តន៍ ជាពិសេសនៅជួរកងទ័ព ។ តើលោកអាចសម្គាល់ឃើញថាមានអ្នកទោសប្រភេទផ្សេងទៀតដែរ?

**ឆ៖** ចំពោះបញ្ហានេះខ្ញុំក៏ក្តាប់មិនបានដែរ ។

**ស៖** នៅមន្ទីរស-២១ហ្នឹង តើមានអ្នកទោសជាជនបរទេសដែរ? គឺជនបរទេសនោះគឺសំដៅទៅលើជនជាតិបស្ចិមប្រទេស តើមានដែរ?

**ឆ៖** បញ្ហានេះកាន់តែខ្ញុំក្តាប់មិនបានទៅទៀត ពីព្រោះថាគ្មានសិទ្ធិអីដើរហើរនឹងដឹង ហើយនិងដឹងរឿងអ្នកដទៃ ។ ជាគោលការណ៍ ការងារគេ គេដឹង ការងារយើង យើងដឹង ។

**ស៖** ចុះមានមន្ទីរស-២១ មានធ្លាប់ដែលបានទទួលអ្នកទោសដែលជាជនស៊ីវិល ឬក៏ទាហានវៀតណាមដែរឬទេ?

**ឆ៖** ចំពោះបញ្ហានេះគឺថា ចំពោះវៀតណាម ទាហានវៀតណាមអាហ្នឹងគឺថាមាន ។ ហេតុម៉េចបានជាខ្ញុំថាមាន ពីព្រោះមិត្តឌុច ចាត់តាំងឲ្យខ្ញុំសួរចម្លើយវៀតណាម ។

**ស៖** វៀតណាមដែលលោកសួរចម្លើយនោះជាជនស៊ីវិល ឬក៏ជាទាហាន?

**ឆ៖** ខ្ញុំប្រទះ ទាហាន ។

**ស៖** តើលោកអាចដឹងចំនួនច្បាស់លាស់ទេថា ជនស៊ីវិល និងទាហានវៀតណាមដែលត្រូវចាប់មកមន្ទីរស-២១ ហ្នឹងមានចំនួនប្រហែលប៉ុន្មានទៅ?

**ឆ៖** ចំពោះបញ្ហានេះ ខ្ញុំក្តាប់មិនបានដែរ ពីព្រោះខ្ញុំដឹងតែពីរឿងគេយកមកឲ្យខ្ញុំសួរ ខ្ញុំសួរទៅ ។ សួរចប់គេយកទៅវិញទៅ ។ នេះខ្ញុំដឹងតែប៉ុណ្ណឹង ។

**ស៖** ចុះខ្លួនលោកផ្ទាល់វិញ តើលោកធ្លាប់បានសួរចម្លើយអ្នកទោស ដែលជាជនជាតិវៀតណាមនោះប៉ុន្មាននាក់ដែរ?

[១០:១៨:០៣]

**ឆ៖** ខ្ញុំក្តាប់មិនបានទេ ។ ចាំក៏វាមិនបាន ប្រហែលវាបួនដប់ម្ភៃនាក់ប៉ុណ្ណឹង ។

**ស៖** ក្នុងការចាប់អ្នកទោសយកមកចូលក្នុងមន្ទីរស-២១ តើប្រតិបត្តិការនៃការចាប់នេះ គេប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ? លោកមានដឹងដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ខ្ញុំអត់ដឹងទេ ។

**ស៖** ចុះអំពីការឃុំខ្លួនអ្នកទោសវិញ តើគេឃុំខ្លួនរបៀបយ៉ាងដូចម្តេចដែរ?

**ឆ៖** បញ្ហានេះខ្ញុំក៏អត់ដឹងដែរ ពីព្រោះខ្ញុំគ្មានសិទ្ធិចូលទៅកន្លែងឃុំឃាំងនុ៎ងទេ ។

**ស៖** អ៊ីចឹងចំពោះអ្នកទោសដែលលោកសួរចម្លើយនោះ តើគេនាំមកយ៉ាងដូចម្តេច? លោកទៅនាំមកពីក្នុងកន្លែងឃុំឃាំង ឬក៏គេប្រគល់ឲ្យលោកយ៉ាងម៉េច?

**ឆ៖** កន្លងមកខ្ញុំមិនដែលទៅយកអ្នកទោសពីកន្លែងឃុំឃាំងទេ ច្រើនតែគេយកមកឲ្យ ហើយគេនៅចាំការពារអ្នកទោសដែលខ្ញុំសួរចម្លើយនោះ ។

**ស៖** អ៊ីចឹងលោកមិនដែលនាំអ្នកទោសមកខ្លួនឯងទេ គេនាំយកមកឲ្យលោក មកដល់កន្លែងសួរចម្លើយតែម្តង តើអ៊ីចឹងមែនទេ?

**ឆ៖** គឺគេនាំមកឲ្យខ្ញុំសួរតែម្តង ។

**ស៖** អ៊ីចឹងអំពីរបៀបសួរចម្លើយវិញ តើនៅពេលដែលគេនាំអ្នកទោសយកមកឲ្យលោកសួរនោះ តើលោកត្រូវចាប់ផ្តើមរបៀបម៉េច?

**ឆ៖** គេនាំមកដល់ គេដាក់ខ្នោះជើងគេដាក់អីហើយ គេស្រាយដៃស្រាយអីទៅ ហើយខ្ញុំចាប់ផ្តើមសួរ តែមុននឹងខ្ញុំសួរគឺខ្ញុំត្រូវ គេហៅថាធ្វើនយោបាយណែនាំពន្យល់គេឲ្យគេយល់ឲ្យគេសុខចិត្តសារភាព

ឲ្យយើង ។ រួចហើយក៏ខ្ញុំសួរពីប្រវត្តិរូប ។ ប្រវត្តិរូបរួចហើយក៏ឲ្យគេនិយាយ អំពីប្រវត្តិសកម្មភាពរបស់គេ ។

**ស៖** អ៊ីចឹងលោកបានណែនាំហើយឲ្យគេនិយាយពីប្រវត្តិរូប ឬក៏ប្រវត្តិសកម្មភាព ។ ចុះបើគេឆ្លើយ តើចម្លើយហ្នឹងលោកកត់ត្រាដោយខ្លួនឯង ឬក៏យ៉ាងម៉េច? ឲ្យអ្នកទោសសរសេរ ជាអ្នកសរសេរ?

**ឆ៖** ចម្លើយហ្នឹង គឺកត់ត្រាអ្នកសួរ គឺខ្លួនខ្ញុំកត់ត្រាអ្នកទោស-- ចម្លើយអ្នកទោស ។

**ស៖** លោករៀបរាប់ហើយថា ចូលមកដល់លោកបានធ្វើសតិអារម្មណ៍គេឲ្យឆ្លើយ ហើយបើគេឆ្លើយលោកជាអ្នក-- គេជាអ្នកឆ្លើយលោកជាអ្នកកត់ ។ ចុះចំពោះអ្នកដែលមិនព្រមឆ្លើយវិញ តើលោកធ្វើយ៉ាងម៉េច?

[១០:២២:៥៧]

**ឆ៖** ចំពោះខ្ញុំ កាលដែលសួរធ្វើប្រវត្តិរូប និងប្រវត្តិសកម្មភាព វាមិនមានអីពិបាកទេ ។ ហើយប្រវត្តិសកម្មភាព សួរថាតើទាក់ទងឧទាហរណ៍ថា ទាក់ទងជាមួយអ្នកណាដែលគេមានឋានៈខ្ពស់ជាងថាជាអ្នកក្បត់នោះ យើងមានសកម្មភាពយ៉ាងម៉េចជាមួយនឹងគេ? អីគេ? ហើយប្រសិនថា ឥឡូវគេមិនព្រមឆ្លើយៗ យើងពន្យល់គេតទៅទៀត នេះម៉្យាង ។ ម៉្យាងទៀត ខ្ញុំតែងតែឲ្យគេយកទៅទុកសិនទៅ ហើយឲ្យគេគិតទៅ ឲ្យគេគិត ដើម្បីរៀបរាប់អំពីការគេប្រព្រឹត្តត្រូវ ឬប្រព្រឹត្តខុសរបស់គេកន្លងមកជាមួយនឹងមនុស្សដែលនៅខាងលើរបស់ខ្លួននោះ ។

**ស៖** ចុះនៅអំឡុងពេលដែលគេមិនព្រមឆ្លើយ លោកថាយកទៅឲ្យគេគិត ។ ចុះក្នុងរយៈពេលប៉ុន្មានទៅដែលលោកត្រូវយកត្រលប់សួរជាថ្មីឡើងវិញនោះ?

**ឆ៖** រយៈពេលយូរដែរ ពីរបីថ្ងៃ ។

**ស៖** ចុះតើលោកត្រូវធ្វើដូចម្ដេចទៀត បើសិនជាឲ្យគេទៅពីរបីថ្ងៃហើយ ហើយឲ្យត្រឡប់មកវិញគេនៅតែមិនឆ្លើយ?

**ឆ៖** បើគេមិនឆ្លើយ គឺខ្ញុំពិនិត្យមើលសាច់រឿងពីដើម ប្រវត្តិរូបនិងប្រវត្តិសកម្មភាពរបស់គេ ហើយបើខ្ញុំពិនិត្យហើយ ខ្ញុំវិភាគថា គេអត់មានអីឆ្លើយទេ គឺខ្ញុំធ្វើចម្លើយនឹងទៅ មិត្តឌុច ទៅ ។

**ស៖** អ៊ីចឹងថា តើមានការណែនាំនៅពេលដែលលោកផ្ញើចម្លើយទៅឲ្យលោក កាំង ហ្គេកអ៊ាវ ហៅ ឌុចហើយ ។ ហើយតើមានការណែនាំពីលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ មកវិញទេ? ថាតើបន្តការសួរយ៉ាងម៉េច? សួរអំពីអីៗទៀត? តើមាន ធ្លាប់មានអ៊ីចឹងដែរ?

ឆ៖ ចំពោះបញ្ហានេះ ខ្ញុំសូមជម្រាបលោកថា ខ្ញុំភ្លេចអស់ហើយ ខ្ញុំមិនបានចាំទេ ។

ស៖ ចុះអំពីរបៀបសរសេរចម្លើយសារភាពនោះ ។ តើគេមានបង្រៀនអំពីរបៀបសរសេរនេះទេ ? របៀបសរសេរនេះ ប្រើជាទូទៅនៅក្នុងមន្ទីរស-២១ ឬក៏សរសេរនេះទៅតាមអ្នកសួរចម្លើយម្នាក់ៗយល់ឃើញ?

ឆ៖ តាមខ្ញុំយល់ ប្រហែលជាគេសរសេរទៅតាមគេម្នាក់ៗគេយល់ ។ ក៏ប៉ុន្តែ ជាគម្រោងទូទៅគឺថាប្រវត្តិរូប ប្រវត្តិសកម្មភាព ។

ស៖ អ៊ីចឹង គេមានដែលបង្រៀនអំពីរបៀបសរសេរ ឬក៏វិធីសាស្ត្រក្នុងការសួរចម្លើយហ្នឹង ដល់បុគ្គលិកមន្ទីរស-២១ ដែរ?

ឆ៖ ចំពោះរឿងនេះ គឺខ្ញុំក៏ភ្លេចមិនដែរ ។ ក៏ប៉ុន្តែគ្រាន់តែដឹងថា ជាទូទៅគឺគេត្រូវតែនិយាយអំពីប្រវត្តិរូប ប្រវត្តិសកម្មភាពប៉ុណ្ណឹង ។

ស៖ នៅក្នុងបុគ្គលិករបស់មន្ទីរស-២១ ហ្នឹង គេដែលមានប្រជុំដែរ? ប្រជុំប្រចាំខែ? ប្រជុំប្រចាំសប្តាហ៍អីដែរ?

ឆ៖ ក្នុងការប្រជុំគឺគេប្រជុំតែធ្វើជីវភាពទេ ឯប្រជុំជាការងារសួរចម្លើយយ៉ាងម៉េច? អីយ៉ាងម៉េច? ជាមួយពួកក្រុមសួរចម្លើយគឺមិនដែលបានជុំគ្នាទេ ។

ស៖ ប្រជុំជីវភាពនុ៎ង ប្រជុំយ៉ាងម៉េចទៅ?

ឆ៖ ប្រជុំជីវភាពនេះ ទៅតាមជាន់ តាមថ្នាក់ ។ អ្នកណាជាមហាជនធម្មតា អាហ្នឹងគេមានពួកគេទៅ ។ អ្នកណាជាមហាជនចម្រើន គេមានពួកគេទៅ ។ អ្នកណាជាសម្ព័ន្ធយុវកក គេមានពួកគេទៅ ។ អ្នកណាជាបក្ខជន អាហ្នឹងគឺពួកគេបក្ខជនហ្នឹងទៅ គេប្រជុំដូច្នេះ ។ ហើយក្នុងការប្រជុំជីវភាពគឺពាក់ព័ន្ធអំពីការត្រូវនិងខុស គឺការរកគុណសម្បត្តិ និងគុណវិបត្តិរបស់ខ្លួនឯង ហើយនិងដាក់ទិសកសាងខ្លួនឯង ។

[១០:២៩:២៧]

ស៖ អ៊ីចឹង អាប្រជុំជីវភាពហ្នឹង តើក្រុមរបស់លោកនុ៎ង មានគ្នាប៉ុន្មាននាក់ចូលរួមប្រជុំទៅ ក្នុងម្តងៗ?

ឆ៖ ចំពោះក្រុមខ្ញុំ អាហ្នឹងគឺខ្ញុំចាំមិនច្បាស់លាស់ទេ ។ ក៏ប៉ុន្តែ តាមចំណាំគឺថាមិនលើសពីបួនប្រាំនាក់ទេ ។

**ស៖** ចុះនៅពេលសួរចម្លើយ តើមានអ្នកផ្សេងមកចូលរួមសួរចម្លើយជាមួយលោកដែរឬទេ?

**ឆ៖** ចំពោះខ្ញុំសួរ សូមជម្រាបលោក វាថាខ្ញុំសួរចម្លើយមានពីរវគ្គ ។ ដំបូង ខ្ញុំសួរខ្មែរ កាលពេលខ្ញុំសួរខ្មែរ ក៏គ្មានអ្នកណាក្រៅពីខ្លួនឯង ម្នាក់ឯងទេ ។ ហើយមានតែកងការពារ ដែលគេចាំយាមអ្នកទោសនោះឯង នេះម្យ៉ាង ។ ម្យ៉ាងទៀតដល់ពេលសួរយួនៗ នេះគឺដំបូងមានម្នាក់ ក៏ប៉ុន្តែខ្ញុំភ្លេចឈ្មោះហើយ ។ ហើយបើពូហ៊ា នោះ គាត់មកចូលរួមម្តងម្កាលតែប៉ុណ្ណឹង ។ ហើយមានតែខ្ញុំហើយនិងអ្នកការពារ ។ ដល់ក្រោយមកបានម្នាក់ដែលសួរជាមួយនឹងខ្ញុំហ្នឹងទៅបាត់ទៅ បាន មិត្តឌុច នេះឲ្យអ្នកទោសម្នាក់ឈ្មោះចាន់ ដែលមកពីហាណូយនោះមកបកប្រែ នែ៎យួនឲ្យខ្ញុំ ។ នឹងខ្ញុំសួរជាមួយ ចាន់ ហ្នឹងរហូតទាល់តែដល់ពេល នែ៎ យួន នែ៎ កងពងវៀតណាមនឹងចូលមកដល់ភ្នំពេញ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាក ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចនីតិវិធីសវនាការដេញដោល ។ ហើយមន្ត្រីតុលាការជូនលោក ម៉ម ណៃ ទៅរកកន្លែងបានសម្រាកសមរម្យនៅក្នុងពេលអំឡុងឈប់សម្រាកនេះ ហើយនិងឲ្យនាំគាត់ត្រឡប់មកវិញ បានមុនម៉ោងដប់មួយខ្វះដប់នាទី ។

*[សវនាការសម្រាកពីម៉ោង ១០:៣៣នាទី ដល់ម៉ោង ១០:៥៣នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោល លើសាក្សីឈ្មោះ ម៉ម ណៃ ហៅ ចាន់ ។ ប្រគល់វេទិកានេះទៅជូនលោកចៅក្រម ធូ មណី ដើម្បីសួរសាក្សីរូបនេះជាបន្ត ។ សូមអញ្ជើញលោកចៅក្រម ។

**សួរដោយចៅក្រម ធូ មណី៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក ម៉ម ណៃ មុននេះបន្តិចនេះលោកបានអះអាងថា លោកកន្លងមកធ្លាប់សួរតែអ្នកទោសដែលមិនសូវសំខាន់ ហើយនិងអ្នកទោសដែលជាជនជាតិវៀតណាម ។ អ៊ីចឹង តើក្នុងការសួរអ្នក

ទោសជនជាតិវៀតណាមនោះ តើលោកចេះភាសាវៀតណាមដែរឬទេ? ឬក៏ត្រូវការការសួរនោះឆ្លងកាត់អ្នកបកប្រែ?

**ឆ៖** ខ្ញុំដំបូងខ្ញុំចេះវៀតណាមតិចៗ ហើយខ្ញុំសួរម្នាក់ឯងដោយធ្វើកាយវិការ ឬក៏គូរអីអាត្រង់ណាខ្ញុំមិនចេះ ខ្ញុំគូរជារូបជាអីទៅ ហើយឲ្យវៀតណាមហ្នឹងវាឆ្លើយតាមហ្នឹង ។ ហើយក្រោយមកបានន៏មានអ្នកមកបកប្រែ អាហ្នឹងខ្ញុំក៏ចេះវៀតណាមកាន់តែច្រើនហើយ ហើយក៏បានអ្នកជំនួយការបកប្រែមកទៀត អាហ្នឹងវាកាន់តែល្អ ។ ហើយកាលខ្ញុំសួរដំបូងថា មិត្តឌុច គាត់ប្រាប់ខ្ញុំថា ខាងលើឲ្យខ្ញុំសួរក្នុងមួយខែ ឲ្យបានចម្លើយហ្នឹងជូនខាងលើ ។ ហើយចម្លើយហ្នឹងវា តាមពិតវាអត់មានអីពិបាកទេ គឺចម្លើយអំពីសមរភូមិ ។ ហើយខ្ញុំក៏ធ្វើការហ្នឹងបាន វាមិនល្អទេ ក៏ប៉ុន្តែ វាគួរសម គ្រាន់តែបានដឹងសភាពការណ៍សមរភូមិ ហើយជូនទៅ មិត្តឌុច ទៅ ។

**ស៖** សូមអរគុណ ។ ហើយអ៊ីចឹង យើងសូមត្រឡប់ទៅក្រោយបន្តិច ។ លោកបានអះអាងថា ធ្លាប់ធ្វើការចូលព្រៃក៏ជាមួយ ឌុច ហើយអម្បាញ់មិញនេះ លោកបានអះអាងថា ឌុច ណែនាំឲ្យសួរសំណួរហ្នឹងឲ្យបានក្នុងរយៈពេលមួយខែ ហើយលោកក៏បានអនុវត្ត ដោយសារថាសំណួរហ្នឹងវាមិនជាពិបាកអីទេ ប្រហែលគ្រាន់តែពីសភាពការណ៍នៅសមរភូមិ ។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើ ឌុច ហ្នឹង គឺជា ឌុច ដែលមានឈ្មោះពិតប្រាកដ កាំង ហ្កេកអ៊ាវ ហៅ ឌុច ហ្នឹង ឬក៏មិនមែនទេ? ឌុច ដែលស្ថិតនៅចំពោះមុខលោកនោះលោកស្គាល់ដែរ? គឺ ឌុច ហ្នឹង ឬក៏មិនមែនទេ?

[១០:៥៦:៤៦]

**ប្រធានអង្គជំនុំ៖**

លោក ម៉ម ណៃ ចាំដល់ពេលរង់ចាំបង្អង់បន្តិច ដល់ពេលមានភ្លើងក្រហមនៅអាក្បាលមេក្រូហ្នឹង សូមលោកនិយាយនោះបានសំឡេងលោកឮដល់ទៅអ្នកបកប្រែ ហើយអ្នកបកប្រែអាចបកប្រែជាភាសាអង់គ្លេស ឬភាសាបារាំងបាន ។ ហើយសង្ឃឹមថា លោកនឹងអនុវត្តឲ្យបានល្អនៅលើចំណុចនេះ ដើម្បីឲ្យមានការកត់ត្រានូវកំណត់ហេតុជាពាក្យសម្ដីរបស់លោក ទាំងការស្ដាប់ ទាំងការកត់ត្រាបានផង ។ ហើយអាចសួរម្ដងទៀតនូវសំណួរអំមិញនេះ ដូចជាមិនទាន់បានឆ្លើយតាម-- ឮតាមក្បាលមីក្រូដែលអាចបកប្រែភាសាបានទេ ។

**សួរដោយចៅក្រម ធូ មណី៖**

**ស៖** អ៊ីចឹង លោក ម៉ម ណៃ សូមលោកបញ្ជាក់មើល តើលោក ឌុច ដែលលោករៀបរាប់ ធ្លាប់

និយាយកន្លងមកហ្នឹង តើជាលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលស្ថិតនៅចំពោះមុខលោកនេះ ឬក៏មិនមែនទេ?

**ឆ៖** មុននឹងខ្ញុំឆ្លើយ ខ្ញុំសូមអភ័យទោសអំពីសំណាក់លោកប្រធាន ដែលខ្ញុំប្រញាប់និយាយពេក ។ ហើយបន្តទៅខ្ញុំនឹងព្យាយាមធ្វើយ៉ាងណាឲ្យសវនាការនេះបានល្អតាមសំណូមពររបស់លោកប្រធាន ។ គឺមិត្ត ឌុច នេះហើយដែលជាប្រធានឲ្យខ្ញុំសួរចម្លើយយួនឲ្យបានតាមខាងលើតម្រូវនោះ ។

**ស៖** អរគុណ ហើយចំណុចមួយទៀត ដែលលោកអះអាងថាបន្ទាប់ពីជ័យជម្នះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ នោះ លោកបានប្តូរពីអមលាំងមកភ្នំពេញនេះ គឺនៅ*ប៉េអេស* តើលោកអាចបញ្ជាក់បានទេ *ប៉េអេស* ហ្នឹងស្អីទៅ *ប៉េអេស*?

**ឆ៖** គឺកន្លែងន៉ែ ប៉ូលិសសម័យសម្តេច សីហនុ ធ្វើការ ។

**ស៖** កន្លងមកហ្នឹង យើងធ្លាប់តែឮ *ប៉េហ្ស៊ី (PJ)* គឺប៉ូលិស*យុដេហ្ស៊ី* ហ្នឹង តើ *ប៉េអេស (PS)* ហើយនិង*ប៉េហ្ស៊ី (PJ)* ជាកន្លែងតែមួយ ឬក៏ផ្សេងគ្នា?

**ឆ៖** តាមខ្ញុំយល់ គឺថាកន្លែងនុ៎ងកន្លែងជាមួយគ្នា ។

**ស៖** លោកបានអះអាងថា ក្នុងការសួរអ្នកទោសដែលជាជនជាតិវៀតណាមនេះ លោក ឌុច ធ្លាប់បានណែនាំលោកឲ្យសួរក្នុងរយៈពេលប៉ុន្មានៗ អ៊ីចឹងណ៎ា ។ ថាតើលោក ឌុច ហ្នឹងមានធ្លាប់ដែលណែនាំលោកអំពីវិធីសាស្ត្រក្នុងការសួរ ឬក៏អាចឲ្យធ្វើក្នុងការធ្វើទារុណកម្មអីដែរឬទេ?

[១១:០០:០៨]

**ឆ៖** ចំពោះរូបខ្ញុំដែលសួរយួនក៏ដោយ សួរខ្មែរក៏ដោយ មិត្តឌុច មិនដែលពន្យល់ពីរឿងឲ្យធ្វើទារុណកម្ម ឬក៏ឲ្យធ្វើអីផ្សេង ឲ្យរបៀបសួរផ្សេងអីទេ ។

**ស៖** អាហ្នឹងចំពោះលោកផ្ទាល់ ចុះចំពោះក្រុមសួរចម្លើយផ្សេងទៀត តើលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះអាចណែនាំ ឬក៏បង្រៀនពីវិធីសាស្ត្រ ឬក៏ទារុណកម្មដល់ក្រុមអ្នកសួរចម្លើយផ្សេងទៀតដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោក! គឺជាគោលការណ៍ដូចខ្ញុំបានជម្រាបលោកហើយថា ការងារគេ គេដឹង ការងារយើង យើងដឹង ។ ដូច្នេះខ្ញុំមិនដឹងថា គាត់ណែនាំ ឬមិនបានណែនាំអ្នកសួរចម្លើយដទៃទៀតយ៉ាងណានោះទេ ។

**ស៖** ក្នុងការចាប់ខ្លួននាំយកមកមន្ទីរស-២១នេះ តើលោកដឹងទេថា គេឃុំខ្លួនជនដែលចាប់ខ្លួនយកមកនោះនៅកន្លែងណាខ្លះ?

**ឆ៖** រឿងហ្នឹងក៏ខ្ញុំមិនដឹងទេ ឃុំនៅកន្លែងណាខ្លះទេ គ្រាន់តែដឹងថា បើកន្លែងនែ៎ វិទ្យាល័យពញាយ៉ាត គ្រាន់តែដឹងថានៅក្នុងវិទ្យាល័យពញ៉ាយ៉ាតតែប៉ុណ្ណឹង ។

**ស៖** ចុះការឃុំខ្លួនហ្នឹង លោកមានដឹងទេ តើឃុំខ្លួនហ្នឹងជានៅក្នុងបន្ទប់រួម ឬក៏អ្នកទោសម្នាក់ៗគេដាក់ដាច់ដោយឡែកពីគ្នា?

**ឆ៖** បញ្ហានេះក៏ខ្ញុំមិនដឹងដែរ ពីព្រោះខ្ញុំមិនមែនជាអ្នកគ្រប់គ្រងអ្នកអី មានភារកិច្ចអីធំដុំ ដូចគេដូចឯងទេ គ្រាន់ថាជាកម្មាភិបាលសាមញ្ញម្នាក់ខាងសួរចម្លើយប៉ុណ្ណឹង ។

**ស៖** អ៊ីចឹងកន្លែងដែលលោក ដែលធ្វើការសួរចម្លើយទៅលើអ្នកទោសនោះ ស្ថិតនៅក្នុងទីតាំងវិទ្យាល័យពញ៉ាយ៉ាតនោះ ឬក៏នៅខាងក្រៅ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំសួរចម្លើយនៅផ្ទះខាងក្រៅ ចម្ងាយប្រហែលពីពីររយទៅបីរយម៉ែត្រ ។

**ស៖** អ៊ីចឹង លោកធ្លាប់បានដែលបានចូលទៅក្នុងទីតាំងគុកស-២១ ហ្នឹង គឺទីតាំងវិទ្យាល័យពញាយ៉ាត ហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺខ្ញុំថ្ងៃមួយខ្ញុំសុំអនុញ្ញាត មិត្តឌុច ទៅជួបកូនសិស្សដល់មូលដ្ឋានគេចាប់បញ្ជូនមក ។ ក៏ប៉ុន្តែមានកន្លែងជួបនៅក្នុងមែន ក៏ប៉ុន្តែខ្ញុំមិនបានដើរពេញពាសនុ៎ង ដើម្បីរកកូនសិស្សខ្ញុំនោះទេ ។ គឺគេយកមកឲ្យខ្ញុំជួបប៉ុណ្ណឹង ជួបហើយខ្ញុំក៏ត្រូវចេញមកវិញទៅ ។

**ស៖** លោកធ្លាប់បានចូលទៅក្នុងកន្លែងនោះប៉ុន្មានដងដែរ តាំងពីលោកចាប់ផ្តើមធ្វើការរហូតដល់លោករត់ចេញនេះ?

**ឆ៖** ខ្ញុំបានទៅនៅពេលដែលខ្ញុំទៅសួរកូនសិស្សខ្ញុំនោះ ។

**ស៖** ចុះការរៀបចំប្រជុំជីវភាព ឬក៏ប្រជុំរៀនសូត្រនយោបាយធំៗមួយឆ្នាំម្តង ឬក៏មួយខែម្តងនោះ តើគេរៀបចំពិធីប្រជុំហ្នឹងនៅកន្លែងណា?

**ឆ៖** ប្រជុំរៀនសូត្រនយោបាយនៅវិហារ នែ៎ សាសនាកាតូលិក នៅក្រៅគុកនោះ ។ ហើយប្រជុំជីវភាព អាហ្នឹង គឺខ្ញុំភ្លាប់កន្លែងវាមិនទៀងទាត់ដូចជា ប្រជុំនៅផ្ទះគាត់ក៏មិនដឹង ហើយមានពេលមួយនោះទៅប្រជុំនៅខាងក្រៅ នៅខាងត្បូងវ៉ារទេះភ្លើង ។

**ស៖** អ៊ីចឹងអ្នកទោសដែលគេនាំយកមកឲ្យលោកសួរចម្លើយនោះ តើលោកពិនិត្យឃើញថា ពេលដែលគេនាំយកមកនោះ គេដាក់ខ្នោះយ៉ាងម៉េច? ចងដៃយ៉ាងម៉េច? ឬក៏គេចងមុខឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! គេដាក់ខ្នោះក្រពាត់ដៃមកក្រោយ ហើយគេរុំមុខ ។

**ស៖** នៅពេលដែលមកដល់បន្ទប់សួរចម្លើយ តើគេធ្វើរបៀបម៉េចទៀត?

**ឆ៖** ជម្រាបប្រសាសន៍លោក! មកដល់ផ្ទះដែលខ្ញុំសួរចម្លើយ គេយកអ្នកទោសនោះដាក់ខ្នោះជើងទាំងពីរ រួចហើយគេដោះខ្នោះ គេស្រាយមុខទៅ ហើយគេថយទៅអង្គុយនៅឯមាត់ច្រកចេញ ។ គេទុកឲ្យខ្ញុំ ហើយនិងអ្នកទោសធ្វើការងារទៅ ។

**ស៖** តើលោកមានដឹងទេថា តើពេលដែលគេចាប់អ្នកទោសមកនោះមានធ្វើជាប្រវត្តិរូប ឬក៏ថតរូបអីអ្នកទោសទុកដែរឬទេ?

**ឆ៖** រឿងហ្នឹងខ្ញុំក៏មិនដឹងដែរ ពីព្រោះថាវាជាភារកិច្ចគេផ្សេងទៀត ហើយដល់ខ្ញុំក៏មិនបានដេញដោលសួរគេដែរ ខ្លាចមានបញ្ហាដល់ខ្លួនឯង ហ្នឹងទីមួយ ។ ទីពីរក៏វាមិនដែលបានជួបគ្នាទៀត ។

**ស៖** អ៊ីចឹងនៅពេលដែលគេបញ្ជូនលោកបញ្ជូនមនុស្សយកមកឲ្យលោកសួរចម្លើយ តើគេមានបញ្ជូនសំណុំលិខិត ឬក៏សំណុំរឿងដែលជនជាប់ចោទ ជនដែលគេចាប់បញ្ជូនមកនោះមកជាមួយឬទេ ឬក៏បញ្ជូនតែមនុស្សមកឲ្យលោកសួរតែម្តង?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺគេបញ្ជូនតែមនុស្សមកឲ្យខ្ញុំសួរតែម្តង ។

**ស៖** ហើយលោកអាចពិនិត្យបានទេ ថាតើអ្នកទោសដែលគេនាំមកឲ្យលោកសួរចម្លើយនោះ តើលោកអាចពិនិត្យឃើញថាមានស្លាកស្នាមដែលបណ្តាលមកពីការធ្វើទារុណកម្មដែរឬទេ?

**ឆ៖** ខ្ញុំមិនបានឃើញមានស្លាកស្នាមអីទេ ហ្នឹងម្យ៉ាង ។ ម្យ៉ាងទៀតក៏ខ្ញុំមិនសូវយកចិត្តទុកដាក់ដែរឃើញតែគេស្លៀកពាក់ធម្មតាមកអ៊ីចឹង ។

**ស៖** អំពីសម្លៀកបំពាក់របស់ជនជាប់ចោទ លោកថាគេស្លៀកពាក់ធម្មតា តើស្លៀកពាក់យ៉ាងម៉េចទៅ? ស្លៀកពាក់ខោអាវគេ ដែលគេមានពីអង្គភាពគេដើម ឬក៏ជាខោអាវដែលផ្លាស់ប្តូរនៅក្នុងមន្ទីរ ស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោក! មិនដឹងជាខោអាវមកពីអង្គភាពដើមគេមិនដឹង ឬក៏អី ក៏ប៉ុន្តែខ្ញុំឃើញជាខោអាវធម្មតា វាមិនមែនជាខោអាវរបស់អ្នកបដិវត្តន៍ ពីព្រោះអ្នកបដិវត្តន៍គេស្លៀកពាក់ខ្មៅ ហើយនេះស្លៀកពាក់ខោអាវពណ៌ ។

[១១:១០:០៧]

**សៈ** អាចប្រាប់យើងបានទេ តើអ្នកទោសដែលគេចាប់ឃុំខ្លួននៅក្នុងមន្ទីរស-២១ ហ្នឹងគេឱ្យរបបអាហារគ្រប់គ្រាន់ដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោក! បញ្ហានេះខ្ញុំរឹតតែមិនដឹងតទៅទៀត ។

**សៈ** អ៊ីចឹងនៅពេល ដែលគេនាំអ្នកទោសយកមកឱ្យលោកសួរ លោកពិនិត្យឃើញថា តើអ្នកទោសដែលគេនាំមកនោះមានសុខភាពល្អ សាច់ឈាមធម្មតា ឬក៏មានការស្គមស្គេកស្គាំងអាចបណ្តាលមកពីអត់អាហារនោះ?

**ឆៈ** សូមជម្រាបប្រសាសន៍លោក! គឺតាមដែលខ្ញុំមើល គឺអ្នកទោសនោះមិនមានអីស្គម មិនមានអីស្គេកស្គាំងទេ គឺជាមនុស្សដែលមានសុខភាពធម្មតា មិនស្គម ហើយក៏មិនធាត់ ។

**សៈ** អ៊ីចឹង នៅក្នុងបន្ទប់ដែលលោកសួរចម្លើយហ្នឹង តើគេមានដាក់តាំងនូវឧបករណ៍សម្លាប់ធ្វើទារុណកម្មផ្សេងៗនៅក្នុងបន្ទប់ ឬក៏លើតុនោះទេ ដើម្បីជាការគំរាម សម្លុតស្មារតីដល់អ្នកទោសដែរត្រូវសួរចម្លើយនោះ?

**ឆៈ** នៅក្នុងបន្ទប់ខ្ញុំសួរចម្លើយ ទាំងនៅលើជញ្ជាំង ឬក៏នៅលើតុ គឺគ្មានអ្វីទេ គឺរលីងស្អាត ។

**សៈ** លោកបានអះអាងថាលោកធ្លាប់សួរតែមនុស្សមិនសំខាន់ ហើយនិងអ្នកទោសវៀតណាមមួយចំនួន ។ អ៊ីចឹង អ្នកទោសដែលសំខាន់ៗហ្នឹង តើក្រុមណាមួយដែលជាអ្នកទទួលខុសត្រូវក្នុងការសួរចម្លើយនោះ?

**ឆៈ** អ្នកទោសសំខាន់ៗដែលសួរចម្លើយនោះ តាមដឹង គឺមានមួយក្រុមទៀត ដែលមានមិត្ត ប៉ុន ជាអ្នកសួរ ។

**សៈ** តើក្រុមមិត្ត ប៉ុន នុំងក្នុងការសួរចម្លើយនោះ តើក្រុមនោះមានការធ្វើទារុណកម្មអីទៅលើអ្នកទោសដែរឬទេ?

**ឆៈ** រឿងហ្នឹងក៏ខ្ញុំមិនដឹងដែរ ពីព្រោះការដែលសួរចម្លើយក្រុម មិត្តប៉ុន នុំង ប្រហែលជានៅតាមខ្ញុំប៉ាន់ប្រហែលជា៥០០ម៉ែត្រពីកន្លែងខ្ញុំសួរ ។

**សៈ** ក្រៅពីក្រុមមិត្ត ប៉ុន ហ្នឹង តើមានក្រុមសួរចម្លើយណាផ្សេងទៀតដែរឬទេ?

**ឆៈ** ក្រៅពីក្រុមមិត្តប៉ុន ហ្នឹង គឺថាមានអ្នកសួរចម្លើយដូចលោកបានសួរខ្ញុំពីលើកមុនថា មានគេសួរចម្លើយប៉ុន្មានដែលខ្ញុំសារភាពប្រាប់លោកថា ខ្ញុំក្តាប់មិនបានទេ គឺវាមាន ក៏ប៉ុន្តែមិនដឹងជាគេសួរ

ប៉ុន្មាននាក់ ខ្ញុំក្តាប់វាមិនបានដែរ ។

**ស៖** អ៊ីចឹងលោកមានដឹងទេ ថាតើនៅស-២១ ហ្នឹងគេបែងចែកអ្នកសួរចម្លើយជាក្រុម ។ ឧទាហរណ៍ជាក្រុមត្រជាក់ ក្រុមស្ករក្តៅ ឬក្រុមអង្កៀមនោះ លោកមានបានដឹងពីបញ្ហាហ្នឹងដែរឬទេ?

**ឆ៖** បញ្ហានេះ ខ្ញុំមិនបានដឹងទេ គឺថាខ្ញុំ ខ្ញុំសួរតែរឿងអត់ធ្វើទារុណកម្ម ពីព្រោះអី ពីព្រោះខ្ញុំយល់ថា ជាការធ្វើទារុណកម្មមិនបានចម្លើយល្អត្រឹមត្រូវទេ គឺមានភាគត្រឹមត្រូវតិចណាស់ ។

**ស៖** អ៊ីចឹងលោកជឿថាមានការធ្វើទារុណកម្មទេនៅមន្ទីរស-២១?

**ឆ៖** បញ្ហានេះដូចខ្ញុំជម្រាបលោកពីដំណាក់មុនអ៊ីចឹងថា វាប្រហែលជាមាន ពីព្រោះអី ពីព្រោះតាមក្រឹត្យក្រមសាកលលោកពីមុន ខ្ញុំមិននិយាយបច្ចុប្បន្នទេ ពីមុន ហើយប៉ូលិសខ្មែរពីមុនគេធ្វើទារុណកម្ម ។ ដូច្នេះខ្ញុំមិនអាចនិយាយថា គេធ្វើ ឬគេមិនធ្វើនោះទេឲ្យបានច្បាស់នោះទេ ខ្ញុំមិនដឹងដែរ ។

**ស៖** ក្រៅពីការសួរចម្លើយហើយ តើអ្នកទោសទាំងនោះ ក្រោយពីបានទទួលចម្លើយសារភាពហើយ តើអ្នកទោសទាំងនោះគេនាំយកទៅណា? គេដោះលែង ឬក៏បញ្ជូនទៅកម្ទេច?

**ឆ៖** បញ្ហានេះក៏ខ្ញុំក្តាប់មិនបាន ពីព្រោះអី? ពីព្រោះខ្ញុំជាអ្នកសួរចម្លើយ ខ្ញុំមិនមែនជាអ្នកការពារ ហើយខ្ញុំមិនមែនជាអ្នកមានសិទ្ធិដឹងឮបញ្ហាទាំងនេះទេ ។

**ស៖** តាមការកត់សម្គាល់កន្លងមក ដូចយើងឃើញថាលោក គឺជាអ្នកសួរចម្លើយដែលមានបទពិសោធន៍យូរតាំងពីនៅក្នុងមន្ទីរសន្តិសុខនៅអមលាំងរហូតមកដល់មន្ទីរស-២១ ។ អ៊ីចឹង អាចនិយាយបានថា ជាអ្នកដែលសួរចម្លើយមានបទពិសោធន៍ ។ អ៊ីចឹង តើលោកដែលមានបានចែករំលែកនូវបទពិសោធន៍របស់លោកហ្នឹងទៅដល់ពួកក្មេងៗអ្នកសួរចម្លើយនៃមន្ទីរស-២១ ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំគ្មានតួនាទីអីទៅហៅថាណែនាំវិធីសួរ ឬក៏អីដល់អ្នកដទៃទេ។

**ស៖** ក្នុងការសួរចម្លើយលោកហ្នឹង លោកធ្លាប់បានសួរចម្លើយទៅលើអ្នកទោសជាស្ត្រីដែរឬទេ?

**ឆ៖** បញ្ហានេះខ្ញុំភ្លេចអស់ហើយ ខ្ញុំមិនចាំទេ ដឹងថាខ្ញុំបានសួរ ឬអត់ទេ ។

**ស៖** តើលោកធ្លាប់បានធ្វើទារុណកម្ម ឬក៏ឃើញអ្នកផ្សេងធ្វើទារុណកម្មអ្នកទោសនៅមន្ទីរ ស-២១ ដែរឬទេ?

[១១:១៩:២៤]

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំមិនដែលធ្វើទារុណកម្មទេ ហើយអ្នកដទៃទៀតក៏ខ្ញុំមិនដឹង ពីព្រោះផ្ទះសួរចម្លើយវាដាច់ពីគ្នាឆ្ងាយៗពីគ្នា មិនដឹងជាអ្នកណា គេសួរត្រង់ណា អ្នកណា គេធ្វើអីត្រង់

ណា ហើយក៏ជាគោលការណ៍ គឺមិនប៉ាំនទាក់ទងគ្នាទេ ។ អ្នកណានៅកន្លែងណា គឺនៅកន្លែងហ្នឹងទៅ សួរកន្លែងហ្នឹងទៅ អត់មានដើរប្រសេចប្រសាចដូចសង្គមចាស់នោះទេ ។

**ស៖** តើលោកមានដែលធ្លាប់បានសួរចម្លើយទៅលើបុគ្គលិករបស់មន្ទីរស-២១ ខ្លួនឯងផ្ទាល់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំអត់ដែលបានសួរទេ។

**ស៖** អ៊ីចឹងលោកមានដែលដឹងទេថា បុគ្គលិករបស់មន្ទីរស-២១ ហ្នឹងត្រូវបានគេចាប់ខ្លួន?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ក៏ប៉ុន្តែ គ្រាន់តែមួយនោះធ្លាប់ដេកជាមួយនឹងខ្ញុំហើយស្រាប់តែបាត់ខ្លួនទៅអាហ្នឹង ខ្ញុំសង្ស័យគេចាប់ខ្លួន ។

**ស៖** អ៊ីចឹងតើលោកមានដឹងពីមូលហេតុនៃការបាត់ខ្លួនឬក៏ការចាប់ខ្លួនអ្នកនោះទៅទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំអត់ដឹងទេ មិនដឹងមូលហេតុអីទេ ស្រាប់តែបាត់ៗទៅ ។

**ស៖** ក្រៅពីការសួរចម្លើយអ្នកទោសតើលោកអាចដឹងទេ អំពីការជោគវាសនាអ្នកទោសទាំងនោះ ត្រូវគេយកទៅណា ដោះលែងឬមួយកម្ទេច?

**ឆ៖** ខ្ញុំពុំបានដឹងថាគេដោះលែងឬកម្ទេចនោះទេ ពីព្រោះខ្ញុំមិនប៉ាំនដេញដោលសួរ សូម្បីតែមិត្តឌុច ក៏មិនប៉ាំនសួរខ្លាចនែគេចោទប្រកាន់ខ្ញុំថា ខ្ញុំទាក់ទិនខ្សែខ្មាំងដែរ ។

**ស៖** ក្នុងអំឡុងពេលដែលលោកធ្វើការនៅមន្ទីរស-២១ តើលោកស្គាល់បុគ្គលិកមន្ទីរស-២១ ចំនួនប៉ុន្មាននាក់ទៅ ហើយឈ្មោះអីខ្លះទៅ?

**ឆ៖** ក្នុងអំឡុងកាលដែលខ្ញុំធ្វើការនៅស-២១ នេះ ខ្ញុំស្គាល់តែអនុប្រធាន ពូហ៊ី ហើយនិងពួកក្មេង មកពីអមលាំង ហើយ មិត្តប៉ុន ហើយនិងនៃ មិត្តហ៊ុយ នៅស្រែ និង ហ៊ុយ មួយទៀតនៅខាងប្រចាំការចាំ ទទួលមនុស្ស ។ ឯអ្នកដទៃទៀតខ្ញុំមិនបានស្គាល់ឈ្មោះ ឬក៏ស្គាល់ខ្លះហើយភ្លេចអស់ទៅ ។

**ស៖** អ៊ីចឹងតើលោកមានដឹងទេ តើនៅស-២១ នុំងមានក្រុមអ្នកសួរចម្លើយជាស្ត្រី?

**ឆ៖** បញ្ហាក្រុមសួរចម្លើយជាស្ត្រីនោះខ្ញុំបាទគ្រាន់តែបានដឹងបានឮក៏ប៉ុន្តែមិនដឹងថា មានសមាជិកប៉ុន្មានទេ គ្រាន់តែដឹងថា ប្រពន្ធពូហ៊ី ធ្វើប្រធានតែប៉ុណ្ណឹង ។

[១១:២៤:៤៣]

**ស៖** ចុះស្ត្រីដែលជាអ្នកទោសដែលគេចាប់មកហ្នឹងមានស្ត្រីដែលមានផ្ទៃពោះ ឬក៏មានកូនតូចមកជាមួយដែរឬទេ?

**ឆ៖** នេះដូចខ្ញុំជម្រាបប្រសាសន៍លោកអ៊ីចឹងថា ខ្ញុំមិនអាចដឹងអីទាំងអស់ពីព្រោះខ្ញុំគ្មានតួនាទីអីសំខាន់ នេះម្យ៉ាង ។ ម្យ៉ាងទៀត គ្មានច្បាប់ទម្លាប់ដើរពាសវាលពាសកាលទេ គឺនៅតែមួយកន្លែង ។ បើនិយាយឱ្យស្រួលស្តាប់ដូចជាសង្គមចាស់គេថា ធ្វើថ្លង់ធ្វើគទៅ ឱ្យដាំដើមគចុកត្រចៀកទៅកប្បាស ។ ដូច្នេះ មិនចង់ដឹងរឿងអ្នកដទៃទេ ពីព្រោះកាលដែលខ្ញុំមិនចង់ដឹងរឿងអ្នកដទៃហ្នឹងហើយបានជាខ្ញុំរស់នៅរហូតដល់ឥឡូវ ។ បើខ្ញុំចចេសចចូចប្រហែលជាខ្ញុំនឹងត្រូវគេចាប់បាត់ទៅហើយ ។

**ស៖** អ៊ីចឹងតើនៅក្នុងអំឡុងពេលនៃការសួរចម្លើយអ្នកទោស តើមានអ្នកណាត្រួតពិនិត្យអំពីការសួរចម្លើយហ្នឹងដែរឬទេ?

**ឆ៖** ចំពោះខ្ញុំគឺខ្ញុំសួរចម្លើយអត់មានអ្នកណាមកត្រួតពិនិត្យទេ សូម្បីតែ មិត្តឌុច ក៏គាត់អត់មកត្រួតពិនិត្យពេលខ្ញុំសួរចម្លើយដែរ ។ គាត់ចាំតែទទួលសេចក្តីកត់ត្រាជូនគាត់តែប៉ុណ្ណឹង ។ ហើយពូហ៊ីគ្រាន់តែមកឈរអើតមួយភ្លែត ហើយក៏គេចេញទៅ ។ ដូច្នេះបញ្ហាត្រួតត្រារឿងសួរចម្លើយមើលចម្លើយអីហ្នឹងអត់មានទេ ។

**ស៖** ក្នុងការសួរចម្លើយអ្នកទោសមួយៗ តើគេមានកំណត់ពេលវេលាច្បាស់លាស់ ឬក៏ចំនួនពេលដែលច្បាស់លាស់សម្រាប់ការសួរចម្លើយទេ? ឧទាហរណ៍អ្នកទោសម្នាក់ត្រូវសួរមួយលើក ពីរលើក ឬក៏មួយសប្តាហ៍មួយខែ តើគេមានកំណត់ជាគោលការណ៍ដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ចំពោះខ្ញុំជាអ្នកសួរចម្លើយដែរ ប្រធានឌុច មិនដែលទៅកំណត់ថា ខ្ញុំត្រូវសួរមួយខែ ពីរខែទេ លើកលែងតែចម្លើយយួនដល់ខាងលើត្រូវការសមរភូមិ បានមិត្តឌុច ប្រាប់ខ្ញុំថាការពិតខ្ញុំមិនទាន់ចេះយួនច្បាស់លាស់ ហើយមិនទាន់មានអ្នកបកប្រែច្បាស់លាស់កំណត់ថា មួយខែឱ្យបានសភាពការណ៍សមរភូមិ ។

**ស៖** ចុះចម្លើយសារភាពដែលទទួលបានពីរអ្នកទោសដែលត្រូវបានសួរនោះតើគេបញ្ជូនទៅដល់ណា?

**ឆ៖** បញ្ហាការបញ្ជូនចម្លើយហ្នឹងទៅដល់ណា អាហ្នឹងគឺថា ខ្ញុំមិនដឹងដែរ ពីព្រោះខ្ញុំដឹងថា បើខ្ញុំសួរដល់តែត្រឹម មិត្តឌុច តែប៉ុណ្ណឹង ។

[១១:២៩:១៩]

**ស៖** នៅក្នុងការសួរចម្លើយនោះគឺគេសួរអំពីប្រវត្តិរូប ប្រវត្តិសកម្មភាព ហើយនិងអាចជាការខ្សែក្សែត់ តើលោកសង្កេតឃើញទេ ឧបមាថា អ្នកទោសម្នាក់ដែលបានឆ្លើយដាក់អ្នកផ្សេងអំពីខ្សែក្សែត់

របស់គាត់ ថ្នាក់លើមេដឹកនាំក្បត់របស់គាត់ តើលោកសម្គាល់ឃើញថា មានការចាប់ខ្លួនអ្នកដែលគេឆ្លើយដាក់នោះមកមន្ទីរស-២១ បន្តបន្ទាប់ឬទេ?

**ឆ៖** បញ្ហានេះក៏ខ្ញុំក្តាប់មិនបាន ហើយខ្ញុំមិនដឹងទៀត ។

**ស៖** តើខ្លួនលោកផ្ទាល់ តើចម្លើយសារភាពដែលយកបានអ្នកទោសនោះ តើលោកយល់ថាការឆ្លើយនោះគឺជាការពិតឬក៏មិនពិត?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺចំពោះខ្ញុំ ខ្ញុំយល់ថា វាជាការពិតខ្លះនិងមិនពិតខ្លះ ។ ហើយដែលថា ការពិតហ្នឹងគឺថា វាត្រង់កម្រិតស្រាល វាមិនមែនកម្រិតធ្ងន់ទេ ។

**ស៖** ក្នុងនាមលោកជាបុគ្គលិកម្នាក់នៃមន្ទីរស-២១ តើលោកអាចដឹងបានទេ ថាតើខាងព្រៃសនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរស-២១ ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! តាមការប្រជុំជីវភាពគឺថា ព្រៃសហ្នឹងវានៅក្រោមការគ្រប់គ្រងរបស់២១ ។

**ស៖** តើលោកអាចដឹងទេថាព្រៃសនោះជាកន្លែងសម្រាប់ធ្វើអ្វីទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ព្រៃស តាមខ្ញុំដឹងគឺធ្វើស្រែ ។

**ស៖** តើកម្លាំងពលកម្មដែលធ្វើស្រែនោះគេប្រើប្រាស់បុគ្គលិកធម្មតា ឬក៏ប្រើប្រាស់កម្លាំងរបស់អ្នកទោស?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺថាត្រង់ប្រើប្រាស់កម្លាំងខ្ញុំបាទមិនដឹងថា ប្រើប្រាស់កម្លាំងប្រភេទណាខ្លះទេ ។

**ស៖** តើអ្នកដែលនៅព្រៃសនោះ ទទួលការឃុំខ្លួនក្នុងមន្ទីរឃុំឃាំងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំមិនដឹងដែរ ។

**ស៖** លោកមានដែលធ្លាប់បានទៅព្រៃសដែរឬទេ?

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោក! ខ្ញុំដូចជាបានទៅម្តងក្រោយពេលរំដោះបានប្រហែលជាពីរបីខែ ពីព្រោះខ្ញុំទៅមើលកន្លែងគេធ្វើស្ពាន ហើយនិងធ្វើទ្វារទឹក។ ហើយក្រោយមកខ្ញុំអត់បានទៅទេ ពីព្រោះថានៅពេលគ្រោងការធ្វើស្ពានធ្វើទំនប់ទឹកហ្នឹង មិត្តឌុច បានឲ្យវិស្វករម្នាក់គូសប្លង់ ហើយវាត្រូវអស់ស៊ីម៉ង់ដ៍ច្រើន ហើយពូហ៊ី គេថា គេធ្វើអស់ស៊ីម៉ង់ដ៍តិច អ៊ីចឹងខ្ញុំក៏លែងបានទៅៗ ហើយដឹងការងារនោះគេធ្វើយ៉ាងម៉េច ខ្ញុំមិនដឹងដែរ ។

**ស៖** អ៊ីចឹងលោកអាចរៀបរាប់បានទេអំពីការទិដ្ឋភាពនៅព្រៃស តើជាកន្លែងវាលស្រែ ឬក៏មានអគារសម្រាប់ឲ្យអ្នកទោសស្នាក់នៅយ៉ាងម៉េចដែរ?

[១១:៣៥:០០]

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំក្ដាប់មិនបានទេ ខ្ញុំគ្រាន់តែទៅឃើញវាលស្រែតែប៉ុន្នុំង ហើយគ្រាន់តែឃើញផ្ទះកំពឹកកំពកតែប៉ុណ្ណឹង អត់មានអគារអីធំដុំទេ ហ្នឹងកាលដែលខ្ញុំទៅឃើញ។ ប៉ុន្តែក្រោយមកខ្ញុំ មិនដឹងយ៉ាងម៉េចទេ ។

**ស៖** ក្នុងពេលដែលលោកទៅនោះ គឺលោកបានជួបឃើញអ្នកទោសដែលត្រូវឃុំខ្លួននៅព្រៃសនោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ក្នុងពេលដែលខ្ញុំទៅនោះ ខ្ញុំគ្រាន់តែទៅមើលកន្លែងដែលគេថាត្រូវសង់ស្ពាន ហើយនិងកន្លែងដែលធ្វើទ្វារទឹក រួចហើយខ្ញុំត្រឡប់មកវិញមក ។

**ស៖** ចុះលោកមានដែលបានដឹងអំពីកន្លែងវាលពិឃាតជើងឯកដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំមិនដឹងទេ ហើយរហូតមកដល់ថ្ងៃនេះ មិនដឹងជើងឯកហ្នឹងនៅឯ ណាផង ។

**ស៖** ក្នុងអំឡុងពេលដែលលោកធ្វើការនៅមន្ទីរស-២១ រហូតដល់ពេលរំដោះដែលកងទ័ពវៀត-ណាមចូលនោះ តើលោកមានដឹងថា អ្នកទោសទាំងនោះត្រូវបានគេសម្លាប់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំមិនបានដឹងទេ ។

**ស៖** ចុះនៅថ្ងៃដែលកងទ័ពវៀតណាមចូលភ្នំពេញ តើលោកនៅឯណា?

**ឆ៖** នៅពេលកងទ័ពវៀតណាមចូលមកភ្នំពេញ ខ្ញុំនៅកន្លែងនៃផ្ទះខ្ញុំខាងកើតគុក ហើយដល់ឮសូរកាំភ្លើងខ្ញុំក៏នាំគ្នារត់ទៅកន្លែងដែលមានពួកកងការពារ ហើយក៏យកកាំភ្លើង យកអី ដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតណាម ក៏ប៉ុន្តែកាំភ្លើងនោះបានបាញ់តែមួយគ្រាប់ ហើយឆ្លាក់ទៅនាំគ្នារត់ថយមកក្រោយវិញអស់មក ។

**ស៖** ថយក្រោយនោះ លោករត់ទៅណាទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ថយក្រោយនោះ គ្រាន់តែថយមកដើម្បី ថារៀបចំវៃវៀតណាមវិញ ប្រយុទ្ធតទល់ ក៏ប៉ុន្តែពួ ហ៊ា ថាអត់ទេ តទល់មិនកើតទេ ពីព្រោះអត់មានពេទ្យ អត់មានអី ក៏នៅសម្ងំប្រហែលជារសៀលល្ងាចបាននាំគ្នារត់ចេញទៅបឹងទំពន់ទៅ ។

[១១:៣៩:៤០]

**ស៖** តើលោកមានដឹងទេ នៅថ្ងៃចុងក្រោយនៅថ្ងៃទី៦ ឬក៏ទី៧ មករា ឆ្នាំ១៩៧៩ ហ្នឹងមានសល់អ្នកទោសនៅក្នុងមន្ទីរឃុំឃាំងស-២១ ទៀតដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំអត់បានដឹងទេ ។

**ចៅក្រម ធូ មណី៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក ម៉ម ណៃ ខ្ញុំចង់ត្រឡប់ទៅក្រោយបន្តិចនៅពេលដែលលោកនៅជានិស្សិត នៅជាកូនសិស្ស មុនពេលដែលលោកក្លាយទៅជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា តាមពិតនៅពេលដែលលោកនៅរៀននៅឡើយនោះ លោកបានសិក្សានៅសាលាគរុកោសល្យនៅភ្នំពេញ គរុវិជ្ជានៅភ្នំពេញ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺពិត ។

**ស៖** តើលោកបានរៀនភាសាអ្វី បរទេសអ្វីក្រៅពីភាសាខ្មែរដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ក្រៅពីភាសាខ្មែរ ខ្ញុំរៀនភាសាបារាំង ហើយអង់គ្លេសតិចៗ ។

**ស៖** តើកម្រិតនៃការចេះដឹងភាសាបារាំងរបស់លោកហ្នឹងត្រឹមណាដែរ?

**ឆ៖** កម្រិតភាសាបារាំងរបស់ខ្ញុំកាលសម័យនោះត្រឹមថ្នាក់ទីបី បារាំងគេថា ក្លាស ឌឺទ្រ័រជាម *(Class de troixème)* ។

**ស៖** អ៊ីចឹងលោកនិយាយភាសាបារាំងបានល្អ ហើយអាចអាន អាចសរសេរបានល្អ តើត្រូវទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺត្រូវ ។

**ស៖** តើត្រឹមត្រូវទេលោកបានសិក្សាអំពីវិទ្យាសាស្ត្រផងដែរ?

[១១:៤៣:០៤]

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! វិទ្យាសាស្ត្របានរៀនសូត្រទាំងគណិតវិទ្យា ទាំងរូបវិទ្យា គីមីវិទ្យា ធម្មជាតិវិទ្យា ។

**សៈ** ហើយក្រោយមកលោកបានទៅបង្រៀននៅសៀមរាប តើមែនទេ?

**ឆ៖** ការនេះពិតលោកស្រី ។

**សៈ** បន្ទាប់មកលោកទទួលបានជោគជ័យ ហើយទទួលបានកន្លែងមួយនៅសាលាគរុវិជ្ជាមួយនៅភ្នំពេញ តើមែនទេ?

**ឆ៖** ក្រោយមកខ្ញុំប្រលងចូលសាលាគរុវិជ្ជាផ្នែកខាងសាស្ត្រាចារ្យ គឺខ្ញុំប្រលងជាប់ ក៏ប៉ុន្តែជាប់កាលណោះ ជាប់ជាអ្នកបម្រុងទេ តែដល់មានមិត្តម្នាក់គេមានបងប្អូនគេធ្វើរដ្ឋលេខាធិការក្រសួងអប់រំ ក៏គេទាក់ទិននឹងរដ្ឋលេខាធិការក្រសួងអប់រំនោះ សុំបានចូលមក ព្រោះគេជាប់បម្រុងដូចខ្ញុំដែរ ហើយជាប់នៅខាងក្រោមខ្ញុំ ដូច្នេះ ខ្ញុំបានមកដោយបម្រុងទេ មិនមែនប្រលងជាប់បានពេញសិទ្ធិនឹងគេទេ ។

**សៈ** ប៉ុន្តែនៅពេលដែលលោកបានចូលមកដល់វិទ្យាស្ថានគរុវិជ្ជានោះ គឺលោកបានទទួលជោគជ័យ ហើយលោកបានទទួលលេខមួយនៅក្នុងថ្នាក់នៅក្នុងឆ្នាំដំបូង តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថាខ្ញុំបានលេខមួយពិតមែន ។

**សៈ** ហើយលោកជានិស្សិតលេខមួយនៅក្នុងចំណោមសិស្សពីររយនាក់ជាភាសាបារាំង តើមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថាអាហ្នឹងគឺប្រលងឆមាសទេលោកស្រី គឺធ្វើអត្ថាធិប្បាយគរុកោសល្យ និងខ្ញុំរកបកជាភាសាខ្មែរមិនទាន់ សុំអត់ទោសសូមជម្រាបថា វាជា ឌីសៀប៉ាហ្សុង ហ្វីឡូហ្វីកូប៉េដា ។

**សៈ** Yes well please do you wish to say some French? *(គ្មានការបកប្រែ)*

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី គឺខ្ញុំចេះនិយាយបារាំង ។

**សៈ** អរគុណ ដូចលោកបាននិយាយជាភាសាបារាំងរួចហើយ អ៊ីចឹងខ្ញុំបន្តទៅទៀត ក្រោយពីទទួលបានសញ្ញាប័ត្របញ្ចប់ហើយ ហើយលោកបានទៅបង្រៀននៅកំពង់ធំ តើមែនឬទេ?

**ឆ៖** ជាការពិតលោកស្រី ។

**សៈ** ហើយក្រោយមកលោកក្លាយជានាយកនៅលីសេកំពង់ធំ វិទ្យាល័យកំពង់ធំ តើមែនឬទេ?

[១១:៤៧:០៧]

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថានេះមិនពិតទេ គឺក្រោយខ្ញុំបង្រៀន គឺខ្ញុំទៅជាសិក្សាភិរក្ស បារាំងគេថា សង់ធ័រ នៅវិទ្យាល័យកំពង់ធំ ហើយសូមជម្រាបលោកស្រីបន្តទៅទៀត មួយឆ្នាំក្រោយមក ខ្ញុំទៅជានាយកអនុវិទ្យាល័យបល្ល័ង្ក ។

**ស៖** សូមអនុញ្ញាតថយក្រោយទៅបន្តិច ចំណុចមួយដែលលោកបាននិយាយជាភាសាបារាំងពីមុននោះ សូមលោកបញ្ជាក់ជាភាសាបារាំងឡើងវិញបន្តិច ដើម្បីឱ្យអ្នកបកប្រែភាសាបារាំង នោះគាត់អាចនិយាយបាន ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី គឺថា គឺជាអត្ថបទដែលខ្ញុំសរសេរចុងក្រោយមួយនៅក្នុងបរិមាធិប្បាយ ។

**ស៖** ក្រោយពីក្លាយទៅជានាយកសាលារួចហើយ លោកបានចូលបដិវត្តន៍ ហើយបានជាប់ពន្ធនាគារហើយ ហើយការអប់រំពីដំបូងៗរបស់លោកហ្នឹងត្រូវបានបញ្ឈប់ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថាក្រោយពីធ្វើនាយកសាលាអនុវិទ្យាល័យបល្ល័ង្ក គឺខ្ញុំត្រូវរដ្ឋការរបស់សម្តេច សីហនុ ចាប់ដាក់គុក ។

**ស៖** ដូចបានពិនិត្យមើលនូវការសិក្សារបស់លោក គឺជាមុខវិជ្ជាជីវៈរបស់លោកពីដំបូង ហើយនិងការជោគជ័យក្នុងការសិក្សា តើយើងអាចនិយាយបានទេ ថាលោកជាអ្នកមានការអប់រំបានខ្ពស់ហើយក៏ជាអ្នកបញ្ញាល្អដែរ?

**ឆ៖** ជម្រាបលោកស្រី! ត្រង់បញ្ហានេះសូមលោកស្រីជ្រាប ខ្ញុំមិនហ៊ានមានអំនួតលើខ្លួនឯងទេ។

**ស៖** សូមអរគុណ ។ ក្នុងពេលដែលលោកបានធ្វើការនៅស-២១ ក្នុងឋានៈជាអ្នកសួរចម្លើយនោះ លោកបានពន្យល់ឱ្យយើងយល់ខ្លះ ដើម្បីលោកការពារខ្លួនឯងបាន លោកបានសម្រេចថាមិនចង់ដឹងរឿងរ៉ាវពីអ្នកដទៃទាល់តែសោះអំពីជាពិសេសអ្វីដែលបានកើតឡើងនៅទីនោះ ។ តើអ៊ីចឹងមែនទេអ្វីដែលលោកបានបញ្ជាក់ខាងដើមនោះ?

**ឆ៖** ជាការពិតអ៊ីចឹងមែនលោកស្រី ។

**ស៖** ហើយបន្ទាប់មក លោកប្រហែលជាមានតែលោកម្នាក់ទេ ដែលមានការអប់រំខ្ពស់ ហើយជាអ្នកដែលមានបញ្ញាឆ្លាតជាងគេនៅស-២១ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ខ្ញុំទទួលស្គាល់ថា ខ្ញុំរៀនបានខ្ពស់មែន ពីព្រោះអីខ្ញុំជាប់បរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ តែត្រង់ថាឲ្យខ្ញុំឈ្លាសវៃឆ្លាតជាងគេនៅស-២១ អាហ្នឹងខ្ញុំមិនប៉ាននិយាយទេ ។

**ស៖** នៅពេលដែលលោកធ្វើជាអ្នកសួរចម្លើយនៅស-២១ លោកបានសិក្សាភាសាវៀតណាម ដើម្បីអនុញ្ញាតឲ្យលោកអាចសួរចម្លើយអ្នកទោសវៀតណាមបាន រហូតទាល់តែមានអ្នកចេះនិយាយភាសាវៀតណាម មកធ្វើការជាមួយដើម្បីជួយ តើមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! អ៊ីចឹងមែន ។

**ស៖** នៅពេលដែលលោកធ្វើការនៅអមលាំង ដែលបានចូលៗធ្វើការនៅក្នុងមន្ទីរសន្តិសុខ ក្នុងឋានៈជាអ្នកសួរចម្លើយដែរ តើលោកបានទទួលការបណ្តុះបណ្តាល ឬអប់រំឲ្យចេះពីវិធីសួរចម្លើយដែរឬទេ?

**ឆ៖** ចំពោះបញ្ហានេះលោកស្រី គឺអត់បានរៀនសូត្រអីទេ គ្រាន់តែអង្គុយមើល មិត្តឌុច គាត់សួរចម្លើយ ហើយគាត់គ្រាន់តែប្រាប់ថា អាហ្នឹងគេសួរប្រវត្តិរូប ហើយនិងប្រវត្តិសកម្មភាពតែប៉ុណ្ណឹង ។

**ស៖** ក្នុងខណៈដែលលោកសិក្សាតាមរយៈការមើល ឌុច នោះតើលោកបានសង្កេតឃើញថាមានការប្រើទារុណកម្មអ្វីដែរឬទេនៅមន្ទីរសន្តិសុខនៅអមលាំងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! នៅពេលដែលខ្ញុំអង្គុយមើល មិត្តឌុច សួរចម្លើយឃើញគាត់អត់មានប្រើហិង្សាធ្វើទារុណកម្មអីទេ សូម្បីតែរំពាត់មួយនៅជិតគាត់ក៏អត់មានដែរ ។

[១១:៥៣:២៨]

**ស៖** តើលោកយល់ដឹងច្បាស់អំពីវិធីសួរចម្លើយរបស់អ្នកសួរចម្លើយផ្សេងទៀតទេនៅមន្ទីរសន្តិ-សុខអមលាំងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ខ្ញុំមិនបានដឹងអីពីគេឯទៀតទេ ។

**ស៖** តើលោកនៅចាំទេ ដែលមានអ្នកសួរសម្ភាសន៍របស់លោកពេលមួយ គឺមានឈ្មោះ សឹម សុរិយ៉ា ហើយនិង ហ្វាប៊ីយៀន លូកូ ដែលជាអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះ តើលោកនៅចាំទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី ខ្ញុំចាំខ្លះ ភ្លេចខ្លះ ។

**ស៖** នៅក្នុងអត្ថបទអង់គ្លេស ERN គឺ 00162818 គេបានសួរលោកថា-- ហ្វាប៊ីយៀន លូកូ នោះសួរលោកទាក់ទងទៅនឹងនៅមន្ទីរសន្តិសុខអមលាំង តើមានអំពើទារុណកម្មទេ? ហើយលោកបាន

ឆ្លើយកាលណោះថា “គេបានប្រើទារុណកម្មខ្លះ” តើលោកនៅចាំទេចម្លើយពេលនោះនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! កាលនោះលោក សុរិយ៉ា ហើយនិង ហ្វាប៊ីយៀន ហ្នឹងសួរពីរឿងទារុណកម្ម ខ្ញុំថាប្រហែល ខ្ញុំមិនថាច្បាស់លាស់ទេ ប្រហែល ។ ហើយគេបានសួរខ្ញុំតទៅទៀតថា “តើគេអាចធ្វើនឹងអី?” ខ្ញុំក៏តាមការវិភាគរបស់ខ្ញុំ ហើយមានពិសោធន៍ពីប៉ូលិសសង្គមចាស់គេប្រើប្រាស់ថា “គ្មានអីក្រៅពីរំពាត់ទេ” ។

**ស៖** ដូច្នេះ ពេលដែលគេសួរលោក គេសួរថា “តើលោកធ្លាប់បានឃើញឧបករណ៍ធ្វើទារុណកម្ម?” ហើយលោកឆ្លើយថា “មិនមានអ្វីទេ មានតែរំពាត់” ហ្នឹងជាចម្លើយដែលលោកបានឆ្លើយ តើត្រឹមត្រូវទេ?

**ឆ៖** អាហ្នឹង គឺវាត្រឹមត្រូវហើយ ដូចខ្ញុំជម្រាបប្រសាសន៍លោកស្រីអំមិញអ៊ីចឹង ។

**ស៖** ក្រោយមកគេក៏បានសួរលោកតទៅទៀត “តើដំណើរការប្រព្រឹត្តទៅនៃស-២១ ដូចគ្នានឹងអមលាំងទេ?” ពេលនោះលោកឆ្លើយថា នៅក្នុងអត្ថបទអង់គ្លេស ERN 00162909 គឺមាន-- លោកឆ្លើយថា “មានភាពខុសគ្នាខ្លះ គឺមានភាពដូចគ្នាខ្លះ” តើនេះជារបៀបដែលលោកអាចបញ្ជាក់បានដែរឬទេចម្លើយនោះ?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកស្រី ខ្ញុំថាមានដូចគ្នាខ្លះ មានខុសគ្នាខ្លះ ។ មានដូចគ្នា គឺត្រង់ដែលថា ធ្វើប្រវត្តិរូប ហើយធ្វើប្រវត្តិសកម្មភាព ហើយប្រហែលជាខុសគ្នា មិនដឹងជាអ្នកសួរគេសួរពីរឿងដូចម្ដេចទៀត ។

[១១:៥៧:៤៣]

**ស៖** តាមវិធីសាស្ត្រផ្សេងទៀត ថាតើលោកចង់បញ្ជាក់ថា គេប្រើរំពាត់ខ្សែតីដូចនឹងអមលាំងដែរ ឬក៏គេប្រើរំពាត់អ្វីផ្សេង?

**ឆ៖** បញ្ហានេះខ្ញុំអត់ដឹងដែរ ។

**ស៖** តើលោកអាចពន្យល់ខ្ញុំបានទេ អ្វីដែលលោកអាចនិយាយបានថា គេប្រើវិធីសាស្ត្រខុសគ្នា ប្រសិនបើលោកមិនដឹងថាវិធីសាស្ត្រអ្វីនោះម៉េចទេ នៅស-២១ នោះ?

**ឆ៖** ខ្ញុំក៏មិនដឹងដែរ មិនយល់ដែរ មិនដឹងគេប្រើវិធីសាស្ត្រអីខ្ញុំមិនដឹងដែរ ។

**ស៖** នៅស-២១ តើលោកធ្លាប់បានចូលរួមនៅក្នុងការអប់រំអ្វីទេអំពីវិធីសាស្ត្រ ហើយនិងគាត់ទចក្នុងការសួរចម្លើយដែរឬទេ?

**ឆ៖** នៅស-២១ ជម្រាបប្រសាសន៍លោកស្រី គឺខ្ញុំមិនចាំអីទេ ព្រោះខ្ញុំរៀន វារៀនច្រើន ហើយជាពិសេស គឺរៀនខាងនយោបាយនោះ ។

**ស៖** តើជនជាប់ចោទធ្លាប់បានបង្រៀនអ្នកសួរចម្លើយអំពីរបៀបសួរចម្លើយដែរឬទេ?

**ឆ៖** បញ្ហានេះ ជម្រាបប្រសាសន៍លោកស្រី ខ្ញុំក្តាប់មិនបានទេ ខ្ញុំមិនដឹងថាបានបង្រៀនឬអត់ ខ្ញុំក៏មិនដឹងដែរ ។

**ស៖** ម្តងទៀតនៅលើអត្ថបទអង់គ្លេស ERN00162915 គេបានសួរលោកជាក់លាក់នូវសំណួរបែបនេះថា "ថាតើ ឌុច ធ្លាប់បានបង្រៀនអ្នកសួរចម្លើយអំពីរបៀបសួរចម្លើយដែរឬទេ?" ពេលនោះលោកឆ្លើយថា "ជាទូទៅ ខ្ញុំបានឃើញ គេមិនដែល-- មិនបានហៅអ្នកសួរចម្លើយទៅប្រជុំនោះទេ ហើយការបង្រៀនទៅអ្នកសួរទាំងនោះ គឺគេមិនឲ្យអ្នកផ្សេងដឹងទេ ជាពិសេសឲ្យអ្នកសួរចម្លើយនោះឲ្យគេអនុវត្តនូវវិធីសួរចម្លើយអង្កៀម" តើលោកនៅចាំទេ ចម្លើយដែលលោកបានឆ្លើយពេលនោះ?

**ឆ៖** បញ្ហាសួរអង្កៀម គឺខ្ញុំនៅចាំ គឺគាត់ឧស្សាហ៍ណែនាំខ្ញុំថា "បើសួរវាមិនចេញទេ គឺថា សួរអង្កៀមដដែលៗៗៗៗ ទៅ ហើយព្យាយាមកុំធុញទ្រាន់" តែត្រង់គាត់ណែនាំអ្នកដទៃទៀត ខ្ញុំក្តាប់មិនបានដែរ ។

[១២:០១:៣៨]

**ស៖** តើជនជាប់ចោទរៀបរាប់ប្រាប់លោកដូចម្តេចដែរ អំពីវិធីសាស្ត្រសួរចម្លើយរបៀបអង្កៀមនោះ?

**ឆ៖** គឺជម្រាបប្រសាសន៍លោកស្រី! គឺសួរយូរហើយដដែលៗហ្នឹង អត់មានស្អីប្លែកទេ គឺព្យាយាម ។

**ស៖** តើលោក-- តើគាត់ធ្លាប់បានរៀបរាប់អំពីវិធីសាស្ត្រសួរចម្លើយផ្សេងៗទៀតទេ ដូចជារបៀបសួរក្តៅជាដើមនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ខ្ញុំដូចជាក្តាប់មិនបានទេ បញ្ហានេះ ឬក៏ខ្ញុំភ្លេចក៏មិនដឹង ឬអីក៏មិនដឹង ខ្ញុំ-- ក៏ប៉ុន្តែចំពោះខ្ញុំគាត់អត់ដែលបានណែនាំឲ្យធ្វើវិធីសួររបៀបហ្នឹងទេ ។

**ស៖** លោកបានប្រាប់យើងថា នៅពេលដែលលោកធ្វើជាអ្នកសួរចម្លើយនៅស-២១ នោះ លោកតែងតែសួរចម្លើយតែម្នាក់ឯង ហើយដោយខ្លួនឯង តើមែនឬទេ?

**ឆ៖** ការពិត លោកស្រី ។

**ស៖** តើធ្លាប់មានអ្នកយាមនៅក្នុងបន្ទប់សួរចម្លើយជាមួយលោកដែរឬទេ?

**ឆ៖** អ្នកយាមនៅមាត់ច្រកលោកស្រី អត់មកជិត អត់មក-- ប៉ានមករវីរវល់ជាមួយខ្ញុំ ហើយនិងអ្នកជាប់ចោទទេ ។

**ស៖** តើលោកធ្លាប់ប្រើរំពាត់ខ្សែតីដែរទេ នៅក្នុងពេលសួរចម្លើយម្តងៗនោះ?

**ឆ៖** ខ្ញុំពុំដែលមានរំពាត់អីផង ។

**ស៖** តើធ្លាប់មានបុគ្គលណាផ្សេង ហើយកត់ត្រាៗចម្លើយ ដែលលោកបានសួរទៅអ្នកទោសហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! កាលខ្ញុំនៅសួរអ្នកជាប់ចោទខ្មែរ អត់មានអ្នកណាដែលមកកត់ត្រាជាមួយខ្ញុំទេ ។

**ស៖** អ៊ីចឹងហើយថាមិនមានអ្នកណាម្នាក់នៅក្នុងបន្ទប់ហ្នឹង ដែលគេអាចនិយាយបានពីរបៀបដែលលោកសួរចម្លើយទៅជនដែលថា លោកទទួលការអ្នកទោសមកសួរហ្នឹង គេមិនដឹងពីរបៀបដែលលោកសួរទេ អ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ដឹងតែអ្នកការពារនុ៎ង ព្រោះគេនៅជិតនុ៎ង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធានខ្ញុំនៅសល់សំណួរពីរបីទៀតសម្រាប់សាក្សីនេះ ប៉ុន្តែប្រហែលជាដល់ពេលសម្រាប់សម្រាកថ្ងៃ ឬដូចម្តេច?

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលត្រូវសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ។ អង្គជំនុំជម្រះនឹងបន្តកិច្ចពិភាក្សាដេញដោលនៅរសៀលនេះ ចាប់ពីម៉ោងមួយកន្លះទៅ ។ មន្ត្រីតុលាការសម្របសម្រួលដល់សាក្សី ម៉ម ណៃ ដើម្បីឲ្យគាត់បានទទួលបាននូវកន្លែងសម្រាកសមរម្យ ហើយនាំគាត់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោងមួយកន្លះ ។

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ ។

*[សវនាការសម្រាកពីម៉ោង ១២:០៦នាទី ដល់ម៉ោង ១៣:៣១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ស្តាប់សក្ខីកម្មសាក្សីឈ្មោះ ម៉ម ណៃ ហៅ ចាន់ ហើយជាបន្តនេះ ដោយព្រឹកមិញ គឺលោកស្រីចៅក្រមនៅមានសំណួរមួយចំនួនមិនទាន់សួរអស់ ។ សូមប្រគល់វេទិកានេះទៅលោកស្រីចៅក្រមដើម្បីបន្តសំណួរដល់សាក្សី ។ សូមអញ្ជើញ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក ម៉ម ណៃ លោកបានលើកឡើងថា គេចាត់តាំងលោកឲ្យធ្វើការសួរចម្លើយអ្នកទោស ឬអ្នកជាប់ឃុំវៀតណាម នៅពេលអ្នកទាំងអស់នោះចូលមកស-២១ ។ តើលោកចាំទេ តើនៅពេលណាដែលលោកចាប់ផ្តើមធ្វើការសួរចម្លើយអ្នកឃុំវៀតណាមលើកដំបូង?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! ខ្ញុំមិនចាំថ្ងៃខែដែលចាប់ផ្តើមសួរវៀតណាមដំបូងនោះទេ ។

**ស៖** គឺមួយឆ្នាំក្រោយពេលដែលលោកចាប់ផ្តើមការងារសួរចម្លើយ ឬក៏ពីរឆ្នាំក្រោយពីពេលនោះ តើលោកអាចធ្វើការសន្និដ្ឋានអំពីរយៈពេលនោះដែរឬទេ?

**ឆ៖** សូមជម្រាបលោកស្រី! ខ្ញុំមិនអាចសន្និដ្ឋានការសួរចម្លើយនោះបានកាលវេលានោះទេ ។

**ស៖** តើនរណាគេចាត់តាំងលោកឲ្យធ្វើការសួរចម្លើយអ្នកជាប់ឃុំវៀតណាម?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺមិត្តឌុច ជាអ្នកចាត់តាំងឲ្យសួរ ។

**ស៖** តើលោកសួរចម្លើយអ្នកចារកម្មវៀតណាម និងយោធាវៀតណាមដែរឬទេ?

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកស្រី! ខ្ញុំសួរតែទាហានវៀតណាមទេ ។

**ស៖** នៅពេលដែលទាហានត្រូវបាននាំមកឲ្យលោកសួរចម្លើយ ថាតើគេនោះស្លៀកពាក់យ៉ាងម៉េចដែរ?

**ឆ៖** គេនោះ-- លោកស្រី គេនោះស្លៀកពាក់ជាស៊ីវិល ។

**ស៖** ដូច្នេះ តាមការស្លៀកពាក់ស៊ីវិល ថាតើទាហានទាំងអស់នោះស្លៀកពាក់ខោអាវធម្មតា ឬក៏ស្លៀកតែខោខ្លីដូចដែលសាក្សីគាត់បានពិពណ៌នានិងលើកឡើង?

**ឆ៖** ទាហានវៀតណាមនោះស្លៀកពាក់ស៊ីវិល ខោអាវធម្មតា ។

[១៣:៣៦:០៩]

**ស៖** តើអ្នកជនជាតិវៀតណាមទាំងអស់នោះបានប្រាប់លោកថាជាទ័ពវៀតណាមដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថាគេចាប់មកពីសមរភូមិគេថាគេជាទាហាន ។

**ស៖** តើលោកសួរចម្លើយទាហានទាំងអស់នោះ ដូចគ្នាទៅរបៀបសួរចម្លើយលើអ្នកទោសផ្សេងទៀតដែរឬទេ?

**ឆ៖** ការសួរចម្លើយទាហានទាំងនោះ វាមិនដូចការសួរចម្លើយខ្មែរទេ គឺសួរតែពីប្រវត្តិរូប សួរពីមុខងារគេ ហើយនិងសមរភូមិដែលគេវ៉ៃ ។

**ស៖** តើលោកបានប្រើរំពាត់ខ្សែតីវ៉ៃទៅលើអ្នកជាប់ឃុំវៀតណាមនោះដែរឬទេ? ឬក៏លោកប្រើប្រាស់វិធីបង្ខិតបង្ខំអីផ្សេង?

**ឆ៖** ជម្រាបលោកស្រី! គឺការសួរទាហានវៀតណាមនេះ វាមិនបាច់បង្ខិតបង្ខំគេទេ ពីព្រោះសួរតែមុខងារគេ សក្តិគេ ទាហានអង្គភាពគេ ហើយនិងអាវុធប្រើប្រាស់ក្នុងអង្គភាព និងអាវុធអន្តរាគមន៍គឺពួកកាំភ្លើងធំអីប៉ុណ្ណឹង ។ តើគេដឹងឬមិនដឹង ហើយតាំងនុំងនៅកន្លែងណា អីកន្លែងណា ហ្នឹងសួររបៀបអ៊ីចឹង ។

**ស៖** ក្រោយពេលដែលគេទាំងអស់នោះបានឆ្លើយសារភាព ។ ថាតើចម្លើយសារភាពទាំងអស់នោះកត់ត្រាទុក ហើយផ្សព្វផ្សាយតាមរយៈវិទ្យុដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថាសួរឆ្លើយបានត្រឹមត្រូវហើយ អាហ្នឹងគឺថតផ្សាយតាមវិទ្យុ ។

**ស៖** ការផ្សាយតាមវិទ្យុនោះ គឺជាបង្គាប់របស់លោក ឬក៏ការបង្គាប់របស់បុគ្គលផ្សេង?

**ឆ៖** ការផ្សាយតាមវិទ្យុនោះ ខ្ញុំគ្មានសិទ្ធិអីនឹងបង្គាប់ទេ គ្រាន់ថា មិត្តឌុច គាត់ប្រាប់ថា យកកាសែតហ្នឹងទៅចាក់តាមវិទ្យុត្រង់គាត់ថាទទួលបញ្ជាពីនរណាទៀត ខ្ញុំមិនដឹងទេ ។

**ស៖** ថាតើទាហាន-- អ្នកជាប់ឃុំជាទាហាននោះ គេហៅថាជាឈ្លើយសឹកដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! កាលណាបើគេចាប់នៅលើសមរភូមិគេហៅថា ឈ្លើយសឹកហើយ ។

**ស៖** ថាតើជនជាប់ចោទគាត់ប្រើពាក្យនុំងដែរឬទេ? នៅពេលដែលគេចាត់តាំងលោកឲ្យធ្វើការសួរចម្លើយអ្នកជាប់ឃុំទាហានបែបនោះ?

[១៣:៤០:១៩]

**ឆ៖** គាត់មិនបានប្រើពាក្យហ្នឹងទេ គាត់គ្រាន់តែថាសួរទាហានយួនទៅ ។

**ស៖** តើលោកជឿទៅលើចម្លើយសារភាពដែលទាហាននោះបានឆ្លើយសារភាពជូនលោកដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! គឺខ្ញុំជឿថា ទាហាននោះនិយាយការពិត ពីព្រោះថាវាមកវ៉ៃយើងហើយ ។

**ស៖** ខ្ញុំស្នើសុំឱ្យលើកឡើង ERN ជាភាសាខ្មែរ 0066314 ដល់លេខ 0066316 សូមឱ្យបញ្ចាំងឯកសារនេះ ដែលមានលេខ ERN ហ្នឹង ។

សូមអរគុណ ។ តើលោកអាចធ្វើការចុះទៅដល់ចុងទំព័រខាងក្រោមនៃឯកសារនេះ ។ តើនេះជាហត្ថលេខារបស់លោក គឺចាន់ ហើយដែលមានចុះថ្ងៃទី១៤/ ១២/ ឆ្នាំ៧៨?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ហ្នឹងគឺជាស៊ីញ៉េខ្ញុំហើយ ។

**ស៖** សូមអរគុណ ។ ប្រសិនបើយើងបង្វិលឡើងទៅលើ តាមការបកប្រែជាភាសាអង់គ្លេសកថាខណ្ឌទីមួយដែលលោកបានឃើញនៅទីនេះ បានលើកឡើងថា “បច្ចុប្បន្នអាពួកទីមួយៗ គឺជាសម្ដីរបស់វា” ថាតើខ្ញុំបានអានទៅលើវាក្យខណ្ឌហើយឬនៅ? ថាតើនេះគឺជាផ្នែកដែលបានបង្ហាញជាភាសាខ្មែរនៅលើអេក្រង់ហ្នឹងដែរឬទេ? ខ្ញុំសូមអានជាភាសាអង់គ្លេស “បច្ចុប្បន្នអាពួកទីមួយ គឺសម្ដីវា ។ វាកម្ចាចអ្នកដទៃមិនឱ្យទៅប្រយុទ្ធ ដែលមានសតិអារម្មណ៍ វាអស់សង្ឃឹម វាអស់ជំនឿលើបក្សយើង ។ ពួកទីពីរ ទីបី គិតទៅតាមហ្នឹង ។ ដូច្នេះ ពួកនេះមិនធ្វើការប្រយុទ្ធទៅនឹងកងទ័ពកម្ពុជាយើងទេ នៅពេលដែលពួកគេឃើញកងទ័ព ពួកគេបោះក្រវាត់កាំងភ្លើងចោល ហើយរត់ចោលជួរតែម្ដង” ។ ដូច្នេះ នៅក្នុងចម្លើយសារភាពនេះ គឺបានកត់ត្រានៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៨ បានន័យថា តិចជាងមួយខែក្រោយពេលដែលទ័ពវៀតណាមនិងទាហានវៀតណាមបានចូលមកដល់ស-២១ ។ តើលោកជឿទៅលើចម្លើយនេះដែរឬទេនៅពេលនុ៎ង? បានន័យថា វៀតណាមគឺគេនឹងរត់ចោលជួរ ហើយពួកគេមិនប៉ានវាយនឹងកងទ័ពកម្ពុជា ។ ពួកបានក្រវាត់កាំភ្លើងចោលហើយរត់យករួចខ្លួនតែម្ដង ។ តើលោកជឿទៅលើចម្លើយហ្នឹងដែរឬទេនៅពេលនុ៎ង?

**ឆ៖** សូមជម្រាបលោកស្រី! គឺចម្លើយនេះ វាមិនមែនសារភាពសម្រាប់អង្គភាពទាហានយួនទូទៅទេ វាសារភាពតែអង្គភាពតូចមួយរបស់វាតែប៉ុណ្ណោះ ។ ដូច្នេះ ខ្ញុំជឿថា នេះជាអង្គភាពតូចមួយ

ឬជាក្រុមរបស់វាតែប៉ុណ្ណឹងទេ ក៏ប៉ុន្តែជាទូទៅអាហ្នឹងខ្ញុំមិនជឿទេ ។

**ស៖** តើលោកគិតថា បុគ្គលដែលឆ្លើយសារភាពនេះ គឺជាបុគ្គលដែលគាត់មានការភ័យខ្លាចដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ខ្ញុំជឿថា ទាហានយួននេះ គ្មានការភ័យខ្លាចទេ ។

**ស៖** តើមានអ្វីកើតឡើងចំពោះទាហានរូបនេះ ក្រោយពេលដែលគាត់បានផ្តល់ចម្លើយសារភាពរបស់គាត់គ្រប់សព្វអស់ហើយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ក្រោយដែលវាឆ្លើយសព្វគ្រប់ហើយ ខ្ញុំក៏មិនដឹងដែរ ពីព្រោះគេយកទៅឃុំនៅកន្លែងដែលគេដាក់ទោសវាហ្នឹង ។

**ស៖** តើលោកដឹងដែរឬទេ ដឹងអំពីគោលនយោបាយនៅស-២១ ដែរឬទេ ដូចដែលជនជាប់ចោទបានរៀបរាប់ជូនតុលាការ “បុគ្គលទាំងឡាយដែលត្រូវជាប់ឃុំនោះ គឺមានទោសរួចទៅហើយ ហើយបុគ្គលទាំងឡាយដែលគេឃុំនោះ គឺនឹងត្រូវបានគេយកទៅសម្លាប់ចោល”?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី គឺថាបញ្ហានេះ ខ្ញុំមិនដឹងទេ ។

**ស៖** តើលោកអាចប្រាប់ខ្ញុំដែរឬទេថា តើជម្លោះរវាងកម្ពុជានិងវៀតណាម ចាប់ផ្តើមនៅពេលណា?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថាខ្ញុំមិនបានចាំឆ្នាំកាលបរិច្ឆេទពិតប្រាកដទេ ពីព្រោះជម្លោះនេះ វាមានយូរមកហើយ តាំងតែពីមុននឹងរំដោះនោះវាមានការឲ្យទ័ពយៀកកុង ហ្នឹងចេញឲ្យអស់ពីស្រុកខ្មែរមួយលើកហើយ ហើយដល់រំដោះហើយស្រាប់តែឮថា មិនដឹងឆ្នាំទីប៉ុន្មានអីប៉ុន្មានទេស្រាប់តែថាយួនវ៉ៃតាមព្រំដែនចូលមកវិញ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

សូមឲ្យធ្វើការបង្វែរអេក្រង់នេះ មករូបភាពដើមវិញ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

**ស៖** ដូច្នេះលោកកំពុងតែលើកឡើង និងនិយាយថា ជម្លោះរវាងវៀតណាមនិងកម្ពុជា ចាប់ផ្តើមមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថានៅពេលមុនរំដោះហ្នឹង គ្រាន់តែដឹងថាយួនយៀកកុងហ្នឹងត្រូវត្រឡប់ទៅស្រុកវិញតែប៉ុណ្ណឹង ។

**ស៖** លោកបាននិយាយថា វៀតណាមគឺវាយប្រហារមកលើកម្ពុជា តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បញ្ហានេះវាមានជម្លោះព្រំដែន ព្រោះតែគេវ៉ៃមកលើយើងហើយ បានជាយើងដឹងថា នែ៎! គេឈ្លានពាន ។

**ស៖** ដូច្នេះ ជម្លោះនៅតាមព្រំដែន គឺវាកើតឡើងនៅពេលជាមួយគ្នា នៅពេលដែលមានការរំដោះរបស់កម្ពុជាប្រជាធិបតេយ្យ និងការរំដោះភ្នំពេញនេះដែរឬទេ?

**ឆ៖** ការជម្លោះព្រំដែននេះ ក្រោយពីរំដោះហើយ ។

**ស៖** ថាតើជម្លោះនេះវានៅតែបន្តរហូត ក្រោយពីថ្ងៃរំដោះភ្នំពេញ រហូតដល់មានការលុកលុយពីវៀតណាម ហើយបានចូលមកដល់នៅក្នុងភ្នំពេញនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែរឬទេ?

**ឆ៖** ការជម្លោះហ្នឹងមានរហូតមកដល់រំដោះភ្នំពេញ ។

**ស៖** តើលោកធ្លាប់ឮអំពីជម្លោះនេះតាមរបៀបណា តើពីការអប់រំរបស់លោក ឬក៏តាមវិទ្យុ ឬក៏លោកស្តាប់តាមរយៈប្រភពផ្សេង?

**ឆ៖** ខ្ញុំមិនដឹងថា ឮតាមណាទេ ប៉ុន្តែខ្ញុំដឹងតែថា គេចាប់ទាហានវៀតណាមមកឲ្យ ហើយគេថាឈ្លានពានស្រុកយើង ខ្ញុំដឹងតែប៉ុណ្ណឹង ។

**ស៖** តើលោកនៅចាំទេ ធ្លាប់ឮជនជាប់ចោទនិយាយអំពីជម្លោះរវាងវៀតណាមនិងកម្ពុជា ឬក៏ជនជាប់ចោទហ្នឹង ធ្លាប់បាននិយាយពិភាក្សាជាមួយលោកដោយផ្ទាល់?

**ឆ៖** បញ្ហាជម្លោះតាមព្រំដែននេះ គឺខ្ញុំ និង មិត្តឌុច មិនដែលពិភាក្សាគ្នាទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណច្រើន ខ្ញុំពុំមានសំណួរបន្ថែមនោះទៀតទេ លោកប្រធាន ។

[១៣:៥២:៤៨]

**ប្រធានអង្គជំនុំ៖**

អស់លោកចៅក្រម-- សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមសួស្តី លោក ម៉ម ណៃ ខ្ញុំឈ្មោះជាចៅក្រម ឡាវែន៍ ខ្ញុំសូមសួរសំណួរមួយចំនួន ដើម្បីធ្វើការបំភ្លឺទៅលើចំណុចទាំងឡាយ ដែលបានឆ្លើយនៅក្នុងចម្លើយសក្ខីកម្មរបស់លោក ។

**ស៖** ជាបឋម តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ជម្រាបឲ្យបានជាក់លាក់ និងច្បាស់លាស់ថាតើលោកជួបជនជាប់ចោទលើកទីមួយនៅពេលណា? តើលោកបានជួបគ្នានៅពេលដែលរៀបចំប្រលងថ្នាក់បាក់ឌុបដែរឬទេ? ហើយ ឌុច នោះគាត់ជាសិស្សនៅពេលនោះ ហើយលោកបានរៀបចំទៅលើការប្រលងហ្នឹងនៅពេលហ្នឹងជាមួយគ្នា ឬយ៉ាងម៉េច?

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំមិនបានជួបគ្នានៅពេលប្រលងបាក់ឌុបទេ ហើយក្រោយមក គឺថានៅពេលដែលមករៀននៅឧត្តមសិក្សាហ្នឹង ពេលប្រលងសញ្ញាប័ត្រត្រៀមហ្នឹង គឺថាខ្ញុំគ្រាន់តែឃើញទេ យើងឃើញគ្នាទៅវិញទៅមកទេ មិនបានជួបគ្នា ពិភាក្សាគ្នា និយាយគ្នាទេ គ្រាន់តែឃើញ គាត់ឃើញខ្ញុំ ខ្ញុំឃើញគាត់តែប៉ុណ្ណឹង ។

**ស៖** ដូច្នេះ លោកឃើញគ្នានៅវិទ្យាស្ថានគរុកោសល្យ ឬក៏លោកឃើញគ្នានៅកន្លែងណាផ្សេង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ឃើញគ្នានៅសាលាគរុកោសល្យ វិទ្យាស្ថានគរុកោសល្យ។

**ស៖** នៅពេលនោះលោកទាំងពីរហ្នឹងជានិស្សិតឬក៏មានម្នាក់ជាអ្នកបង្រៀនម្នាក់ទៀតជាសិស្ស?

**ឆ៖** នៅពេលនោះ ខ្ញុំមិនដឹងថាគាត់ជានិស្សិត ឬគាត់ជាសាស្ត្រាចារ្យនៅឡើយទេ ក៏ប៉ុន្តែខ្ញុំជាសាស្ត្រាចារ្យហើយ ។

**ស៖** តើលោកអាចរំឭកយើងដែរឬទេ តើនរណាគេជានាយកនៃវិទ្យាស្ថានគរុកោសល្យនៅពេលនោះ?

**ឆ៖** គឺមុនដំបូង ប្រហែលជាលោក កេង វ៉ាន់សាក់ ហើយក្រោយមកគឺលោក សុន សេន ។

**ស៖** តើនៅពេលនោះលោកបានកសាងទំនាក់ទំនងពិសេសណាមួយជាមួយនឹង សុន សេន ដែរឬទេ?

**ឆ៖** អត់មានទេ ។

**ស៖** តើលោកដឹងអំពីការតម្រង់ទិសនយោបាយរបស់គាត់នៅពេលនោះដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ ។

**ស៖** លោកបានពន្យល់ថា គេឃុំលោកក្នុងអំឡុងពេលរបបសម្តេចព្រះបាទ សីហនុ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ថាតើលោកត្រូវបានតុលាការកាត់ទោសដែរឬទេ? ហើយថាតើការកាត់ទោសនោះ គេកាត់ទោសពីអ្វីដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម! ក្នុងសម័យនោះ គេបានកាត់ទោសខ្ញុំ ហើយនៅពេលដែលគ្រួសារខ្ញុំទៅសុំ លន់ នល់ ។ លន់ នល់ បានដោះលែង ហើយតុលាការសឹក ដល់ពេលដោះលែងហើយ តុលាការសឹក គេហៅខ្ញុំទៅជួប គេប្រាប់ថា លោកអត់មានទោសអីទេ អាហ្នឹងសភាពការណ៍នយោបាយតានតឹង លែងលោកក៏មិនបានដែរ ពីព្រោះគេចោទលោកអីចឹងហើយនោះ ។

**ស៖** ដូច្នេះគេដោះលែងលោក បន្ទាប់ពីមានការស្នើសុំទៅដល់ លន់ នល់ ហើយគាត់គឺជាសេនាប្រមុខនៅពេលនោះ តើលោកជាប់ឃុំរយៈពេលប៉ុន្មានដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! បើតាមខ្ញុំចាំ ប្រហែលជាពីរឆ្នាំខ្វះ១២ថ្ងៃ ឬ១៨ថ្ងៃ ។

**ស៖** ក្នុងពេលដែលលោកជាប់ឃុំនោះ តើលោកមានឱកាសជួបនឹងជនជាប់ចោទនេះដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! គឺនៅពេលដែលជាប់គុកសម័យនោះ គឺថាគេដាក់ មិត្តឌុច ហើយនិងខ្ញុំនៅបន្ទប់ជាមួយគ្នា ។

**ស៖** តើនៅពេលដែលលោកជាប់គុកនោះ លោកបាននិយាយអំពីអ្វី? តើលោកបាននិយាយអំពីនយោបាយ ឬយ៉ាងម៉េច?

[១៤:០០:០៧]

**ឆ៖** នៅពេលជាប់គុកនោះ យើងអត់បាននិយាយគ្នាអំពីនយោបាយទេ គ្រាន់តែថា ឥឡូវយើងខំហូបដើម្បីរស់ ។

**ស៖** ក្នុងពេលដែលលោកជាប់គុក តើគេមានធ្វើបាបលោក ឬក៏គេធ្លាប់ប្រព្រឹត្តអ្វីមិនល្អចំពោះលោក ឬក៏ធ្លាប់គេឃើញ ធ្លាប់ឃើញគេធ្វើការប្រព្រឹត្តិមិនល្អចំពោះអ្នកដទៃដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ក្នុងពេលជាប់គុកចំពោះខ្លួនខ្ញុំ ខ្ញុំអត់មានគេធ្វើអីទេ ពីព្រោះខ្ញុំឆ្លង នែ៎! ប៉ូលិសសួរចម្លើយហើយៗ ។ ខ្ញុំគេចាប់ភ្លាម គេបញ្ជូលតុលាការសឹកតែម្តង ។ ហើយនៅក្នុងគុក គឺធ្លាប់ឃើញគេធ្វើបាបអ្នកទោសដែរ ។

**ស៖** ថាតើគេធ្វើបាបយ៉ាងម៉េចដែរ?

**ឆ៖** ក្នុពេលនោះមិនដឹងជារឿងអីទេ ស្រាប់តែឃើញគេវៃអ្នកទោសម្នាក់នៅអានែ៎ សាលា-- ខ្ញុំអាចនិយាយថា សាលាកណ្តាល ។ អាកូនផ្ទះកណ្តាលគេ ចំហសងខាងហ្នឹង ហើយមានអាអ្នកទោសទាហានខ្លះទៀត វាទៅព្រួតវៃរហូតទាល់តែគ្នាសន្លប់ ។

**ស៖** ក្នុងពេលដែលលោកជាប់គុក តើលោកស្គាល់នរណាផ្សេងទៀតដែរឬទេ? ដែលក្រោយមកធ្វើការនៅម-១៣ និងនៅស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោក! នៅពេលជាប់គុក គឺថាអត់មានស្គាល់អ្នកណាទេ មានតែប្រជាជនផ្សេង ។ ហើយគ្មានអ្នកណានៅជាប់គុកនោះ មកធ្វើការជាមួយនៅម-១៣ និងស-២១ នោះទេ ។

**ស៖** ពេលដែលគេប្រាប់លោកថា លោកមិនមានទោសទេ ក្រោយមកគេលែងលោកនោះ តើលោកបានចូលខ្លួនទៅការងារអប់រំធម្មតាវិញដែរឬទេ?

**ឆ៖** ក្រោយពីត្រូវគេដោះលែង ខ្ញុំក៏បានត្រូវចូលទៅធ្វើជាសាស្ត្រាចារ្យវិញ ។

**ស៖** ក្នុងពេលដែលលោកធ្វើសកម្មភាពជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំអាចសួរ តើលោកជាសមាជិកនៃបក្សនោះដែរឬទេ?

[១៤:០៤:៣៥]

**ឆ៖** នៅក្នុងពេលនោះ ខ្ញុំមិនទាន់ជាសមាជិកបក្សទេ ។ ក៏ប៉ុន្តែជាអង្គការរបស់បក្ស គឺជាជនបង្គោល ខ្ញុំចូលជនបង្គោលហើយៗ ។

**ស៖** បន្ទាប់តទៅទៀត នៅពេលដែលលោកក្លាយទៅជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា តើគេបានស្នើឲ្យលោកថាធ្វើប្រវត្តិរូប តើលោកបានបញ្ជាក់ការងារមួយចំនួន ដែលរាប់បញ្ចូលទាំងអ្វីដែលគេបញ្ជូនលោកទៅតុលាការយោធា លន់ នល់ រួចដោះលែង ។ តើលោកបានដាក់ការងារព័ត៌មាននោះក្នុងប្រវត្តិរូបឬទេ?

**ឆ៖** បញ្ហានេះ ខ្ញុំភ្លាប់មិនទេ ខ្ញុំភ្លេច ដឹងខ្ញុំដាក់ ឬមិនដាក់ អាហ្នឹង ខ្ញុំក៏មិនដឹងដែរ ។

**ស៖** ឥឡូវនេះ យើងត្រឡប់ទៅម-១៣ លោកបាននិយាយថា លោកបានទៅដល់ម-១៣ នោះនៅក្នុងឆ្នាំ១៩៧៣ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំទៅដល់ម-១៣ហ្នឹង ១៩៧៣ មែន ។

**ស៖** តើលោកបានដឹងពីមន្ទីរម-១៣(ក) ហើយមន្ទីរមួយទៀតគេហៅថា ម-១៣(ខ) ដែរឬទេ?

**ឆ៖** ខ្ញុំសុំជម្រាបប្រសាសន៍លោក គឺខ្ញុំមិនដឹង ខ្ញុំភ្លេច ខ្ញុំមិនដឹងឯណាឯណីទេ សូម្បីតែអង្គាល់អ្នកសង្កេតការណ៍ជំនួសចៅក្រមស៊ើបអង្កេតទៅសួរខ្ញុំ ក៏ខ្ញុំនឹកឃើញតែឈ្មោះមន្ទីរសន្តិសុខ ខ្ញុំនឹកមិនឃើញថា (ក) នៃ ១៣(ក) ឬអីនោះទេ ។

**ស៖** លោក ម៉ម ណៃ តើលោកមានបញ្ហាពីរឿងការចងចាំដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺជាទម្លាប់ខ្ញុំតាំងពីនៅរៀន ចំពោះកាលបរិច្ឆេទ ខ្ញុំមិនសូវចាំទេ ។ ហើយកន្លងមកក្រោយនេះ ថ្មីៗនេះដោយសារខ្ញុំធ្លាក់ពីលើផ្ទះ វាដាច់ថ្លា សន្លប់ប្រហែលជិតមួយម៉ោង ។ ក្រោយមកខ្ញុំចេះតែភ្លេចៗ ជាបន្តបន្ទាប់ សូម្បីតែជួនកាលកូនខ្លួនឯង នឹករកឈ្មោះទាល់តែរៀបហៅឈ្មោះអីចឹង ភ្លេចភ្លាម ហើយទាល់តែពីម៉ោងបីម៉ោងក្រោយមកបាននឹកឃើញវិញ ។

**ស៖** ហើយថ្ងៃនេះ លោកអាចប្រាប់តុលាការបានទេថា ការចងចាំរបស់លោក ដែលលោកមានឈ្មោះមួយទៀតហៅថា ចាន់ តើពេលនោះគេហៅលោកថា ចាន់ ដែរឬទេ?

**ឆ៖** បដិវត្តន៍គេស្គាល់ឈ្មោះខ្ញុំតែ ចាន់ៗ ទេ ។

**ស៖** នៅដែលលោកធ្វើការនៅម-១៣ តើមានមនុស្សផ្សេងទៀតដែលអ្នកមានឈ្មោះក្រៅដូចឈ្មោះលោកដែរឬទេ?

[១៤:០៩:៣៨]

**ឆ៖** នៅកាលនៅម-១៣ហ្នឹង ដូចជាគ្មានឈ្មោះក្រៅណាទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោក គង់ សំអុន៖**

សាក្សីអាចឆ្លើយ អាចស្តាប់អត់បានច្បាស់ សុំបញ្ជាក់សំណួរម្តងទៀត ព្រោះឈ្មោះក្រៅអំមិញអាចថាឈ្មោះរបស់គាត់ក្រៅ ឬរបស់មនុស្សម្នាក់ទៀត ដែលមានឈ្មោះក្រៅឈ្មោះ ចាន់ ដូចគាត់ ។

សូមអរគុណ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោក ម៉ម ណៃ លោកមានការលំបាកក្នុងការស្តាប់មិនសូវច្បាស់ដែរឬទេ?

**ឆ៖** មានការលំបាកបន្តិចបន្តួចដែរ ។

**ស៖** នៅពេលដែលខ្ញុំសួរសំណួរទៅលោក តើលោកយល់ខ្ញុំដែរឬទេ នៅពេលដែលខ្ញុំសួរថាឈ្មោះក្រៅរបស់លោក ចាន់ នោះ តើលោកយល់ដែរឬទេ ពីឈ្មោះដែលខ្ញុំនិយាយថា ចាន់ នោះតើលោកយល់បានទេ?

**ឆ៖** ខ្ញុំយល់បានហើយ ។

**ស៖** ឥឡូវនេះ តើលោកអាចឆ្លើយសំណួរនេះទេ តើមានមនុស្សផ្សេងទៀត ដែលប្រើឈ្មោះក្រៅនោះដូចដែលឈ្មោះរបស់លោកទេ នៅពេលដែលលោកធ្វើការនៅម-១៣នោះ?

**ឆ៖** ខ្ញុំក្តាប់មិនបានដែរបញ្ហាហ្នឹង ។

**ស៖** លោកមិនអាចនិយាយ ដោយហេតុថា លោកស្តាប់ទៅឮខុសពីអ្វីដែលខ្ញុំសួរ ឬក៏លោកមិនបានគិតពីរឿងហ្នឹង ។

**ឆ៖** ខ្ញុំយល់ថា ខ្ញុំស្តាប់លោកបាន ហើយខ្ញុំយល់ថា ខ្ញុំឆ្លើយទៅលោកវិញក៏តាមហ្នឹងដែរ ។

**ស៖** លោក ម៉ម ណៃ ហៅ ចាន់ នៅពេលដែលលោកនៅម-១៣ តើលោកនៅទីនោះជាមួយប្រពន្ធ ហើយនិងមានកូននៅជាមួយដែរឬទេ?

[១៤:១២:៥៨]

**ឆ៖** នៅម-១៣ ក្រោយមកគឺខ្ញុំ ប្រពន្ធខ្ញុំ ហើយនិងកូនខ្ញុំតូចៗ ឯធំៗវាទៅនៅមន្ទីរកុមារអស់ហើយ ។

**ស៖** តើនៅម-១៣ នោះលោកអាយុប៉ុន្មាន? ហើយកូនៗរបស់លោកអាយុប៉ុន្មានដែរ?

**ឆ៖** នៅម-១៣ ខ្ញុំមិនដឹងជាអាយុប៉ុន្មានទេ ទាល់តែធ្វើការគិតគូរបាន ធ្វើលេខបានដឹង។ ឯកូនៗខ្ញុំគឺថា ក៏ខ្ញុំក្តាប់អាយុមិនបានដែរ ព្រោះគ្រាន់តែដឹងថា អាធំៗពីរនាក់ទៅនៅមន្ទីរកុមារ នៅអាតូចៗនៅជាមួយ ។

**ស៖** ក្រៅពីការដាំដំឡូងនេះ តើលោក ម៉ម ណៃ-- តើ ឌុច ចាត់តាំងឲ្យធ្វើការ ឬការទទួលខុសត្រូវអីផ្សេងទៀតទេ ជាពិសេសនោះ តើគាត់បានផ្ទេរអំណាច ឬចាត់តាំងឲ្យធ្វើអ្វីទេ ពេលដែលគាត់មិននៅមន្ទីរម-១៣នោះ?

**ឆ៖** ពេលគាត់មិននៅ ខ្ញុំក៏អត់មានភារកិច្ចអីទទួលខុសត្រូវដែរ ពីព្រោះនៅទីនោះមានខ្មោចមិត្តមាស គេជាអ្នកការពារនៅទីនោះហើយ ។

[១៤:១៥:00]

**ស៖** ប្រហែលជនជាប់ចោទអាចរំឭកយើងបានពីបញ្ហានេះ ប៉ុន្តែ ខ្ញុំពិនិត្យឃើញថានៅក្នុងការសម្ភាសន៍គាត់ពីមុននោះ គាត់បាននិយាយថា នៅពេលដែលគាត់ទៅចាកចេញឆ្ងាយពីម-១៣ គាត់បានប្រគល់តួនាទីមន្ទីរនេះទៅឲ្យ ប៉ុន ឬក៏ទៅឲ្យ ម៉ម ណៃ ។

លោក ម៉ម ណៃ តើនៅពេលនោះលោកមានការលំបាកជាមួយការមើលមិនច្បាស់ ឬក៏ពេល

នោះមើលឃើញច្បាស់ដែរឬទេ?

**ឆៈ** ខ្ញុំសូមលោកចៅក្រមអភ័យទោស ខ្ញុំមិនយល់សំណួររបស់លោកទេ ។

**សៈ** នៅពេលដែលលោកធ្វើការនៅម-១៣ តើលោកមានបញ្ហាក្នុងការមើលអ្វីមិនច្បាស់ដែរឬទេ? ឬក៏លោកមិនមានបញ្ហាភ្នែកដែលថាមើលអ្វីមិនច្បាស់ទេ?

**ឆៈ** សូមជម្រាបលោកចៅក្រម វាភ្នែកខ្ញុំ វាជាធម្មតា ។

**សៈ** តើលោកអាចប្រាប់យើងបានទេ ថាតើអ្នកទោសនោះគេឃុំខ្លួននៅកន្លែងណា? តើមើលទៅគេមានលក្ខខណ្ឌដូចម្ដេច? ហើយគេឃុំខ្លួនពួកអ្នកទោសហ្នឹងមានលក្ខខណ្ឌដូចម្ដេច? ស្លៀកពាក់អ្វីដែរ?

**ឆៈ** សូមជម្រាបលោកចៅក្រម! តាមដែលឃើញៗស្លៀកខោខ្លី ហើយនៅពេលនោះគេដាក់អ្នកទោសនៅក្នុងរណ្ដៅ ដើម្បីចៀសវាងការទម្លាក់គ្រាប់បែក B52 របស់អាមេរិកាំង ។

**សៈ** ដូច្នេះ គេត្រូវបានឃុំខ្លួនក្នុងរណ្ដៅ ។ តើលក្ខខណ្ឌនៃការឃុំខ្លួននោះជាធម្មតាទេ បើលោកមើលទៅ ឬក៏មានលក្ខខណ្ឌធម្មតាដូចដែលលោកយល់ថា តើវាស្របទៅនឹងភាពថ្លៃថ្នូររបស់មនុស្សដែរឬទេ ការឃុំខ្លួននោះ?

**ឆៈ** ការឃុំខ្លួនគឺនៅក្នុងរណ្ដៅនោះ តាមខ្ញុំឃើញគេដាក់ខ្នោះជើងហើយខ្លួនទទេនិងខោខ្លីមួយ។

**សៈ** លោក ម៉ម ណៃ តើលោកកាន់អាវុធទេនៅពេលនោះ?

**ឆៈ** នៅពេលនោះ ខ្ញុំមិនមានអាវុធវែងទេ ។ ខ្ញុំមានអាវុធខ្លី ក្រោយមកទៀតខ្ញុំទៅដល់មុនដំបូងគឺខ្ញុំខ្លួនទទេ នៅច្រើនខែទៅបានមានអាវុធនៅពេលខ្ញុំគេប្រើខ្ញុំចេញទៅទាក់ទងនឹងតំបន់៣១អី បានខ្ញុំមានអាវុធទៅជាមួយ ។

[១៤:១៩:៥០]

**សៈ** តើលោកធ្លាប់បាញ់ទៅរកអ្នកទោសដែលរត់គេចខ្លួនដែរឬទេ? ឬក៏យ៉ាងហោចណាស់អ្នកទោសដែលចង់គេចខ្លួន ឬព្យាយាមគេចខ្លួននោះ?

**ឆៈ** ជម្រាបលោកចៅក្រម! ខ្ញុំមិនដែលរកបាញ់អ្នកទោសដែលរត់គេចខ្លួននោះទេ ហើយជាពិសេសគឺថា ខ្ញុំអត់យាមអ្នកទោសផង ។

**សៈ** ប្រហែលជាជនជាប់ចោទអាចនឹងបញ្ជាក់ប្រាប់យើងថា តើលោកគាត់គិតដូចម្ដេចចំណុចនេះ? ខ្ញុំនឹកឃើញថានេះជាការងារមួយរបស់លោក ។ តើលោកបានចូលរួម ឬក៏បានឃើញការសម្លាប់

មនុស្សនៅម-១៣ ដែរឬទេ? ជាពិសេស ថាតើមានស្ថានភាពមួយដែលថាគេបានចងអ្នកទោសទៅនឹងបង្គោលដែលថា មានមនុស្សប្រាំនាក់ តើលោកបានឃើញក្នុងចំណោមប្រាំនាក់ហ្នឹងមានម្នាក់ត្រូវបានសម្លាប់ដោយគេបាញ់ទៅចំក្បាលគាត់នោះ?

**ឆះ** ហ្នឹងខ្ញុំមិនដឹងដែរ គឺខ្ញុំចាំមិនបាន ។ ខ្ញុំចាំបានតែថាមានអ្នកទោសរត់តែប៉ុណ្ណឹង ហើយមានគេបាញ់នៅក្នុងព្រៃងណោះ ។ នៅនឹងអូរមានឮសូរកាំភ្លើងហ្នឹង ពីព្រោះកាលដែលអ្នករត់នោះ ខ្ញុំនៅចម្ការដំឡូងប្រហែលជាពីររយម៉ែត្រពីកន្លែងហ្នឹង ។

**សះ** ហើយខ្ញុំនឹកឃើញថានៅក្នុង E1 ចំណុច 11.1 យើងមានប្រតិចារឹក ហើយសាក្សីកំណត់ហេតុសាក្សីមួយដែលគាត់ជាប់នៅម-១៣ ហើយគាត់និយាយថាមានមនុស្សប្រាំនាក់គេចងនឹងបង្គោលហើយម្នាក់ត្រូវបានគេបាញ់ ហើយអ្នកនៅកណ្តាលហ្នឹងត្រូវបាញ់ ហើយមានពីរនាក់ទៀតនៅសងខាងនៅចងជាប់នឹងបង្គោល ហើយអ្នកដែលនៅកណ្តាលត្រូវបានគេបាញ់សម្លាប់ ។ ហើយគាត់និយាយថាអ្នកដែលបាញ់នោះគឺឈ្មោះ តាចាន់ គឺជាមនុស្សម្នាក់ដែលមានវ័យចំណាស់ប្រហែលជាអាយុ៤៥ឆ្នាំ ឬក៏លើសហ្នឹងទៅដោយសារថាគាត់មានកូនស្រី ហើយនិងកូនប្រុសដែលជាកូននោះធំៗដែរហើយ ។

ហើយខ្ញុំក៏ចង់ដឹងបន្ថែមទៀតដែរថា តើលោកគិតដូចម្តេចអំពីចម្លើយរបស់ជនជាប់ទាក់ទងនឹងម-១៣? ជនជាប់ចោទនិយាយថាយើងបានប្រតិចារឹកនៅថ្ងៃទី២១ ខែ៤ ឆ្នាំ២០០៩ គឺE4/13 ហើយ ERN លេខ 00321213 ហើយទៅដល់ 0032121365 ហើយលក្ខខណ្ឌនៃការឃុំខ្លួននៅទីនោះមិនត្រឹមតែអាក្រក់ទេ វាមានលក្ខណៈឃោរឃៅ ហើយវាមានចរិតលក្ខណៈចេញពីការសំអប់ ។ កន្លែងនេះមិនមានលក្ខណៈមនុស្សធម៌មណាស់ មិនមែនជាកន្លែងត្រឹមត្រូវមនុស្សធម៌ជាកន្លែងដែលឃោរឃៅ ។ ជនជាប់ចោទក៏បានបន្ថែមទៀតថា នៅក្នុងកាលៈទេសៈផ្សេងទៀតនោះ ។ ហើយនៅក្នុងស-២១ មានដែរ គឺថាអ្នកដែលគេបញ្ជូនទៅម-១៣ នោះ ហើយអ្នកដែលគេបញ្ជូនទៅ ម-១៣ “ខ” ជាកន្លែងអប់រំកែប្រែ ។ អ៊ីចឹងហើយគេចាត់ទុកថាជាខ្មាំង ហើយគាត់និយាយថាការ-- អ៊ីចឹងហើយការទារុណកម្មគឺជាវិធាន ហើយមានមួយផ្នែកទៀតជាការលើកលែង បើមិនអ៊ីចឹងទេអ្នកជាប់ឃុំនឹងត្រូវបានសម្លាប់ ។

[១៤:២៥:១៥]

លោក ម៉ម ណៃ តើលោកបាននៅកន្លែងជាមួយគ្នាជាមួយនឹងជនជាប់ចោទដែរឬទេ? តើអ្វីដែលជនជាប់ចោទនិយាយនោះតាមទស្សនៈដែលលោកគិតថា តើសម្តីរបស់គាត់នោះជាការពិតដែរឬទេ? ឬគ្រាន់តែជាការបំផ្លើសទៅតាមគំនិតរបស់ជនជាប់ចោទទេ សម្តីអម្បាញ់មិញនោះ?

**ឆ៖** ខ្ញុំទីមួយ ខ្ញុំសូមបដិសេធ ខ្ញុំមិនបានបាញ់អ្នកណាទេ ក៏ប៉ុន្តែទីពីរ ការដាក់ឃុំឃាំងអ្នកទោស ខ្ញុំយល់ថា អានោះជាក្នុងសភាពការណ៍ដែលប្រទេសជាតិកំពុងតែត្រូវអាមេរិកាំងវាវ៉ៃមកលើយើងតាមរយៈ លន់ នល់ ។ ដូចនេះ ការរស់នៅមិនថាតែអ្នកដែលមានទោសទេ សូម្បីតែប្រជាជនធម្មតាក៏រស់នៅយ៉ាងលំបាកវេទនាដែរ ។ នេះបើតាមខ្ញុំយល់គឺអ៊ីចឹង ។ ហើយបើតាមសម្ដីអ្នកដែលឆ្លើយនុ៎ង គឺថាសារភាពនុ៎ង ឬឲ្យការណ៍ហ្នឹង គឺថាជាការមួយដែលប្រៀបធៀបសម័យនោះនឹងសម័យឥឡូវនេះ ។ អ៊ីចឹងវាខុសគ្នាឆ្ងាយណាស់ សម័យឥឡូវគេសំបូរហូរហៀរ សម័យនោះសម័យក្រលំបាកវេទនា សូម្បីតែខ្ញុំ ឬអ៊ីនឹងគឺគ្រាន់តែដំឡូងមួយមើមប្រវែងមួយចំអាមហ្នឹងហូបមួយពេលទៅហើយ ។ អ៊ីចឹង ជនដែលត្រូវជាប់ចោទនោះ តើមានអីនឹងហូបលើសពីអ្នកដែលមិនជាប់ចោទ វាត្រូវបានសេចក្ដីថា ត្រូវតែតិចជាងហើយ វាត្រូវតែស្គៀកពាក់អន់ជាង ។ ហ្នឹងខ្ញុំសូមជម្រាបលោកចៅក្រមអ៊ីចឹង ។

**ស៖** និយាយពីម្ហូបអាហារនៅកន្លែងនោះលោក ម៉ម ណៃ តើលោកអាចប្រាប់យើងបានទេ អ្នកណាជាអ្នកទទួលបន្ទុកខាងដាំស្លឲ្យបុគ្គលិកនៅម-១៣ ឬក៏នៅស-២១?

**ឆ៖** សូមជម្រាបលោកចៅក្រម នៅម-១៣ គឺក្រោយមកក្រោយដែលគ្រួសារខ្ញុំទៅ គឺគ្រួសារខ្ញុំហើយនិងអ៊ំស្រី ណាក់ នៅនុ៎ង គឺដាំស្លនៅនុ៎ង ។ ឯនៅស-២១ គឺមកចុងៗឆ្នាំហើយ មិនដឹងជាចុងឆ្នាំណាទេ ក៏ប៉ុន្តែគឺថាមុនរត់យួននេះគ្រួសារខ្ញុំដោយសារសម្រាលកូនហើយមកនៅនែ៎អង្គភាពអគ្គិសនីនៅពេទ្យលោកសង្ឃនេះសម្រាកកូនបានតែបីបួនថ្ងៃគេប្រើឲ្យទៅច្រូតស្រូវ ។ ខ្ញុំឮក៏ខ្ញុំទៅសុំស្នើ មិត្តឌុចសុំយកគ្រួសារខ្ញុំមកនៅជាមួយ ។ មិត្តឌុច ក៏យល់ព្រមហើយខ្ញុំក៏យកពីពេទ្យលោកសង្ឃហ្នឹងមក ។ យកមកគ្រួសារខ្ញុំនៅ២១ ហ្នឹងក៏ទទួលភារកិច្ចដាំបាយឲ្យកងការពារ ឲ្យកម្មាភិបាលនៅស-២១ ហ្នឹងហូបទៅ ។

[១៤:២៩:៣២]

**ស៖** លោកបាននិយាយអំពីលក្ខខណ្ឌដែលមិនល្អ តើលោកនៅចាំទេនូវហេតុការណ៍មួយ តើលោកចាំអំពីហេតុការណ៍ទឹកជំនន់ធំមួយនៅម-១៣ ដោយសារមានភ្លៀងខ្លាំងពេក ។ តើលោកចាំទេអំពីហេតុការណ៍នោះ?

**ឆ៖** សូមជម្រាបលោកចៅក្រម! នៅពេលដែលអ្នកស៊ើបសង្កេតទៅសួរខ្ញុំ បានលើកបញ្ហានេះ។ ខ្ញុំបាននឹកឃើញ នៅពេលដែលទឹកឡើង ទឹកស្ទឹងក្រាំងពន្លឺឡើង ។ ឡើងខ្លាំងមែនទែន ខ្ញុំក៏ទៅអើតប្រពន្ធខ្ញុំហើយនិងកូនខ្ញុំ ។ ទៅបានប្រហែលថាមួយរយម៉ែត្រចុះ ពីកន្លែងឃុំឃាំងហ្នឹងទឹកឡើងត្រឹមចង្កេះខ្ញុំ

ហើយ ។ ដល់ខ្ញុំទៅដល់ប្រពន្ធខ្ញុំ ទឹកហ្នឹងវាឡើងជិតលេចដំបូកហើយ នៅលើដំបូកហ្នឹងមានប្រពន្ធខ្ញុំ មានកូនខ្ញុំ ហើយមានយាយនិងតាមួយដែលខ្ញុំហៅថាអ៊ំនុំងនៅលើត្បូកទុំង ខ្ញុំក៏ជាប់គាំងនៅនុំងទៅ ។ ឯមិត្តម្នាក់ទៀត នៅនឹងចង្ក្រានបាយគេឡើងលើដំបូលផ្ទះហ្នឹងទៅ ដូច្នេះទឹកកាលនុំង វាជន់ខ្លាំងណាស់ ។ ហើយដល់ខ្ញុំដឹង គឺៗត្រូវជ្រូកចិញ្ចឹមត្រូវងាប់ ។ ឯមនុស្សងាប់ ខ្ញុំក្តាប់មិនបានទេ ។

**សះ** តាមពិតនៅ D22.14 នៅក្នុងអត្ថបទភាសាបារាំង ។ សំណួរគេបានសួរទៅលោកថា តើអ្នកទោសជាអ្នកកម្មាភិបាលប៉ុនណា? ដែលប៉ុន្មាននាក់? នៅក្នុងទឹកជំនន់នោះ លោកបានឆ្លើយថា ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែថា ជ្រូកបានស្លាប់នៅក្នុងទឹកជំនន់នោះពេលមានទឹកជំនន់ ។ តើលោកៗមានឱកាសក្នុងការបានជួបអ្នក-- ជួបជនជាប់ចោទជាញឹកញាប់ណាស់នៅម-១៣។ ជាពិសេសនៅពេលចុងបញ្ចប់នៃកន្លែងនោះ ហើយនៅពេលចាប់ផ្តើមរំដោះ ។ តើលោកមានឱកាសពិភាក្សា ឬក៏សន្ទនាជាមួយគាត់ទេ? តើលោកបាននិយាយពីបញ្ហាផ្ទាល់ខ្លួនទេ? តើលោកសង្កេតឃើញថាតើគាត់មានអារម្មណ៍ថា តានតឹង ឬក៏បានជួបគ្នាដែរឬទេ?

**ឆះ** សូមអត់ទោស លោកចៅក្រម ខ្ញុំមិនយល់សំណួរលោកចៅក្រមទេ ។ សូមលោកចៅក្រមសួរម្តងទៀត ។

**សះ** សូមអភ័យទោសដោយសារតែសំណួរខ្ញុំហាក់ដូចជាវែងបន្តិច ។ នៅពេលដែលលោកនៅម-១៣ មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ តើលោកមានដែលធ្លាប់និយាយសន្ទនាពិភាក្សាជាមួយនឹងជនជាប់ចោទដែរឬទេ? ឬក៏លោកធ្លាប់មានឱកាសកត់សម្គាល់ឃើញថា ជនជាប់ចោទនោះមានអារម្មណ៍តានតឹង ឬក៏មិនសប្បាយចិត្តនូវអ្វីនិងទាក់ទងទៅនឹងការងារដែលគាត់ធ្វើនៅម-១៣ តើលោកគាត់មានអារម្មណ៍អាក់អន់ស្រពន់ចិត្តទេ ចំពោះការងារដែលគាត់ធ្វើ?

**ឆះ** សូមជម្រាបលោកចៅក្រម! នៅមុនរំដោះខ្ញុំហើយនិងមិត្តឌុច មិនបានពិភាក្សាគ្នារឿងអីទេ ។ ហើយខ្ញុំក៏មិនបានសង្កេតគាត់ដែរ ព្រោះពេលនោះ ខ្ញុំវាចាប់ចិត្តទៅលើការដាំដំណាំគឺដាំដំឡូងគ ។ ខ្ញុំពេញចិត្តនឹងការដាំដល់ផលអ៊ីចឹង ខ្ញុំក៏គ្មានពេលនឹងមើលនែ៎ សង្កេតមើលគាត់ដែរ ដឹងគាត់យ៉ាងម៉េចខ្ញុំមិនដឹងដែរ ហើយក៏មិនដែលពិគ្រោះពិភាក្សាគ្នាពីរឿងអីផ្សេងដែរ ។

[១៤:៣៤:៥៥]

**សះ** ថាតើជនជាប់ចោទមានជំនឿទៅលើលោក ហើយគាត់ប្រាប់រឿងរ៉ាវលាក់លៀមមួយចំនួនហើយគាត់ដាក់ឲ្យលោកធ្វើការងារមួយចំនួនទាក់ទងនឹងបញ្ហាសន្តិសុខដែរឬទេ?

**ឆ៖** ដូចជាគាត់គ្មានជំនឿអីខ្លាំងក្លាមកលើខ្ញុំទេ ហើយដូចគ្មានដាក់ការងារអីធំដុំដែរ គ្រាន់តែមានការសួរចម្លើយ ជនដែលយល់ថាជាអ្នកមិនសូវសំខាន់ប៉ុណ្ណឹងទេ ។

**សៈ** នៅពេលនេះ យើងចូលនិយាយអំពីស-២១ ។ លោកមានឱកាសធ្វើការជាមួយនឹងបុគ្គលមួយឈ្មោះ ណាត ។ តើលោកអាចជម្រាបយើងទេ អំពី ណាត នុ៎ង?

**ឆ៖** ចំពោះ ណាត ទើបតែនឹងស្គាល់គ្នានៅក្រោយរំដោះនេះទេ ។ ហើយខ្ញុំក៏ក្តាប់មិនបានបុគ្គលិកលក្ខណៈគាត់អីទេ គ្រាន់តែដឹងថា គាត់ជា-- កាលមុនជាប្រធានកងពល ។

**សៈ** នៅពេលដែលលោកស្គាល់-- ចាប់ផ្តើមស្គាល់ ណាត ។ តើគាត់នុ៎ង ជាប្រធានមន្ទីរស-២១ទេ នៅពេលដែលលោកចាប់ស្គាល់គាត់នោះ?

**ឆ៖** ចាប់ផ្តើមស្គាល់ក្រោយយើងរំដោះហើយ គឺថាស្គាល់ជាប្រធានកងពលធម្មតា ។ ហើយក្រោយមកទៀតបានត្រូវខាងលើចាត់តាំងគាត់ជាប្រធានស-២១ ប៉ុណ្ណឹង ។

**សៈ** តើលោកអាចកត់សម្គាល់ឃើញភាពលំបាកលំបិនមួយចំនួនរវាង ណាត និងជនជាប់ចោទដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំមិនបានយកចិត្តទុកដាក់ពីបញ្ហាអស់នេះទេ ។

**សៈ** តើលោកបានដឹងទេ ហេតុអ្វីបានជាណាត នេះគាត់លាលែងពីតួនាទីរបស់គាត់នៅស-២១?

**ឆ៖** សូមជម្រាបលោកចៅក្រម! ខ្ញុំមិនបានដឹងអីទាំងអស់ទេ ។

**សៈ** នៅពេលដែល ណាត ជាប្រធានស-២១ តើលោកទទួលបន្ទុកសួរចម្លើយអ្នកទោសដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ខ្ញុំនៅតែជាកម្មាភិបាលសួរចម្លើយជនមិនសំខាន់ ។

**សៈ** តើលោកចាំទេថានៅពេល ណាត នៅស-២១ នៅពេលនោះលោកបានស្នើសុំឲ្យមានការដោះលែងអ្នកទោសមួយចំនួន?

[១៤:៣៩:២៦]

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ខ្ញុំមិនចងចាំទេ នឹកមិនឃើញទេ ។

**សៈ** ប្រហែលជាយើងអាចធ្វើបញ្ចាំងនៅលើអេក្រង់នេះ នូវឯកសារមួយដែលឯកសារនេះនៅមាននៅក្នុងសំណុំរឿង E5/2.8 ជាពិសេសនោះ គឺយើងចង់បញ្ចាំងទំព័រដែលមានលេខ ERN0022 6566 ហើយនិងទំព័រលេខ 00226567 ។

ខ្ញុំចង់បញ្ជាក់ថា គឺមានសេចក្តីសង្ខេបនៃចម្លើយនេះដែលខ្ញុំសុំអានដែលវាជាភាសាអង់គ្លេស ហើយវាមានលេខ Index E5/2.8 គឺមានលេខ ERN00283986 ។ នេះគឺលេខទំព័រលេខ00226566 តើលោកស្គាល់នូវសំណេរនេះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបចៅក្រមថា អក្សរនេះប្រហាក់ប្រហែលនឹងអក្សរខ្ញុំដែរ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

នេះគឺជាឯកសារសង្ខេបបកប្រែជាភាសាមក ដែលមានជាភាសាអង់គ្លេសផងដែរ ។ ចាន់ គឺទាក់ទងទៅនឹងចាន់ ។

*(អ្នកបកប្រែ៖ សូមអភ័យទោស អ្នកបកប្រែស្តាប់អត់ឮពីអ្វីដែលលោកចៅក្រមបានលើកឡើង)*

ដូច្នេះ យើងបានទទួលការពន្យល់ពីជនជាប់ចោទហើយ ទាក់ទងទៅនឹងឯកសារនេះ ។ ជនជាប់ចោទ គាត់បានលើកឡើងជូនយើងខ្ញុំ ហើយសុំឲ្យគាត់កែខ្ញុំ ប្រសិនខ្ញុំលើកឡើងខុស ។ នៅពេលដែលគេប្រើពាក្យ “ដោះលែង” នោះ គឺវាមានន័យថា វាគ្រាន់តែនិយាយថា វាបញ្ជាក្លែងក្លាយតែប៉ុណ្ណោះ បានន័យថា បុគ្គលនឹងត្រូវគេយកទៅសម្លាប់ចោល ហើយអ្នកដែលត្រូវគេដោះលែងនោះគឺបានន័យថា នៅពេលដែលយើងប្រើពាក្យ “ដោះលែង” បានន័យថា នឹងសម្លាប់ ។ ហើយជនជាប់ចោទ បានពន្យល់ថា ចំណុចនេះ គឺជាការអនុវត្តមួយដែលបានបង្កើតឡើងដោយ ណាត ដើម្បីធ្វើការលាក់កំបាំងពីថ្នាក់លើចំពោះការសម្លាប់បុគ្គលមួយចំនួន ដែលគាត់បានស្តាប់តាមសេចក្តីសម្រេចផ្ទាល់របស់គាត់ ។

ដូច្នេះ តើចំណុចនេះវាស៊ីគ្នាទៅនឹងអ្វីដែលលោកឡើងដែរឬទេ? លោក កាំង ហ្គេកអ៊ាវ ឬក៏ខ្ញុំនិយាយខុសទៅលើចំណុចនេះ?

[១៤:៤៥:០៨]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម! ពាក្យដោះលែងនេះ ជាពាក្យប្រឌិតរបស់ ណាត នៅក្នុងករណីដែល ណាត ចាប់មនុស្សតាមចិត្តគាត់ ។ ដល់គាត់ភ័យខ្លាចបែកការណ៍ដល់ខាងលើ គាត់ប្រើឧបាយកលនេះដើម្បីលុបដាន ។ ដូច្នេះ ជាឧបាយកលរបស់គាត់ ឯចំណែកអ្នកសរសេរជាស្មៀនដូចយ៉ាងបង ម៉ម ណៃ ស្មៀនគេឲ្យធ្វើអីធ្វើប៉ុណ្ណឹង នេះជាពាក្យពន្យល់របស់ខ្ញុំកាលពីមុន ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក ម៉ម ណៃ ពាក្យថាដោះលែងនេះបានន័យថា នៅរស់ ឬក៏យ៉ាងម៉េច? ការសរសេរដូច្នេះ ដើម្បីបង្ហាញអំពីការលាក់បាំង ឬក៏ជាបញ្ហាការធ្វើជាការវិធីមួយដើម្បីក្លែងក្លាយ ឬក៏យ៉ាងម៉េច?

**ឆ៖** សូមជម្រាបលោកចៅក្រម! គឺថា ខ្ញុំជាអ្នកមិនភារកិច្ចអីធំដំទេ ដូច មិត្តឌុច និយាយអំមិញ អ៊ីចឹងថា ដល់ពេលគេប្រើខ្ញុំឲ្យសរសេរពាក្យ ហើយសុំដោះលែង ខ្ញុំដឹងតែថា ខ្ញុំមិនយល់ដូចមិត្តឌុច គាត់ជាអ្នកគ្រប់គ្រងបន្ទាប់ពី ណាត ទេ ។ ខ្ញុំទាល់តែគេប្រើខ្ញុំឲ្យសរសេរសុំដោះលែង អាហ្នឹងសុំដោះលែង ខ្ញុំដឹងតែថា ដោះលែង ត្រង់ថាគេយកទៅណា អាហ្នឹងខ្ញុំអត់ដឹង ។ ពីព្រោះខ្ញុំមានភារកិច្ចប៉ុណ្ណឹងនៅក្រោមគេ គេប្រាប់ថា ឥឡូវសរសេរសុំដោះលែងមក អាហ្នឹងខ្ញុំសរសេរហើយ ។ ហើយដូច ខ្ញុំជម្រាបលោកចៅក្រមអំមិញហើយ ខ្ញុំខំមើលអក្សរហ្នឹង មុនដំបូងខ្ញុំជម្រាបលោកចៅក្រមថា ប្រហាក់ប្រហែល ខ្ញុំចេះតែផ្ទៀងមើល រកមើលទៅបានថា វាជាអក្សរខ្ញុំមែន ។ ដូច្នេះ គឺកាលខ្ញុំសរសេរនោះ គឺខ្ញុំនៅទាបជាងគេ អត់ដឹងការល្បិចរាក់ជ្រៅរបស់គេ គេប្រាប់ថា សុំសរសេរដោះលែងមក ខ្ញុំសុំសរសេរដោះលែងតាមហ្នឹងទៅ គេថាឲ្យដោះលែងឈ្មោះណាៗគេប្រាប់ ខ្ញុំសរសេរអ៊ីចឹងទៅ ពីព្រោះខ្ញុំនៅក្រោមគេ ។ អ៊ីចឹងសូមលោកចៅក្រមជ្រាប ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមានសំណួរមួយទៀត ប៉ុន្តែ ខ្ញុំជឿថា នៅពេលនេះគឺជាពេលដែលយើងអាចសម្រាកមួយភ្លែតសិន ។

**ប្រធានអង្គជំនុំ៖**

ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំបីនាទីរហូតដល់ម៉ោងបីនិងប្រាំនាទី សូមអញ្ជើញចូលមកវិញ ដើម្បីបន្តកិច្ចពិភាក្សាដេញដោល ។ ហើយមន្ត្រីតុលាការសម្របសម្រួលដល់សាក្សី ដើម្បីឲ្យបានទទួលនូវកន្លែងសម្រាកសមរម្យផង ។

*[សវនាការសម្រាកពីម៉ោង ១៤:៥០នាទីដល់ម៉ោង ១៥:០៧នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តនីតិវិធីពិភាក្សាដេញដោលតទៅទៀត ហើយអម្បាញ់មិញនេះលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ នៅមានសំណួរចំពោះសាក្សីរូបនេះទៀត ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោក ម៉ម ណៃ តើជារឿយៗ គេស្នើសុំឱ្យលោកសរសេរពាក្យថា ស្នើសុំដោះលែងដែរឬទេ?

**ឆ៖** សូមជម្រាបលោកចៅក្រម! ខ្ញុំចាំមិនច្បាស់ទេ ។

**ស៖** តើនរណាគេស្នើសុំឱ្យលោកសរសេរចំណារបែបនោះ? តើជាជនជាប់ចោទ? ឬក៏ ណាត?

**ឆ៖** តាមយល់ គឺថាមានតែប្រធាន គឺ ណាត ទេ ដែលឱ្យសរសេរសុំដោះលែងហ្នឹង ។

**ស៖** ខ្ញុំមិនមែនសួរថា តើលោកយល់ ឬក៏លោកមិនយល់នោះទេ ថាតើលោកចាំដែរឬទេ?

**ឆ៖** សូមជម្រាបលោកចៅក្រម! ខ្ញុំមិនចាំទេ ក៏ប៉ុន្តែបើកាលនោះ បើថា ណាត ធ្វើប្រធាន គឺមានតែ ណាត ហ្នឹងហើយ ។

**ស៖** នៅក្នុងទំនាក់ទំនងលោកជាមួយនឹង ឌុច លោកបានលើកឡើងថា គាត់មិនជឿលោកជានិច្ចនោះទេ ។ តើលោកដឹងដែរឬទេ ថា ឌុច បានរាយការណ៍ទៅថ្នាក់របស់គាត់ក្នុងនាមលោក?

**ឆ៖** ត្រង់នេះក៏ខ្ញុំមិនយល់ពីសំណួររបស់លោកចៅក្រមដែរ សូមលោកចៅក្រមអភ័យទោស ហើយសូមសួរខ្ញុំម្តងទៀត ។

**ស៖** ណាត គឺជាប្រធានស-២១ នៅពេលដែលចាប់ផ្តើមមន្ទីរនេះ បន្ទាប់មកជនជាប់ចោទបានជំនួស ណាត គឺ ឌុច នេះបានជំនួស ណាត ។ ឌុច ធ្វើការទាក់ទងជាមួយនឹងថ្នាក់លើ តើលោកបានដឹងដែរឬទេ ថា ឌុច ដែលជាជនជាប់ចោទនៅទីនេះបានរាយការណ៍ទាក់ទងទៅនឹងអាកប្បកិរិយារបស់លោក ហើយគាត់ដាក់ជូនរបាយការណ៍នោះទៅថ្នាក់លើ?

**ឆ៖** ខ្ញុំនៅតែមិនយល់អំពីសំណួររបស់លោក តើលោកចង់សួរថា មិត្តឌុច រាយការណ៍ពីអាកប្បកិរិយាខ្ញុំ ឬយ៉ាងម៉េច?

[១៥:១១:៣៩]

**ស៖** គឺខ្ញុំនិយាយអ៊ីចឹងមែន ។

**ឆ៖** សូមជម្រាបលោក ថ្ងៃមួយមានខ្មាំងដែលថាខ្មាំងនៅវរសេនាធំនៅកងពល១៧០ នោះឈ្មោះ ផាន នោះ តាមមិត្តឌុច ប្រាប់ខ្ញុំ គឺថា ផាន ហ្នឹងឆ្លើយដាក់ខ្ញុំ ថាខ្ញុំហ្នឹងធ្លាប់ទៅលេងផ្ទះពូវា ។ ហើយសូមជម្រាបលោកឱ្យវែងបន្តិចចុះ ពូវាហ្នឹង គឺវាពួកម៉ាកខ្ញុំតាំងតែពីនៅរៀន ពីថ្នាក់ប្រាំមួយរហូតដល់ទៅចេញធ្វើគ្រូទាំងអស់គ្នា ។ ហើយពូវាហ្នឹង មុននឹងឈ្មោះ លី ផែន ហ្នឹងចូលធ្វើបដិវត្តន៍

ត្រូវកាសែតចោទថាជាខ្មែរសេរី ។ ហើយដល់អ៊ីចឹងទៅខ្ញុំក៏ជម្រាបទៅមិត្ត ឌុច ថា បើមិនទុកចិត្តខ្ញុំ អាហ្នឹងចាប់ខ្ញុំទៅ ហើយបានបន្តិចក្រោយមកស្រាប់មិត្ត ឌុច គាត់ប្រាប់ខ្ញុំថា គាត់បានរាយការណ៍ទៅខាងលើហើយ ។ ហើយខាងលើបានឆ្លើយតបមកវិញ ឆ្លើយតបមកវិញថា ខ្ញុំជាអ្នកចេះ ខ្ញុំនិយាយអីជឿគាត់ទៅ ។ អាហ្នឹង គឺ-- ហើយតាំងពីនោះមក មិត្តឌុច ក៏អត់មាននិយាយអីពីខ្ញុំទៀត ក៏ប៉ុន្តែតាមខ្ញុំសង្កេតឃើញថា ប្រហែលជាគាត់មិនទុកចិត្តខ្ញុំ ។ ក្រោយមកស្រាប់តែឲ្យខ្ញុំឈប់សួរចម្លើយទៅ ។

នេះខ្ញុំសូមជម្រាបលោកឲ្យវែងបន្តិច អានេះតាមខ្ញុំយល់ទេ មិនមែនខ្ញុំដឹងថា តើគាត់ទុកចិត្ត ឬមិនទុក តែខ្ញុំសង្កេតអ៊ីចឹង ។ ខ្ញុំថាគាត់ប្រហែលជាមិនសូវទុកចិត្តខ្ញុំហើយ បានដកខ្ញុំឲ្យឈប់សួរចម្លើយទៅ ។

**ស៖** ចាតើឧប្បត្តិហេតុ និងហេតុការណ៍នេះកើតឡើងនៅពេលណា? នៅពេលដំបូងដែលមន្ទីរនេះចាប់ផ្តើម ឬក៏នៅចុងបញ្ចប់នៃមន្ទីរនេះ?

**ឆ៖** ខ្ញុំបញ្ហាហ្នឹង ក៏ខ្ញុំភ្លេច-- ខ្ញុំចាំមិន ថ្ងៃខែក៏មិនច្បាស់ ប្រហែលនៅមុនពាក់កណ្តាលរយៈកាលនោះក៏មិនដឹង ។ បញ្ហាហ្នឹងខ្ញុំភ្លេចមិនបានច្បាស់ទេ ខ្ញុំគ្រាន់តែដឹងពីសភាពការណ៍អ៊ីចឹង ។ សូមលោកចៅក្រមជ្រាប ។

**ស៖** ចាតើវាកើតឡើងមុនពេលដែល ឌុច ចាត់តាំងលោកឲ្យសួរអ្នកជាប់ឃុំវៀតណាម ឬក៏វាកើតឡើងបន្ទាប់ពីពេលដែលគាត់ចាត់តាំងលោក?

**ឆ៖** មុនពេលខ្ញុំសួរយួន គឺថាប្រហែលជានៅពេលគាត់ឡើងធ្វើជាប្រធានមន្ទីរពេញ ប្រធាន ស-២១ ហើយមើលទៅ ។

**ស៖** នៅក្នុងចម្លើយរបស់លោក ដែលបានឆ្លើយមុខអ្នកស៊ើបអង្កេត ហើយនៅពេលដែលសួរតទល់គ្នា ដែលមានលេខឯកសារ D54 នៅក្នុងកំណត់ហេតុ ។ លោកបានលើកឡើងចំណុចមួយចំនួនខ្ញុំនិយាយអំពីទំព័រ៩ នៃឯកសារបារាំង ។ លោកបានលើកឡើងថា នៅក្នុងស-២១ ការទាក់ទងសន្ទនាតាមទូរស័ព្ទត្រូវបានគេថតទុក ពីព្រោះមានការភ័យខ្លាចថា បុគ្គលទាំងឡាយទាក់ទងបុគ្គលផ្សេងទៀតទាក់ទងទៅនឹងបញ្ហាធ្ងន់ធ្ងរ ។ ហើយលោកបានលើកឡើងថា ឌុច បានប្រាប់លោកអំពីការអនុវត្តថតដូច្នេះ ហើយ ឌុច បានពន្យល់ប្រាប់លោកថា គោលបំណង គឺដើម្បីរាំងអ្នកសួរចម្លើយមិនឲ្យទាក់ទងគ្នា ។ ហើយលោកក៏បានលើកឡើងផងដែរថា ទូរស័ព្ទនោះ គឺនៅជិតកន្លែងដែល ហ៊ីម ហ៊ុយ ធ្លាប់ធ្វើការងារ ។ តើលោកនៅចាំចំណុចលើកឡើងដូច្នេះដែរឬទេលោក?

[១៥:១៦:៥៩]

**ឆ៖** សូមជម្រាបលោកចៅក្រម!គឺបញ្ហាចំណុចនេះខ្ញុំនៅចាំ ដូចលោកចៅក្រមបានអានចម្លើយដែលខ្ញុំនិយាយជម្រាបលោកចៅក្រមស៊ើបអង្កេត កាលពីតទល់គ្នានុំងមែន ។

**ស៖** តើវាមានន័យថា ឌុច តាមដាននូវអ្វីដែលបានគេបាននិយាយគ្នា ហើយគាត់មិនជឿទុកចិត្តលើអ្នកណាទាំងអស់?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! បញ្ហាទាំងនេះខ្ញុំវិភាគជំហាររបស់គាត់មិនបានត្រឹមត្រូវទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា គាត់រារាំងមិនឲ្យអ្នកសួរចម្លើយទាក់ទងគ្នា មានទិសដៅអ៊ីចឹង ។

**ស៖** ដូច្នេះ ឌុច បានដាក់ចេញក្រឹត្យក្រមដូច្នេះ ដែលថាមិនឲ្យអ្នកសួរចម្លើយនិយាយគ្នា ។ តើលោកបញ្ជាក់ទៅលើចំណុចនេះដែរឬទេ?

**ឆ៖** សូមជម្រាបលោកចៅក្រម គឺថាតាមគាត់ប្រាប់ខ្ញុំ គឺដើម្បីក្តាប់ការឆ្លងឆ្លើយពីអ្នកសួរចម្លើយ ក្នុងទិសដៅ គឺរារាំងមិនឲ្យអ្នកសួរចម្លើយនិយាយគ្នា ឆ្លើយឆ្លងគ្នាបញ្ហាផ្សេងៗ ។

**ស៖** តើពេលខ្លះ ឌុច បានមកចូលរួមការសួរចម្លើយ ដែលលោកសួរដែរឬទេ? ថាតើ ឌុច នេះគាត់ធ្វើការតាមដាន និងត្រួតពិនិត្យទៅលើការសួរចម្លើយនៅពេលដែលមានការសួរចម្លើយរបស់អ្នកសួរចម្លើយដែរឬទេ?

[១៥:២០:០០]

**ឆ៖** ចំពោះបញ្ហានេះសូមលោកចៅក្រមជ្រាប! ខ្ញុំសួរចម្លើយ មិត្ត ឌុច មិនដែលមកចូលកន្លែងខ្ញុំដើម្បីពិនិត្យអីនោះទេ ហើយចំពោះអ្នកដទៃទៀត ក៏ខ្ញុំក្តាប់មិនបានថា តើគាត់ទៅឬមិនទៅ? អាហ្នឹងខ្ញុំមិនដឹងដែរ ។

**ស៖** លោក ស៊ឹម សុរិយ៉ា បានសួរ និងសម្ភាសលោក និងលោកស្រី ហ្វាប៊ីយៀន លូកូ ក៏បានសម្ភាសលោក ដែលជាអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក នេះ គឺមាននៅក្នុងឯកសារ D54/2 នៅក្នុងទំព័រទី៤ នៃកំណត់ហេតុនេះ ។ នេះ គឺអ្វីដែលគាត់លើកឡើង “នៅពេលដែលខ្ញុំសួរចម្លើយ ពេលខ្លះ ឌុច មកមើលខ្ញុំផងដែរ” ។ អ៊ីចឹងចំណុចនេះវាមានន័យយ៉ាងម៉េច?

**ឆ៖** តាមខ្ញុំចាំ គឺថានៅពេលសួរយួន ខ្ញុំមិនដែលឃើញគាត់មកទេ ក៏ប៉ុន្តែ បើថាពេលសួរខ្មែរក្រែងខ្ញុំភ្លេចមិនដឹង ។

**ស៖** ក្រៅពីការសួរចម្លើយ តើលោកមានភារកិច្ចផ្សេងទៀតដែរឬទេ? បានន័យថា តើលោកបានធ្លាប់ជួយក្នុងការទទួលអ្នកទោសដែលបញ្ជូនមកស-២១ ដែរឬទេ? តើលោកចង់ឱ្យខ្ញុំធ្វើការសួរសំណួរនេះឡើងវិញ ឬក៏លោកអត់បានស្ដាប់ឮសំណួរនេះទេ ។

**ឆ៖** ខ្ញុំស្ដាប់បាន សូមជម្រាបលោកចៅក្រម! គឺខ្ញុំមិនដែលបានទទួលអ្នកទោសឯណាទេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រហែលជាវាអាចមានលទ្ធភាពមួយដើម្បីនឹងដាក់បញ្ចាំងឯកសារមួយដែលឯកសារដែរចុះលេខ D57 ឧបសម្ព័ន្ធ 105 ERN លេខជាភាសាបារាំង គឺ 00333262 ហើយ ERN លើភាសាខ្មែរ គឺ 00088706 រហូតទៅដល់ 00088708 ។ សូមឱ្យខាងសោតទស្សន៍បង្ហាញឯកសារនេះជាភាសាខ្មែរនៅលើអេក្រង់ ។ ប្រហែលជាយើងអាចបង្វិលទៅខាងក្រោមនៃឯកសារ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើនេះជាឯកសារដែលលោកបានចេញ ឬក៏លោកបានរៀបចំ ដែលជាឯកសារដែលលោកបានទទួលខុសត្រូវមែនទេពេលនោះ លោក ម៉ម ណៃ?

**ឆ៖** សូមជម្រាបលោកចៅក្រម! ខ្ញុំចាំមិនបានច្បាស់លាស់ទេ ពីព្រោះអីខ្ញុំមិនជាអ្នកយកចិត្តទុកដាក់ប៉ុន្មាន ហើយក៏គ្មានការប្រកាសចាត់តាំងអីស្រួលបួលដែរ ។

**ស៖** ប្រសិនបើការចងចាំរបស់លោកមិនសូវបានល្អទេ ខ្ញុំសង្កេតឃើញថា ឈ្មោះនៅខាងក្រោមនេះ គឺជាឈ្មោះហៅក្រៅរបស់លោក តើមែនទេ?

**ឆ៖** ប្រសិនជាឯកសារនេះសរសេរដៃ អាហ្នឹងខ្ញុំមើលស្គាល់អក្សរច្បាស់លាស់ ហើយនេះវ៉ៃពុម្ពអីចឹង គឺខ្ញុំឃើញឈ្មោះដាក់ឈ្មោះខ្ញុំ ក៏ប៉ុន្តែខ្ញុំរកនឹកមិនឃើញ តែប្រសិនបើមានអក្សរដៃមក ខ្ញុំអាចនឹកឃើញ ។ ឈ្មោះហ្នឹងប្រាកដជាឈ្មោះខ្ញុំហើយ ដាក់ ចាន់ ហ្នឹង អត់មានអ្នកណាផ្សេងទៀតទេ ។

[១៥:២៧:៣៤]

**ស៖** លោកគឺជាមនុស្សតែម្នាក់ដែលមានតួនាទីក្នុងការរៀបចំឯកសារបែបនេះ តើអីចឹងមែនទេ?

**ឆ៖** ខ្ញុំដូចជាគ្មានភារកិច្ចអីរៀបចំឯកសារអីចឹងទេ ពីព្រោះខ្ញុំនៅចាំថាខ្ញុំជាអ្នកសួរចម្លើយតែប៉ុណ្ណោះ ។ តែបើថានៅពេលគេប្រើប្រាស់ខ្ញុំឱ្យធ្វើអីផ្សេងទៀត អាហ្នឹងខ្ញុំចេះតែធ្វើតាមការគេបង្គាប់ទៅ ។ ហ្នឹងសូមជម្រាបលោកចៅក្រមអីចឹង ។ ខ្ញុំមិនច្បាស់លាស់ថា--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រហែលជាឯកសារមួយទៀត យើងនឹងត្រូវបង្ហាញលើឯកសារលេខ 0088733, 0088 733 បាទសូមឲ្យបង្ហាញនៅលើអេក្រង់ ។ *(សូមកែដោយអ្នកប្រែ គឺ 00088733 ។ អត្ថបទភាសាខ្មែរ ។)*

ខ្ញុំគិតថាខ្ញុំអាចមើលតែអត្ថបទដែលបកជាភាសាអង់គ្លេស ។ ខ្ញុំមិនដឹងថាមានព័ត៌មានអ្វីនៅខាងក្រោមនៃឯកសារនេះ ឬក៏នៅចុងនៃឯកសារនេះទេ ជាភាសាខ្មែរនោះ ។ ប្រហែលជាយើងអាចបង្វិលទៅខាងក្រោម ខាងចុងនៃឯកសារនេះ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** យើងក៏មានឯកសារដែលវាយអង្គុលីលេខដែរក្នុងឯកសារនេះ តើលោកនឹកឃើញអ្វីទេក្រោយពីបានឃើញឯកសារនេះ លោក ម៉ម ណៃ?

**ឆ៖** សូមជម្រាបលោកចៅក្រម ខ្ញុំនៅតែនឹកមិនឃើញ ក៏ប៉ុន្តែខ្ញុំឃើញថាឈ្មោះ គឺឈ្មោះខ្ញុំ ។ ខ្ញុំខំរកនឹកដែរ ប៉ុន្តែវានឹកមិនឃើញ វាមិនចេញ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ។

**លោក គង់ សំអុន៖**

ខ្ញុំមានយោបល់ពីរ ។ ទីមួយ គឺទាក់ទងទៅនឹងការបង្ហាញឯកសារផ្សេងៗកន្លងមកនេះ គឺថាការបង្ហាញ គឺមិនបានច្បាស់ឲ្យសាក្សីមើលឃើញទាំងអស់ទេ ។ ដូច្នេះ គ្រាន់តែឃើញតែឈ្មោះហ្នឹងមួយម៉ាត់ ឬក៏ថ្ងៃទីបន្តិចអ៊ីចឹង គាត់ក៏មិនអាចចាំបានថា តើជាអត្ថបទយ៉ាងម៉េចដែលកើតឡើងពិតប្រាកដជាមួយនឹងគាត់ ធ្លាប់បានធ្វើកន្លងមក ឬមួយណានោះ ក៏អត់ដឹងដែរ ។ បើសិនជាអាចត្រូវប្រគល់ឲ្យគាត់មើលបានទាំងអស់ឲ្យច្បាស់ ថាតើខ្លឹមសារហ្នឹងគាត់ធ្លាប់បានធ្វើទេ អាចទាញការចងចាំរបស់គាត់ ។ នេះជាចំណុចមួយដែលអាចធ្វើឲ្យគាត់ហ្នឹងធ្វើគាត់ហ្នឹងចងចាំបាន ឬរំឭកឡើងវិញបាន បើសិនរឿងសាមសិបសែសិបឆ្នាំទៅហើយ ហើយអាការសរសេរហ្នឹងវាជារឿងច្រើនទៅទៀត មិនមែនជារឿងអាធំៗមួយ ។ ដូច្នេះ ការចងចាំរបស់គាត់វាមិនអាចនៅបាន ជាពិសេសដោយសារគាត់ចាស់ជរាអ៊ីចេះទៀត យើងឃើញការចងចាំវាបាត់បង់ច្រើន ។

[១១:៣២:២៩]

ទីពីរ ខ្ញុំសូមជម្រាបជូនលោកប្រធានអំពីការបង្កើតសំណួរជាទូទៅខ្ញុំសូមជូនជាសំណូមពរ ថា

តើសមាជិកក្រុមប្រឹក្សាជំនុំជម្រះមានសិទ្ធិបង្កើតសំណួរគ្រប់បែបយ៉ាងទាំងអស់ ដាក់ទៅលើសាក្សី ឬមួយយ៉ាងណា? ឬមួយក៏មានកំណត់ថា សំណួរប្រភេទណាដែរមិនគួរសួរ ឬក៏យើងត្រូវបង្កើតជានីតិវិធីដើម្បីកំណត់ជាបញ្ញត្តិថា សំណួរឧទាហរណ៍ថា ជាសំណួរនាំមុខមិនគួរសួរ ឬក៏សំណួរសួរផ្តាញ់សាក្សីមិនគួរសួរ ។ ពីព្រោះបើសិនជាលោកចៅក្រមគ្រប់រូបសួរមកសាក្សីទាំងអស់ អ៊ីចឹងវាមានបញ្ហាដល់លើកក្រោយទៀតថា ខាងព្រះរាជអាជ្ញា ឬខាងលោកមេធាវីការពារ គាត់នឹងត្រូវសួរយ៉ាងម៉េចទៅលើនេះ ហើយអាចសួរនូវប្រភេទសំណួរដដែលៗច្រើនទៀត ។

ម្យ៉ាងទៀត ខ្ញុំឃើញលោកចៅក្រមដែលសួរកន្លង ក៏មានសំណួរជាន់គ្នាដដែលច្រើនសាច្រើនលើកដែរ ។ អ៊ីចឹងជាសំណូមពររបស់ខ្ញុំ បើអាចធ្វើទៅបាន គួរតែផ្អាកសវនាការនេះសិន ហើយសូមលោកចៅក្រមពិនិត្យទៅលើទម្រង់នៃការបង្កើតសំណួរវិញ ថាតើក្រុមប្រឹក្សាជំនុំជម្រះគួរបង្កើតសំណួរបែបណា ហើយមេធាវី និងព្រះរាជអាជ្ញាអាចមានសិទ្ធិបង្កើតសំណួរបែបណា ដើម្បីខ្ញុំមានលទ្ធភាពថាសំណួរបែបណាដែលខ្ញុំអាចបដិសេធ ។ បើសិនជាសំណួរណាក៏សួរបានៗ វាធ្វើឲ្យសក្សីវង្វេងវង្វាន់មិនអាចគ្រប់គ្រងស្ថានភាពបានទេ ។ ហើយបើយើងគិតថា ដូចជា ការសួរសំណួរតាមប្រភេទសវនាការមួយដែលៗជា យើងហៅថាជា *អែតវើសសើរៀល* ឬក៏ *អ៊ីនគ្រិស៊ីតារៀល ស៊ីសស្ទែម* អាហ្នឹងយើងត្រូវកំណត់ឲ្យច្បាស់ថា ទៅតាមប្រភេទណាមួយឲ្យដាក់ដោយឡែកទៅ ដើម្បីឲ្យយើងយោង ងាយយោងប្រព័ន្ធណាមួយយកមកអនុវត្ត ។

បើសិនជាលោកចៅក្រមសួរច្រើនពេក អ៊ីចឹងវាធ្វើឲ្យប៉ះពាល់ដល់ខាងព្រះរាជអាជ្ញា ឬខាងការពារផងដែរ ។ ហើយក៏ប៉ះពាល់ដល់សាក្សីទៀត ពីព្រោះសាក្សីអាចមានលទ្ធភាពដែលត្រូវចោទប្រកាន់លើកក្រោយ ។ អ៊ីចឹង ធ្វើឲ្យការបង្ហាញអំពីការដាក់បន្ទុកលើខ្លួនឯងហ្នឹង ហ្នឹងអាចកើតមានឡើង ។

សូមអរគុណ ។

[១៥:៣៥:០០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ។ បញ្ហាទីមួយដែលលោកបានធ្វើការកត់សម្គាល់នេះ ខ្ញុំយល់ថា ជាការសមរម្យមួយដែលឯកសារនានាដែលត្រូវបង្ហាញជូនគាត់គឺត្រូវលាតត្រដាងនូវឯកសារទាំងមូលដើម្បីឲ្យគាត់ពិនិត្យនៅលើទម្រង់និងខ្លឹមសារនៃលិខិតនោះឲ្យបានច្បាស់លាស់មុននឹងឆ្លើយសំណួរ ឃើញថាការកត់សម្គាល់នេះសមរម្យត្រឹមត្រូវ ហើយគួរតែត្រូវបានអនុវត្តដូច្នេះ ។

ដោយឡែក បញ្ហាទីពីរដែលលោកបានធ្វើការកត់សម្គាល់អំពីទម្រង់នៃការបង្កើតសំណួររបស់អង្គជំនុំជម្រះ ខ្ញុំសូមជម្រាបលោកមេធាវីថា តាមប្រព័ន្ធដែលយើងអនុវត្តនេះគឺអនុវត្តតាមនីតិវិធីនៅកម្ពុជាដែលមានប្រភពឬក៏លំនាំតាមបែបច្បាប់បារាំងនោះគឺយើងប្រើភាសាថា នីតិវិធីប្រព្រឹត្តទៅតាមបែបស៊ីវិលឡ ។ ដូច្នេះ តួនាទីក្នុងការតាំងសំណួរ ល្អិតល្អន់ជាមុខងាររបស់អង្គជំនុំជម្រះគ្រប់មនុស្សដែលត្រូវកោះហៅមកសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ។ ដោយឡែក ភាគីដទៃទៀតគឺមានសិទ្ធិសួរដូចគ្នាដែរនូវសំណួរឯណាដែលអង្គជំនុំជម្រះមិនបានសួរ ។ ដោយឡែក ប្រភេទសំណួរដែលបានហាមប្រាមនោះគឺអង្គជំនុំជម្រះបានរំឭកដល់ភាគី ញឹកញាប់ហើយ ដូចជាសំណួរដឹកមុខ សំណួរច្រំដែលសំណួរក្រៅអង្គហេតុ សំណួរបែបឧបមាននិទី សំណួរឲ្យជនជាប់ចោទ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានជាដើម ។ ជាពិសេសគឺអ្នកជំនាញ និងសាក្សីឲ្យធ្វើសេចក្តីសន្និដ្ឋាននោះគឺបានកំណត់រួចហើយ ប្រហែលជាលោកមេធាវីពីមុនមិនបានចូលរួមអាចមានការភាន់ច្រឡំ ។

ហើយបញ្ហាមួយទៀតខ្ញុំសូមបំភ្លឺថា ការកត់សម្គាល់របស់លោក មេធាវីប្រហែលជាអាចមានខ្ញុំក៏បានកត់សម្គាល់បញ្ហានេះដែរ ។ ប៉ុន្តែការកំណត់ថា ឲ្យបានច្បាស់លាស់មួយភាគរយ នូវការគ្រប់គ្រងសវនាការដ៏ធំនូវអង្គហេតុដែលកើតឡើង បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ទៅលើជនរងគ្រោះជាច្រើន ហើយមានទាក់ទងទៅនឹងឥទ្ធិពលនយោបាយ ហើយនិងជម្លោះប្រដាប់អាវុធផងនោះ អាចមានបញ្ហាការគ្រប់គ្រងប្រហែលជាមានការខ្វះចន្លោះខ្លះ ប្រសិនបើអង្គជំនុំជម្រះបានយល់និងបានចងចាំក្តាប់បាននោះ គឺយើងបានធ្វើការជំទាស់មិនឲ្យសួរ ឬក៏មិនឲ្យសាក្សី ឬក៏អ្នកជំនាញ ឬក៏កន្លងមកទាំងជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីផងមិនឲ្យឆ្លើយតបនឹងសំណួរណាដែលមិនត្រឹមត្រូវដែលយើងមិនអនុញ្ញាតឲ្យធ្វើការសួរនៅក្នុងដំណើរការនីតិវិធីដេញដោលនេះទេ ។

ដូច្នេះ អាចមានលក្ខខណ្ឌខុសគ្នា បញ្ហាអស់នេះយើងបានជជែកពិភាក្សានៅក្នុងកិច្ចប្រជុំត្រៀមរៀបចំសវនាការ យើងប្រើគោលការណ៍ជាក់លាក់រួចហើយនៃប្រវត្តិ ឬក៏ប្រពៃណីនៃការអនុវត្តច្បាប់នៅក្នុងស្រុកកម្ពុជា នៅប្រទេសយើង ដែលយើងប្រើថា តុលាការនេះគឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នេះជាគោលការណ៍ដែលយើងបានចាត់ចែង ។ ហើយដោយឡែកយើងបានកំណត់នីតិវិធីបន្តទៀតនោះគឺ កំណត់ពេលវេលាក្នុងការកំណត់ក្នុងការបែងចែក ក្នុងការសាកសួរទៅលើមុខសញ្ញាដែលត្រូវសួរ គឺបានកំណត់ពេលវេលាជាក់លាក់ ។ ដូច្នេះ សូមលោកមេធាវីឲ្យបានជ្រាប។

ហើយមួយទៀតក៏យើងមានបញ្ហាខ្លះដែរថា ឧទាហរណ៍ថា អង្គជំនុំជម្រះច្រើននាក់អាចថាសួរ

ជាន់គ្នា សំណួរនេះសួរថាតើអង្គជំនុំជម្រះធ្វើយ៉ាងម៉េច? អង្គជំនុំជម្រះក៏បានពិភាក្សាបន្តបន្ទាប់នៅពេលដែលចូលទៅសម្រាកហ្នឹង មិនមែនទៅអង្គុយលេងសុខ្ទសាធទេ គឺដកបទពិសោធន៍ដើម្បីធ្វើការងារកុំឲ្យមានការច្រំដែល កុំឲ្យមានការខុសឆ្គង ដើម្បីជំរុញល្បឿននៃដំណើរការនីតិវិធីនេះប្រព្រឹត្តទៅបានឆាប់រហ័សប្រកបដោយយុត្តិធម៌ និងការចំណាយដឹកនាំក្នុងការសួរដេញដោលនេះ ឲ្យអស់លទ្ធភាពហើយចំបញ្ហា ។ សូមលោកមេធាវីជ្រាបពីបញ្ហានេះ ។ សូមអញ្ជើញលោកមេធាវី។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសុំបំភ្លឺអ្វីៗបន្ទាប់ពីសហសេវិកលោកមេធាវីគាត់បានលើកឡើងនោះ ហើយខ្ញុំគិតថាវាមានសារសំខាន់ដើម្បីរំឭកអង្គជំនុំជម្រះអំពីមាត្រា២៨ នៃវិធានផ្ទៃក្នុងរបស់ យើងដែលថាសាក្សីអាចបដិសេធមិនព្រមឆ្លើយដែលថាដាក់បន្ទុកលើខ្លួនឯង។ ប៉ុន្តែ នៅក្នុងករណីនេះវា មានន័យថា សាក្សីអាចស្នើសុំនៅស្ងៀមមិនឆ្លើយតបទាក់ទងទៅនឹងសំណួរដែលអាចនឹងឆ្លើយទៅដាក់បន្ទុកលើខ្លួនឯង ។ អ៊ីចឹង យើងដឹងវិធានមួយនេះច្បាស់លាស់ដែលថាយើងអាច យើងចាំច្បាស់ណាស់ ព្រោះថាយើងច្រើនសប្តាហ៍មកហើយ ។ អ៊ីចឹងហើយជាការល្អដើម្បីឲ្យមានសាក្សីហ្នឹង នឹងបញ្ជាក់បាន ដោយសារថាគាត់ចំណាយពេលសឹងថាម្ភៃបួនម៉ោងហើយ ។ ហើយបើសិនជាគាត់រក្សាសិទ្ធិនៅស្ងៀមមិន ឆ្លើយតបចំពោះសំណួរគាត់នោះបាន ប្រសិនបើជាគាត់គិតថា ឆ្លើយទៅនឹងដាក់បន្ទុកលើខ្លួនឯងនោះ ។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវីការពារក្តី ។ ខ្ញុំរំឭកឡើងវិញថា សិទ្ធិនេះបើខ្ញុំមិនភាន់ច្រឡំទេ ខ្ញុំបានជម្រាបជូនដល់សាក្សីរូបនេះតាំងពីផ្តើមដំបូងនៃដំណើរការនីតិវិធីម្ល៉េះ ហើយពេលនេះគឺគាត់នៅតែមានសិទ្ធិនៅក្នុងករណីដែលសំណួរណាដែលគាត់យល់ឃើញថា នាំឲ្យទម្លាក់ពិរុទ្ធភាពទៅលើខ្លួនគាត់ ។ ប៉ុន្តែ ខ្លួនគាត់មិនទាន់បានបង្ហាញអំពីបញ្ហានេះទេ អ៊ីចឹងកិច្ចនីតិវិធីដែលមានចែង វាលុះត្រាតែសំណួរណាដែលនាំឲ្យមានពិរុទ្ធភាព គាត់យល់ថា ខ្លួនឯងថាមានពិរុទ្ធភាពគាត់រក្សាសិទ្ធិមិនឆ្លើយ ។ អ៊ីចឹងនីតិវិធីអាចបន្តទៀតឬក៏ តម្រូវឲ្យឆ្លើយវាអាស្រ័យទៅលើករណីសមស្របហើយមានកិច្ចធានាផ្សេងៗដែលមានចែងនៅក្នុងវិធាន២៨ ដែលមានចែងសព្វគ្រប់អំពីលក្ខខណ្ឌនានានៅក្នុងការអនុវត្ត ថាតើត្រូវអនុវត្តតាមវិធីណា? តាមរបៀបណា? តាំងពី ៨.១ រហូតដល់ ៨.៩ ។ បញ្ហានេះអង្គជំនុំជម្រះបានត្រៀមលក្ខណៈក្នុងការពិភាក្សាច្រើនថ្ងៃច្រើនលើកមកហើយ ដើម្បីដឹកនាំគ្រប់គ្រងសវនាការរបៀបនេះ ។

អញ្ជើញលោកមេធាវី ។

[១៥:៤៣:៤៧]

**លោក អាឡាំង វែនណឺ៖**

សូមអរគុណលោកប្រធាន ។ អ៊ីចឹង ខ្ញុំអាចបញ្ជាក់បានថា ប្រសិនបើយើងបានជូនដំណឹងទៅសាក្សីអំពីទាក់ទងទៅនឹងសិទ្ធិរបស់គាត់តាមវិធាន២៨ហើយ ។ ខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំជឿថា កាតព្វកិច្ចនិង៣៥ និង៣៦ ក៏គប្បីរំឭកដែរ ប្រសិនបើគាត់មិនប្រើលទ្ធភាពមួយដែលថាគាត់ចង់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ គាត់អាចនឹងប្រឈមមុខនឹងកាតព្វកិច្ចដ៏ធ្ងន់ធ្ងរជាពិសេសទាក់ទងនឹងវិធាន៣៦.១ ហើយនិងផលវិបាកនៃការប្រើចំណុចនេះដែលយើងចែងនៅក្នុង៣៦.២ ហើយខ្ញុំមិនប្រាកដទេ ថាតើមេធាវីបានរំឭកគាត់អំពីកាតព្វកិច្ចនៅក្នុងវិធាន៣៥ និង៣៦ ដូចដែលបាននិយាយនៅក្នុងវិធាន២៨ នោះផងដែរ ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំគិតថា ការយល់ដឹងអំពីខ្លឹមសារនៃវិធាន២៨ នេះគឺវាអាស្រ័យទៅលើកាលៈទេសៈ ទៅលើសំណួរដែលជួប ថាតើពេលដែលជួបករណីណា? ដែលគាត់មិនព្រមឆ្លើយដោយសារមូលហេតុនៃបញ្ហាអាចប្រឈមនៅក្នុងការទម្លាក់កំហុសលើខ្លួនឯងនោះ ទើបត្រូវមានការដោះស្រាយ ។ ការដោះស្រាយនេះគឺមានលក្ខខណ្ឌចំពោះអ្នកផ្សេងទៀតដែលចូលរួមប្រសិនបើត្រូវការធ្វើជាសម្ងាត់ជាដើមនោះ ត្រូវធានាថាការផ្តល់សក្ខីកម្មរបស់គាត់ត្រូវធានាថា រក្សាការសម្ងាត់មិនទម្លាយទេ ប្រសិនបើទម្លាយគឺនោះគឺអ្នកដែលទម្លាយនូវព័ត៌មាននោះនៃសក្ខីកម្មនោះត្រូវទទួលខុសត្រូវ ។ ដូច្នេះវាអត់ទាន់ដល់ដំណាក់កាលនីមួយៗមិនមែនយើងពន្យល់នៅមុនពេលមិនទាន់ដល់រឿងហេតុនឹងវាកើតទេ ដល់រឿងហេតុហ្នឹងវាកើតទើបមានលក្ខខណ្ឌតាមវិធានមួយៗដែលអនុវិធាននៅក្នុងវិធាន២៨ នេះយកមកប្រើប្រាស់មកអនុវត្ត។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក សូមបន្តទៀត ហើយសូមមានការចាប់អារម្មណ៍ប្រសិនបើមានការសួរពាក់ព័ន្ធនឹងឯកសារ ដែលមានការផ្ទុះបញ្ចាំងត្រូវគប្បីអាចថតចម្លងឱ្យគាត់មួយច្បាប់ដើម្បីឱ្យគាត់ពិនិត្យមើលនូវទម្រង់ និងខ្លឹមសារដើម្បីឱ្យគាត់មានលទ្ធភាពក្នុងការពិចារណាហើយអាចឆ្លើយតបឱ្យត្រូវ ហើយនិងឱ្យបានច្បាស់លាស់នឹងសំណួរនោះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំជឿជាក់ថាឥឡូវនេះដោយមានការណែនាំតាមមតិទាំងអស់នេះ

ខ្ញុំមិនដឹងថាយើងចាត់តាំងមេធាវីប៉ុន្មានសម្រាប់សាក្សីនេះទេ ។ ប៉ុន្តែ គាត់បានទទួលការផ្ដល់យោបល់ហើយ ហើយគាត់យល់ហើយ គឺថាបើគាត់មិនឆ្លើយគាត់អាចនឹងធ្វើដូច្នោះបាន ។ អ៊ីចឹងហើយខ្ញុំគិតថាគាត់បានទទួលការណែនាំនេះច្បាស់ហើយ ហើយខ្ញុំមិនមានការជំទាស់អ្វីទៅនឹងការថតចម្លងឯកសារដែលបង្ហាញនៅលើអេក្រង់នេះទេ សូមអាចនឹងឲ្យទៅជនជាប់ចោទដែលគាត់អាចអាន ហើយអាចផ្ដល់សេចក្ដីសង្កេតបន្ថែមប្រសិនបើគាត់អាចធ្វើបាន ។ ខ្ញុំចង់ដឹងបន្ថែមទៀតថា តើនៅពេលដែលគាត់ធ្វើការនៅធ្វើការនៅស-២១ គាត់បាននិយាយប្រាប់យើងថា គាត់មិនមានសិទ្ធិដើរនៅក្នុងបរិវេណនោះបានទេ តើលោកបានឮមនុស្សស្រែកយំ ឬក៏ថ្ងូរស្រែកដោយសំឡេងណាមួយ? ថាតើបានឃើញមនុស្សរងការឈឺចាប់ក្នុង នៅទីនោះទេ? តាមមតិរបស់គាត់ គាត់ថាម្នាក់ៗមានសុខភាពល្អនៅស-២១ នោះ?

**ប្រធានអង្គជំនុំ៖**

ម៉ម ណៃ កុំអាលឆ្លើយនឹងសំណួរនេះ សូមជនជាប់ចោទមានលើកដៃចង់មាននិយាយបញ្ហាអីទៅ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ជម្រាបប្រសាសន៍លោកចៅក្រមជាទីគោរព! បញ្ជីបែបនេះខ្ញុំឃើញកាលដែលសម័យស៊ើបអង្កេត គេប្រគល់មកឲ្យខ្ញុំផ្ទាល់ខ្លួនខ្ញុំក៏ខ្ញុំភ្ញាក់ដែរ ។ ប៉ុន្តែ ខ្ញុំទទួលស្គាល់ពីព្រោះខ្ញុំឃើញមានអក្សរខ្ញុំនៅលើទំព័រណាមួយទេ ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា ទម្រង់នេះគឺជាទម្រង់ដែលមិត្តហ៊ី ប្រឌិតរៀបចំដើម្បីឲ្យមានលក្ខណៈខាងការិយាល័យឲ្យវាស្រួលបួល នោះដាក់ឈ្មោះរង់ចាំទៅហើយ ប្រហែលជាខ្ញុំបានសុខចិត្តឲ្យគេធ្វើទម្រង់នេះ ។ ខ្ញុំមានចំណារខ្ញុំមួយ នៅក្នុងចំណោមប៉ុន្មានសន្លឹកនោះមានចំណារខ្ញុំមួយ ដោយសារចំណារហ្នឹងហើយបានខ្ញុំទទួលស្គាល់ថាអាបញ្ជីនេះពិតជាបញ្ជីស-២១ ។ ដូច្នេះ បងម៉ម ណៃ ក៏ភ្ញាក់ផ្អើលដែរអត់ជារឿងអីប្លែកទេ ព្រោះទម្រង់នេះថ្មី ដូច្នេះអាចមិនមានស៊ីញេ បងម៉ម ណៃ ឬក៏មានយ៉ាងច្រើនមួយសន្លឹក ។ នេះ ខ្ញុំសូមបញ្ជាក់អំពីបញ្ហាទម្រង់នេះ ធ្វើឲ្យខ្ញុំទាំងពីរនាក់ភ្ញាក់ផ្អើលអ៊ីចឹង ប៉ុន្តែ ខ្ញុំបានឃើញរួចមកហើយ ខ្ញុំសូមបញ្ជាក់អ៊ីចឹងថា ទម្រង់នេះថ្មី ។ សូមគោរពជូនប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក បន្ត អាចសួរឡើយវិញ ដើម្បីឲ្យគាត់ចងចាំនូវសំណួរអំមិញបានច្បាស់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមទទួលថា ខ្ញុំធ្វើឲ្យមានការច្របូកច្របល់ថាមិនដឹងត្រូវសួរទៅណា ។ ប៉ុន្តែ ឥឡូវខ្ញុំសួរទៅជនជាប់ចោទ គាត់បានបំភ្លឺ ហើយខ្ញុំក៏ចង់ដឹងបន្ថែមទៀតដែលជាចំណុចសំខាន់ អនុលោមតាមសម្ដីរបស់គាត់ ដែលគាត់ជាប្រធានស-២១ ។ តើលោកដឹងថាមានទម្រង់ណាមួយដែលថាវាមានចំណារនៅលើហ្នឹង ដែលថាអាចហ្នឹងចេញមកពីឈ្មោះ ចាន់ ហើយតាមការពន្យល់ គឺថាចេញមកពី ហ៊ា ជាអ្នករៀបចំទៅវិញ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម! នេះជាកិច្ចការការិយាល័យសុទ្ធសាធ មិនទាក់ទងដល់ការចាប់ខ្លួនមនុស្ស ឬក៏ទទួលមនុស្សទេ ។ បញ្ជីមកដល់ពីលើកមុនមិនទាន់មានលក្ខណៈអីរបៀប បារាំងហៅ ស្ទីលបែបបទនោះ ។ “បងជាទីគោរព” ដោយខាងចុងបញ្ចប់ “ដោយគោរព” ដូចអ៊ីចឹងទេ ។ ដោយគេឃើញរបៀបខ្ញុំសរសេរទៅខាងលើ គេក៏យកអាហ្នឹងមកប្រឌិត ។ ដល់មកប្រឌិតប្រហែលជាខ្ញុំអនុញ្ញាតឲ្យមិត្តហ៊ា សរសេរឈ្មោះអ្នកកាន់បញ្ជីហ្នឹងដាក់ ចាន់ ខ្ញុំអាច ។ ហើយក្នុងបញ្ជីប៉ុន្មានសន្លឹកដែលចៅក្រមស៊ើបអង្កេតយកមកប្រគល់ឲ្យខ្ញុំមើលនោះ ខ្ញុំមើលតតើក១ទេ ខ្ញុំច្រើនថ្ងៃដែរ ខ្ញុំបានច្រើនថ្ងៃដែរយកមកមើល ។ ខ្ញុំមានស៊ីញ៉េខ្ញុំមួយ អក្សរខ្ញុំមួយ ខ្ញុំថា អានេះមិនមែនខ្សែខ្មែរសេរីទេ ខ្សែ *សេអ៊ីអា* ខ្ញុំចារអ៊ីចឹងច្បាស់ នៅក្នុងចំណោមបញ្ជីប៉ុន្មាននេះ ។ ក៏ប៉ុន្តែ ក្នុងចំណោមបញ្ជីទាំងអស់នោះខ្ញុំសង្ស័យដូចជាមានឃើញស៊ីញ៉េបង ម៉ម ណៃ មួយសន្លឹក ។

[១៥:៥២:៣២]

ដូច្នេះ សរុបមកបញ្ជីនេះខាងការងាររដ្ឋបាលសុទ្ធសាធ អត់ទាក់ទងដល់ការចាប់ អត់ទាក់ទងដល់ការទទួលស្អីៗទេ គឺទាក់ទងការិយាល័យដើម្បីរក្សាចំនួនមនុស្សឲ្យមានទម្រង់បែបនេះ តែប៉ុនន៉ុងឯង ។ ប៉ុន្តែ ជាទម្រង់បែបបទមួយថ្មី ដែលមិត្តហ៊ា ប្រឌិតឡើង ។ អ្នកប្រឌិតនេះ គឺមិត្តហ៊ា ទេ មិនមែនខ្ញុំ ហើយក៏អាចមិនមែនបង-- ពិតជាមិនមែនបង ម៉ម ណៃ ដែរ ។ ប៉ុន្តែ បែបពេលនុ៎ង គាត់ក៏យល់ស្របតាមការចាត់តាំងនឹងដែរ តែគាត់ភ្លេចទៅ ព្រោះរឿងវាតិចពេក បើប្រៀបធៀបនឹងរឿងផ្សេងទៀតដែលច្រើន រឿងនេះតិចពេក ។ ខ្ញុំបញ្ជាក់ជូនប៉ុណ្ណោះ តាមការចងចាំរបស់ខ្ញុំក្នុងឋានៈខ្ញុំជាប្រធាន ដែលដឹងកិច្ចការអ៊ីចឹងៗខ្លះច្រើនជាងគេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប៉ុន្តែ ខ្ញុំចង់ដឹងថា តើឈ្មោះចាន់ គឺបញ្ចូលនៅក្រោមបង្គាប់របស់លោកផងដែរ ដែលលោកស្នើសុំឲ្យហ៊ី ធ្វើការបំពេញការងារនុំង?

**ជនជាប់ចោទ៖**

នេះពេលដែលខ្ញុំឃើញ នៅពេលដែលលោកចៅក្រមស៊ើបអង្កេតគាត់ប្រគល់មកឲ្យខ្ញុំ ខ្ញុំភ្ញាក់ដែរដំបូង ។ ដូច្នេះ ការដែលខ្ញុំគិតបែបនេះ គឺជាការសន្និដ្ឋានទេ តែខ្ញុំអត់ប៉ិានប្រកែកទេ ព្រោះមានអក្សរខ្ញុំនៅហ្នឹងមួយសន្លឹក មួយសន្លឹកមួយនេះមានអក្សរខ្ញុំ ។ ដូច្នេះ បើតាមការវិភាគហើយនិងការសន្និដ្ឋានគឺឈ្មោះចាន់ ហ្នឹង ខ្ញុំអនុញ្ញាតតាមគោលការណ៍ ដែលមិត្តហ៊ី ស្នើសុំ ។ ឲ្យគាត់សរសេរឈ្មោះ ចាន់ហ្នឹង សម្រាប់ជាអ្នកកាន់កាប់បញ្ជីនេះ ។ ដូច្នេះ ជារឿងការងាររដ្ឋបាល អត់មានជារឿងការងារចាប់ការងារស្អីៗ គឺការងាររដ្ឋបាលដើម្បីរក្សាបញ្ជីនេះឲ្យមានឈ្មោះអ្នកទោសនៅបានគ្រប់គ្រាន់ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមអភ័យទោស ប៉ុន្តែខ្ញុំមិនយល់ការពន្យល់របស់លោកសោះ ។ ហេតុអ្វីបានជាលោកស្នើសុំឲ្យដាក់ឈ្មោះ ចាន់ នោះ ដោយសារតែ ហ៊ី ជាអ្នកទទួលបន្ទុក ហើយលោកចង់លាក់បាំងអ្វីនៅទីនេះ ។ លោកចង់លាក់បាំងពីយើង ឬយ៉ាងម៉េច?

**ជនជាប់ចោទ៖**

លោកប្រធាន លោកចៅក្រមជាទីគោរព! អនុប្រធានរបស់ខ្ញុំ គឺមិត្តហ៊ី កិច្ចការទាំងអស់ គេដឹង គេគ្រប់គ្រង គេរាយការណ៍ឲ្យខ្ញុំ គេសុំសេចក្តីសម្រេចពីខ្ញុំ ។ ចំណែកបញ្ជីនេះ ទៅខាងផ្នែករដ្ឋបាលទេ ដើម្បីរក្សាឲ្យមានជាក្រដាស ជាស្នាមទុកនៅការិយាល័យប៉ុននុំង ។ ម្ល៉ោះហើយបានៗជាគេដាក់ឈ្មោះចាន់ ។ ហើយខ្ញុំប្រហែល ប្រហែលអីពិតជាអនុម័ត ឲ្យគេរួចទៅហើយ ។ ក៏ប៉ុន្តែ រឿងវាតិចតួចពេកខ្ញុំភ្លេចបាត់ទៅ ហើយក៏ប្រហែលបង ម៉ម ណៃ ក៏ភ្លេចដែរ បានជាគាត់ធ្វើម៉ឹងម៉ាំងអ៊ីចឹង ។ បញ្ជីនេះវាពិតជាបញ្ជីស-២១ ហើយ អ្នករៀបចំ គឺគេ ខ្ញុំជាអ្នកអនុម័ត យកឈ្មោះបង ម៉ម ណៃ ទៅដាក់ ដើម្បីកាន់កាប់ឯកសារបញ្ជីនេះឯងតែប៉ុននុំង ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំជឿថា យើងយល់ទៅលើចំណុចនេះហើយ ក៏ប៉ុន្តែ យ៉ាងណាក៏ដោយ យើងមានការយល់ច្រឡំ

នៅទីនេះដែរ ។

**សះ** លោក ម៉ម ណៃ ខ្ញុំសូមលើកសំណួររបស់ខ្ញុំឡើងវិញ ដែលខ្ញុំបានសួរមុនហ្នឹង ។ នៅពេលដែលលោកបំពេញការងារនៅស-២១ តើលោកធ្លាប់ឮមនុស្សស្រែក ធ្លាប់មនុស្សថ្ងូរ ឬក៏ៗលោកធ្លាប់ឃើញមនុស្សឈឺដែរឬទេ? ឬក៏តាមលោកនោះ គឺថាអ្នកជាប់ឃុំហ្នឹងគាត់សុទ្ធតែមានសុខភាពល្អទាំងអស់ ។

**ឆះ** ជម្រាបលោកចៅក្រម! មុននឹងចូលដល់ចម្លើយដែលខ្ញុំនឹងត្រូវឆ្លើយនោះ ខ្ញុំសូមជម្រាបលោកអំពីស្ថានភាពនៃទីតាំងសិន ។ ផ្ទះខ្ញុំសួរចម្លើយដាច់ពីគេ ផ្ទះខ្ញុំនៅដាច់ពីគេ គឺដាច់គ្នាឆ្ងាយ។ ហើយទីពីរ គឺគ្មានសិទ្ធិដើរហើរទេ ។ ដូច្នេះ ក៏គ្មានអីស្តាប់ឮដែរ ។ នេះសូមលោកចៅក្រមជ្រាប ។ ឯថាស្ថានភាពអ្នកទោសយ៉ាងម៉េចនោះ? ខ្ញុំមិនដឹងដែរ ខ្ញុំឃើញតែគេយកមកឲ្យខ្ញុំសួរ មនុស្សហ្នឹងនៅៗល្អគួរសម ។ ហើយតាមវិភាគ គឺថាមនុស្សហ្នឹងគេទើបតែបញ្ជូនមកបានជាវានៅគួរសមអ៊ីចឹង គេមិនមែនឲ្យខ្ញុំទៅរើសមនុស្ស ឬក៏គេយកមនុស្សដែលជាប់រាប់ឆ្នាំមកឲ្យខ្ញុំសួរទេ ។ សូមលោកចៅក្រមជ្រាបជាព័ត៌មាន ។

**សះ** យោងតាមលោក អ្នកជាប់ឃុំដែលគេនាំមកស-២១ ថាតើពួកគេនោះជាខ្មាំងបដិវត្តន៍ទាំងអស់ ឬក៏ពួកគេនោះបានប្រព្រឹត្តបទល្មើសដែរឬទេ? ដោយសារតែយើងឃើញមានការចាប់ខ្លួនពួកគេមក។

**ឆះ** ខ្ញុំសូមជម្រាបលោកចៅក្រម ខ្ញុំចង់បញ្ជាក់ តើលោកចៅក្រមសួរអំពីអ្នកជាប់ចោទខ្មែរ ឬអ្នកជាប់ចោទយួន? លោកចៅក្រមមេត្តាបញ្ជាក់ខ្ញុំនឹងជម្រាបជូន ។

**សះ** លោកអាចឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំនេះ ដោយលើកអំពីប្រភេទទាំងពីរនេះ ដាច់ដោយឡែកពីគ្នា ។

[១៥:៥៩:៣៨]

**ឆះ** សូមជម្រាបលោកចៅក្រម! គឺថាប្រភេទជនដែលជាប់ចោទខ្មែរ ។ ខ្ញុំក៏មានជំនឿថា មិនមួយរយភាគរយជាខ្មាំងទេ ។ ក៏ប៉ុន្តែ មិនមួយរយភាគរយជាមនុស្សត្រឹមត្រូវដែរ គឺមនុស្សនោះមានប្រព្រឹត្តខុសឆ្គងត្រង់ថាតិចនិងច្រើនតែប៉ុណ្ណោះទេ។ នេះចំពោះខ្មែរ ។ ឯចំពោះពួកយួនវិញ ខ្ញុំសួរតែគេបញ្ជូនមកឲ្យខ្ញុំសួរ គឺថាប៉ះស៊ីវិលតែម្នាក់នាក់ ឬពីរនាក់ទេ ។ ស៊ីវិលនេះក៏គេចាប់មកពីសមរភូមិដែរមិនដឹងថាគេចូលទៅខាងនុ៎ងដីយួនចាប់ក៏មិនដឹង អីក៏មិនដឹង ខ្ញុំគ្រាន់តែដឹងថា ខាងទ័ពគេបញ្ជូនមកអ៊ីចឹងសួរទៅ។ ហើយចំពោះជាទាហាន ខ្ញុំមានជឿជាក់ក្នុងចិត្តថា ជាពួកឈ្លានពានទឹកដីកម្ពុជាសុទ្ធសាធ។

អត់មានអ្នកល្អ ជាពួកមកវ៉ៃខ្មែរយកប្រទេសខ្មែរ ។ នេះជាការសន្និដ្ឋាន ជាការបញ្ជាក់របស់ខ្ញុំ ។ សូមលោកចៅក្រមជ្រាប ។

**ស៖** ប្រសិនបើខ្ញុំសរុបមកវិញ ទាក់ទងទៅនឹងអ្នកជាប់ឃុំឃាំងរៀតណាម អ្នកទាំងអស់នោះត្រូវបានគេចាប់ដោយហេតុផលល្អ ដែលវាហេតុផលទាំងនោះពាក់ព័ន្ធនឹងប្រទេសកម្ពុជា ។ មិនមាននរណាមួយដែលស្លូតត្រង់នោះទេ គឺបានន័យថា អ្នកទាំងអស់នោះត្រូវបានចាប់មកក្នុង ចូលក្នុងស-២១ ដោយមូលហេតុល្អទាំងអស់ ។

**ឆ៖** សូមជម្រាបលោកចៅក្រម! ខ្ញុំក៏មិនយល់ដែលលោកលើកឡើងថា ជាមូលហេតុល្អពាក្យនេះក៏ខ្ញុំមិនយល់ មិនដឹងលោកចង់ថាម៉េច ។ លោកអាចបញ្ជាក់ន័យរបស់លោកថា ល្អហ្នឹង ឲ្យខ្ញុំបាទដឹងផង ។

**ស៖** ខ្ញុំនឹងនិយាយយោងទៅដល់ចម្លើយរបស់លោកមួយទាក់ទងទៅនឹងឯកសារលេខ D58/2 នៅពេលដែលលោកត្រូវបានសួរសម្ភាស ដោយអ្នកស៊ើបអង្កេតនៅក្នុងទំព័រទីបួនជាភាសាបារាំង ។ លោកបានលើកឡើងថា “ខ្ញុំជឿថា អ្នកដែលត្រូវបានគេចាប់ខ្លួន គឺប្រាកដណាស់អ្នកទាំងអស់នោះប្រព្រឹត្តខុសតិចតួចនិងធ្ងន់ធ្ងរ” ។ ដូច្នេះ យោងទៅតាមរូបលោក បុគ្គលទាំងឡាយដែលបាន ត្រូវបានគេចាប់បញ្ជូលមកស-២១ តើពួកគេទាំងអស់នោះបានប្រព្រឹត្តខុសដែរឬទេ ដែលវាជាការបញ្ជាក់ត្រឹមត្រូវថាពួកគេសមនឹងចាប់ចូលមកស-២១?

**ឆ៖** សូមជម្រាបលោកចៅក្រម! បញ្ហាទោសកំហុសដែលគេចាប់មកពីមូលដ្ឋានបញ្ជូនមកឲ្យស-២១ គឺខ្ញុំមិនដឹងជាទោសកំហុសយ៉ាងម៉េចទេ តែខ្ញុំនិយាយជាមួយនឹងអ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតខ្ញុំថា “មានខុសតិច ហើយនិងច្រើន” ខុសគឺខុស ក៏ប៉ុន្តែមានខុសតិច ហើយនិងច្រើនបានជាគេចាប់មក ។ តែត្រង់មូលដ្ឋានគេឃើញកំហុសប៉ុនណា អាហ្នឹងខ្ញុំមិនដឹងទេ ព្រោះខ្ញុំដឹងតាមខ្ញុំសួរចម្លើយ ព្រោះមានខុសមែន ។ ក៏ប៉ុន្តែ វាគ្រាន់តែស្រាល ហើយនិងធ្ងន់ប៉ុណ្ណឹងទេ ។ នេះសូមចៅក្រមជ្រាប ។

**ស៖** យើងចូលត្រឡប់ទៅលើការពន្យល់របស់លោកវិញ តើលោកជឿដែរឬទេថា ការវិនិច្ឆ័យទៅលើអ្នកដែលចាប់មកពីមូលដ្ឋាននោះអាចខុស ហើយការដែលគេវិនិច្ឆ័យថា ពួកគេយ៉ាងម៉េចយ៉ាងម៉េចនោះអាចខុស?

**ឆ៖** ខ្ញុំនៅតែមិនយល់ ការសួររបស់លោកចៅក្រមគឺថា លោកចង់និយាយថា តើអ្នកមូលដ្ឋានខុស ឬក៏អ្នកដែលគេចាប់មកខុស?

**ស៖** លោកបានលើកឡើងជូនយើងខ្ញុំថា បុគ្គលដែលបញ្ជូលជូនមកស-២១ អ្នកទាំងអស់នោះគឺត្រូវបានចាប់ខ្លួនដោយពួកមូលដ្ឋាន អ្នកមូលដ្ឋាននៅទីនោះ ។ ដូច្នេះ តើការចាប់ខ្លួនបែបនោះ គឺបានធ្វើឡើងខុសដែរឬទេ? បានន័យថា ចាប់ខុសដោយសារតែអ្នកទាំងអស់នោះ ហើយថា អ្នកដែលត្រូវបានចាប់មកអាចជាអ្នកជនស្លូតត្រង់មួយរយភាគរយ ឬក៏អាចជនស្លូតត្រង់ហាសិបភាគរយ តើលោកអាចនិយាយបញ្ជាក់លើចំណុចបានដែរឬទេ?

**ឆ៖** ជម្រាបលោកចៅក្រម! ខ្ញុំមិនអាចសន្និដ្ឋានទេ ។ ខ្ញុំសូមចប់ប៉ុណ្ណឹង ។

**ស៖** យើងចូលទៅដល់ឯកសារដដែលនេះ នៅពេលដែលអ្នកស៊ើបអង្កេតបានសួរលោក លោកបានពន្យល់ជូនគេថា លោកមិនខ្លាចស្លាប់ទេនៅពេលនោះ ហើយលោកនឹងលះបង់ខ្លួនរបស់លោកដោយជូនប្រជាជននិងបក្ស ។ ហើយលោកក៏បានពន្យល់បដិវត្តន៍មានន័យយ៉ាងម៉េចផងដែរ គឺបដិវត្តន៍មានបីដំណាក់ គឺបានន័យថា ការតស៊ូ ការតតាំងរវាងអ្នកពួកចក្រពត្តិ ហើយទីពីរ គឺសង្គមនិយម ហើយនិងទីបី បញ្ហាកុម្មុយនីស្ត ។ ហើយលោកបានធ្វើការសន្និដ្ឋាននៅក្នុងនោះថា បដិវត្តន៍មិនទទួលជោគជ័យដោយសារតែមានខ្មាំងស៊ីរូងផ្ទៃក្នុង ហើយនិងខ្មាំងនៅខាងក្រៅ ដូចជាវៀតណាម ។ ដូច្នេះ តើលោកអាចជម្រាបបន្ថែមទៅលើចំណុចនេះដែរឬទេ?ហើយវាស៊ីគ្នាទៅនឹងការយករបស់លោកដែរឬទេ?ហើយវាមានការស៊ីគ្នាទៅនឹងការសោកស្តាយដែរឬទេ? លោកអាចបញ្ជាក់ទៅលើចំណុចហ្នឹង?

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនលោកចៅក្រម កាលណោះខ្ញុំនិយាយថា បដិវត្តន៍វាមានបីដំណាក់កាលអ៊ីចឹងហើយ បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ, បដិវត្តន៍សង្គមនិយម ហើយនិងបដិវត្តន៍កុម្មុយនីស្តនិយម នេះម្យ៉ាង ។ ម្យ៉ាងទៀត ខ្ញុំនិយាយថា មកបដិវត្តន៍ត្រូវទទួលបរាជ័យ មកពីមានការវាទំនាស់នៅក្នុងផ្ទៃក្នុងរបស់ប្រជាជនកម្ពុជា ហើយនិងមានការឈ្លានពានពីខាងវៀតណាម អាហ្នឹងខ្ញុំនិយាយអ៊ីចឹងហើយខ្ញុំឃើញថា វាអ៊ីចឹង វាពីព្រោះនៅក្នុងសង្គមកម្ពុជាពេលនោះ វាចាប់បែកបាក់គ្នា ហើយជាប្រវត្តិ-សាស្ត្រ កាលណាតែបែកបាក់សាមគ្គីហើយ វាចាញ់គេហើយ ។ នេះសូមលោកចៅក្រមជ្រាប ។

[១៦:១០:១៥]

**ស៖** តើលោកអាចពន្យល់ឱ្យបានច្បាស់ជាងនេះដែរឬទេ ថាតើនរណាគេជាអ្នកទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើង? ថាតើលោកមានការសោកស្តាយរបស់លោកនោះ តើការសោកស្តាយរបស់

លោកនោះយ៉ាងម៉េចដែរ? លោកមានការសោកស្ដាយអ្វីទៅ?

**ឆ៖** សូមជម្រាបលោកចៅក្រម! ការសោកស្ដាយរបស់ខ្ញុំ គឺថាសោកស្ដាយត្រង់ថា ប្រទេសយើងត្រូវគេឈ្លានពាន ។ និយាយឲ្យចំគឺថា ក្រោយពីអាមេរិកាំង គឺត្រូវយួនឈ្លានពាន អាហ្នឹងខ្ញុំសោកស្ដាយ ប្រជាជនមិនបានសុខ ប្រទេសជាតិក៏វាត្រូវហិនហោច ។ អាហ្នឹងខ្ញុំសោកស្ដាយអ៊ីចឹង ។

**ស៖** ខ្ញុំជឿថា ខ្ញុំយល់ថា នៅពេលដែលលោករៀននៅវិទ្យាស្ថានគរុកោសល្យ លោកបានរៀនភាសាអង់គ្លេសតិចតួចដែរ តើត្រឹមត្រូវដែរឬទេ? តើលោកបានរៀនភាសាអង់គ្លេសដែរឬទេ លោក ម៉មណៃ?

**ឆ៖** រៀនភាសាអង់គ្លេសបានតិចតួចទេ ។ និយាយក៏វាមិនបានជាអ្នកនិយាយ គ្រាន់ថាដឹងហូបដឹងចុក ដឹងន៎ែ ទទួលទានទឹក ទទួលអីហ្នឹងទេ ។ ឯការសន្ទនាគ្នាច្បាស់លាស់ អាហ្នឹងខ្ញុំទៅមិនរួចទេ ។

**ស៖** ខ្ញុំដឹង ខ្ញុំចង់សួរលោក តើលោកដឹងអត្ថន័យពាក្យពីរដែរឬទេ? ពាក្យភាសាអង់គ្លេស វាគឺពាក្យថា *No fear* តើលោកមានន័យ តើលោកដឹងអត្ថន័យរបស់វាដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ចំពោះករណីនេះ ខ្ញុំពុំមានសំណួរបន្ថែមទៀត ដើម្បីសួរទៅកាន់សាក្សីនោះទេ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរថែមទៀតទេ ។

បាបើមិនមានទេ ខ្ញុំគិតថា ថ្ងៃនេះអង្គជំនុំជម្រះសម្រេចថា ផ្អាកសវនាការត្រឹមនេះ ហើយសវនាការនឹងលោកទៅបន្តនៅថ្ងៃស្អែក ចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ។

សូមអញ្ជើញ ។

**លោក វីលៀម ស្មីត៖**

អរគុណលោកប្រធាន ។ ខ្ញុំសូមលើកឡើងដោយសង្ខេប ខ្ញុំមានឯកសារដែលខ្ញុំចង់បញ្ជាជនជាប់ចោទនៅថ្ងៃស្អែក គឺឯកសារនេះ វាវែង ខ្ញុំឆ្ងល់ ថាតើយើងអាចផ្ដល់ឯកសារនេះទៅកាន់សាក្សីដែរឬទេ ដើម្បីឲ្យគាត់អាចពិនិត្យនៅក្នុងយប់នេះ ហើយដើម្បីឲ្យការតាំងសំណួរនោះ អាចដំណើរការទៅមានលក្ខណៈរលូន ។ ការលើកឡើងដូច្នេះ ដើម្បីខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។

លោក ហ្វ្រង់ស្វ័រ រូ សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

មេធាវីការពារក្តីចង់សុំសួរថា តើឯកសារនោះ ជាឯកសារអ្វីមុនពេលដែលអង្គជំនុំជម្រះធ្វើការសម្រេច ហើយខ្ញុំសង្ឃឹមថា សហព្រះរាជអាជ្ញា គឺគាត់គួរតែអនុវត្តមុខនាទី ឬក៏នីតិវិធីនៃការដេញដោល ហើយជម្រាបទៅដល់មេធាវីការពារក្តី ។

**លោក វីលៀម ស្មីត៖**

ខ្ញុំបាននិយាយខុស គឺមិនមែនឯកសារសម្រាប់ជនជាប់ចោទទេ គឺឯកសារដើម្បីដាក់បង្ហាញនិងឲ្យផ្តល់ជូនទៅកាន់សាក្សី ។ ខ្ញុំសូមអភ័យទោសទៅលើចំណុចនេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ប៉ុន្តែខាងមេធាវីការពារក្តីចង់ដឹង តើឯកសារអ្វីដែលសហព្រះរាជអាជ្ញាចង់ផ្តល់ជូននោះ។ ចំពោះខ្ញុំ វាហាក់ដូចជាវាសាមញ្ញទេដែលថាយើងចង់ដឹងឯកសារអ្វី ដែលសហព្រះរាជអាជ្ញាចង់ដឹង ។ សូមឲ្យលោកឆ្លើយតបទៅនឹងខ្ញុំ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន គឺ IS ឧបសម្ព័ន្ធ “គ” គឺកំណត់របស់ ចាន់ ដែលមាន៣៩៦ទំព័រ ដើម្បីឲ្យធ្វើយ៉ាងណាឲ្យមានការស្គាល់ ហើយនិងសុំទៅលើឯកសារហ្នឹង ហើយយើងមានកំណត់ហេតុពេញលេញនៅថ្ងៃស្អែក ។

[១៦:១៦:៣១]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ប្រសិនបើឯកសារនេះមែនដែលបានលើកឡើងនោះ គឺថាមេធាវីការពារក្តីមិនមានការជំទាស់នោះទេ គ្រាន់តែខ្ញុំចង់បញ្ជាក់ ថាតើឯកសារអ្វីដែលគាត់ចង់ដឹងនោះ ។ ដូច្នេះ យើងខ្ញុំមិនមានការជំទាស់ទៅលើការដាក់ឯកសារនេះទេ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងដោយសារការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើង គឺការ

ផ្តល់ជូននូវឯកសារដែលជាកំណត់ដៃនៅក្នុងសំណុំរឿងស្រាប់ ហើយមេធាវីការពារក្តីក៏មិនជំទាស់នោះ ដូច្នេះ អង្គជំនុំជម្រះប្រកាន់ជំហរអនុញ្ញាតខាងសហព្រះរាជអាជ្ញា ផ្តល់នូវឯកសារនោះទៅដល់សាក្សីជាមុនដើម្បីបានពិនិត្យ ហើយនិងងាយស្រួលក្នុងការសួរដេញដោលនៅថ្ងៃស្អែក ដើម្បីបានឆាប់រហ័សផង ។

សាជាថ្មីម្តងទៀត អង្គជំនុំជម្រះផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការសូមលើកបន្តទៅថ្ងៃស្អែកចាប់ពីពេលវេលាម៉ោងប្រាំបួនព្រឹកទៅ ។ ហើយលោក ម៉ម ណៃ ដំណើរការនីតិវិធីនៃការស្តាប់សក្ខីកម្មរបស់លោកមិនទាន់បានចប់ទេ ដោយសាររហូតដល់ពេញមួយថ្ងៃនេះ ទើបតែបានខាងអង្គជំនុំជម្រះប៉ុណ្ណោះ ។ អ៊ីចឹងនៅភាគីផ្សេងៗ ដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរហ្នឹងនៅមានឱកាសក្នុងការសាកសួរដល់លោកទៀត។ អ៊ីចឹង សូមអញ្ជើញលោកមកកាន់សាលសវនាការសម្រាប់ថ្ងៃស្អែកប្រហែលជាមួយថ្ងៃទៀត ។ លោកយល់ទេ ហើយមន្ត្រីតុលាការសូមសម្របសម្រួល ដើម្បីឲ្យលោក ម៉ម ណៃ បានទៅកន្លែងសម្រាក ដោយសហការជាមួយនិងខាង *WESU* ។

ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនាំគាត់មកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ៕

*[សវនាការផ្អាកនៅម៉ោង ១៦:១៩ នាទី]*